
សិក្សានីតិសាស្ត្រ



អនីតិសង្ការ

ដោយ៖

ចក សម្បត្តិ

រក្សាសិទ្ធិ©

បោះពុម្ពឆ្នាំ ២០១៤

ការផ្សាយរបស់សាលាត្រាជ្ញ

អារម្ភកថា

ស្ថិតក្នុងបរិបទនៃការកសាងប្រទេសជាតិឡើងវិញលើគ្រប់វិស័យ បន្ទាប់ពីមហាវិនាសកម្មដែលបង្កឡើងដោយរបបប្លែរក្រហម ប្រទេសកម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលកែទម្រង់ស៊ីជម្រៅលើវិស័យសំខាន់ៗជាច្រើន ជាពិសេសក្នុងនោះ ការកែទម្រង់ប្រព័ន្ធច្បាប់ និង តុលាការ ក៏ជាការងារមួយដែលកំពុងតែជំរុញការយ៉ាងល្អផងដែរ។ ការបណ្តុះបណ្តាលអ្នកវិជ្ជាជីវៈច្បាប់ថ្មីៗជាកត្តាដែលមិនអាចខ្វះបានដើម្បីឲ្យការងារនេះទទួលបានជោគជ័យ ដោយមានការចូលរួមពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ។ ជាក់ស្តែងច្បាប់គោលចំនួនបួនត្រូវបានតាក់តែងឡើង និង ប្រកាសឲ្យប្រើរួចមកហើយ គឺទីមួយ ក្រមព្រហ្មទណ្ឌ, ទីពីរ ក្រមនីតិវិធីព្រហ្មទណ្ឌ, ទីបី ក្រមរដ្ឋប្បវេណី, និង ទីបួន ក្រមនីតិវិធីរដ្ឋប្បវេណី។ ច្បាប់ទាំងនេះនាំឲ្យមានអត្ថិភាពនៃប្រព័ន្ធច្បាប់ដ៏រឹងមាំមួយ ដែលជាលក្ខណៈចាំបាច់ក្នុងការធានានូវសន្តិសុខគតិយុត្តនៅក្នុងសង្គមកម្ពុជា។

ទន្ទឹមនឹងនេះដែរបញ្ហាគតិយុត្តមួយចំនួននៅតែចោទជាបញ្ហាធ្ងន់ធ្ងរនៅឡើយនៅក្នុងការអនុវត្តជាក់ស្តែង។ **អនីតិសង្វាស** (ការរស់នៅជាមួយគ្នាជាប្តីប្រពន្ធក្រៅចំណងអាពាហ៍ពិពាហ៍) ក៏ជារឿងដែលកំពុងតែកើតឡើងនៅក្នុងសង្គមច្នៃរយ៉ាងសំបើមដោយសារកត្តាជាច្រើន តែបញ្ហាធំគឺការមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ (សំបុត្រអត្រានុកូលដ្ឋាន)។ ការងារអត្រានុកូលដ្ឋានគឺធ្វើឡើងក្នុងបំណងដើម្បីកំណត់អំពីភាពស៊ីវិលរបស់ពលរដ្ឋណាម្នាក់នៅក្នុងគ្រួសារ សង្គមជាតិ ហើយតាមរ

www.elibraryofcambodia.org

Scanned with CamScanner

យៈយន្តការនេះ វាបង្កើតជាសិទ្ធិ និងកាតព្វកិច្ចពេញលេញតាមផ្លូវច្បាប់។ ក្នុងនោះដែរ សំបុត្រអាពាហ៍ពិពាហ៍ដែលជាសំបុត្រអត្រានុកូលដ្ឋាន ក៏មានបំណងញែកឲ្យដាច់ដែររវាងអាពាហ៍ពិពាហ៍ និង អចិន្ត្រៃសង្វាស។ ការញែកឲ្យដាច់ស្រឡះនេះ មិនមែនក្នុងបំណងត្រឹមតែកំណត់ឲ្យបានច្បាស់អំពីសញ្ញាណគតិយុត្តនីមួយៗ នោះទេ តែក៏មានបំណងចង់វែកញែក និង កំណត់អំពីអានុភាពគតិយុត្តរបស់វានីមួយៗ ផងដែរ។

ក្នុងស្ថានភាពបច្ចុប្បន្ន ការអនុវត្តនៅតាមសាលាជម្រះក្តីនានាគ្មានឯកភាពក្នុងការកំណត់អំពីអ្វីទៅជាអចិន្ត្រៃសង្វាស និង អានុភាពរបស់វានោះទេ ដោយសាលាជម្រះក្តីទាំងនោះមានការបកស្រាយផ្សេងៗពីគ្នា ឃោងទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួនដោយខ្ចីសញ្ញាណគតិយុត្តនៃអាពាហ៍ពិពាហ៍មកអនុវត្តនៅក្នុងរឿងក្តីអចិន្ត្រៃសង្វាស។ ត្រង់ដែននៃការខ្ចីបទប្បញ្ញត្តិអាពាហ៍ពិពាហ៍មកអនុវត្តន៍ក្នុងរឿងក្តីអចិន្ត្រៃសង្វាសនេះនៅមានភាពមិនច្បាស់លាស់។ ក្នុងករណីមួយចំនួន សាលាជម្រះក្តីនានាបានយកបញ្ញត្តិស្តីពីទ្រព្យរួម និង អាហារកិច្ចរវាងសហព័ទ្ធ ជាដើម យកមកអនុវត្តន៍នៅក្នុងរឿងអចិន្ត្រៃសង្វាស។ ស្ថានភាពនេះកំពុងបង្ហាញអំពីការរីករាលដាលនៃអសន្តិសុខគតិយុត្តនៅក្នុងឱតិត្រួសារកម្ពុជា ដែលវាអាចធ្វើឲ្យខូចខាតប្រយោជន៍ធ្ងន់ធ្ងររបស់ភាគីណាមួយនៃអចិន្ត្រៃសង្វាស។

ដូចនេះ ការសិក្សាអំពីការអនុវត្តជាក់ស្តែងនៅតាមសាលាជម្រះក្តីនានាវាជាកត្តាសារវន្តដើម្បីកំណត់ឲ្យបានអំពីកត្តានានានៃការមិនអាចញែកដាច់ពីគ្នាបានរវាង

www.elibraryofcambodia.org

Scanned with CamScanner

អពាហ៍ពិពាហ៍ និង អនីតិសង្វាស។ ការសិក្សានេះនឹងត្រូវយកទៅផ្ទុះបញ្ចាំងជាមួយ នឹងច្រឹស្តីនៃសញ្ញាណទាំងពីរ ដើម្បីអាចឲ្យយើងដឹងអំពីផ្នូរដើរច្បាស់លាស់របស់វា និង អាចឲ្យយើងកំណត់បានអំពីគម្លាតឃ្លោតឆ្ងាយឆ្ងាយរវាងការអនុវត្តនៅតាមសាលាជម្រះក្តីនានា និង ច្រឹស្តីរបស់វា។

ហេតុដូច្នេះ ការសិក្សាអំពី "*អនីតិសង្វាស*"មានសារៈសំខាន់ក្នុងការសង្កេតមើលតថភាពជាក់ស្តែងក្នុងសង្គមកម្ពុជា ឬ ការគាក់តែងច្បាប់ក្នុងវិស័យនេះ ដើម្បីធានាឲ្យបានឲ្យសន្តិសុខគតិយុត្តល្អមួយនៅក្នុងនីតិគ្រួសារខ្មែរ ពោលគឺ ជៀសវាងការកើតមានវិវាទច្បាប់ធ្ងន់ធ្ងរមួយនៅកម្ពុជា។

ចុងក្រោយ ខ្ញុំសង្ឃឹមថាសៀវភៅស្តីពី "*អនីតិសង្វាស*" នេះ នឹងចូលរួមចំណែកផ្តល់ពុទ្ធិពិតប្រាកដមួយអំពីលទ្ធិក្នុងវិស័យនីតិគ្រួសារកម្ពុជា ជាពិសេសគឺការលាតត្រដាងនូវបទពិសោធន៍នានានៅតាមសាលាជម្រះក្តី ដើម្បីការឯកពិសោធន៍សម្រាប់អ្នកវិជ្ជាជីវៈច្បាប់នានាផ្សេងទៀត៕

www.elibraryofcambodia.org

Scanned with CamScanner

សេចក្តីសង្ខេបខ្លឹមសារនៃសៀវភៅ

កាតព្វកិច្ចក្នុងទំនាក់ទំនងឯកជន វាមានប្រភពមកពីការសំរែងឆន្ទៈរបស់បុគ្គលឯកជនដែលជាឱមសាររបស់គោលការណ៍ស្ម័យភាពនៃបុគ្គលឯកជន ឬ គោលការណ៍ស្ម័យភាពនៃឆន្ទៈ។ ការសំរែងឆន្ទៈនេះមានប្រភេទ និង ប្រភពខុសៗគ្នាពីទីមួយ ជាលិខិតគតិយុត្ត ឬ សកម្មភាពគតិយុត្ត ដែលចែកចេញជាកិច្ចសន្យា (កិច្ចសន្យាឯកតោភាគី កិច្ចសន្យាពហុភាគី និង កិច្ចសន្យារួម) ឧបកិច្ចសន្យា (សេចក្តីចម្រើនឥតហេតុ ជាឱម) និង សកម្មភាពឯកតោភាគី ទីពីរជាព្រឹត្តិការណ៍គតិយុត្ត (អំពើអនីត្យានុកូល) និង ទីបី បទប្បញ្ញត្តិច្បាប់។

ជាគោលការណ៍ កាតព្វកិច្ចដែលមានប្រភពខុសគ្នាមិនបង្កើតអនុភាពគតិយុត្តដូចគ្នានោះទេ។ ជាក់ស្តែង អនីតិសង្វាសដែលជាចំណងគតិយុត្តកើតឡើងពីព្រឹត្តិការណ៍គតិយុត្ត ឬ អង្គហេតុ មិនបង្កើតអនុភាពគតិយុត្តដូចគ្នានឹងអាពាហ៍-ពិពាហ៍ដែលជាកិច្ចសន្យាឧឡារិកនោះទេ បើទោះបីជាស្ថានភាពជាក់ស្តែង មានការរស់នៅជាមួយគ្នាជាប្តីប្រពន្ធក៏ដោយ។ ក្នុងប្រភេទជាកិច្ចសន្យា ចំណងគតិយុត្តត្រូវគោរពឱ្យបានខ្វះលក្ខខណ្ឌមួយចំនួនដែលច្បាប់តម្រូវ បើពុំនោះទេត្រូវទទួលទណ្ឌកម្មដោយការលុបចោល ឬ មោឃភាព។ ផ្ទុយទៅវិញ បើជាព្រឹត្តិការណ៍គតិយុត្តតម្រូវឱ្យមានលក្ខខណ្ឌនៃការបង្កើតរបស់វាផងដែរ តែមិនមែនជាលក្ខខណ្ឌតឹងរ៉ឹងដូចគ្នាជាមួយកិច្ចសន្យានោះទេ តែអ្វីដែលចាំបាច់នោះគឺការសំរែងឆន្ទៈមានសុពលភាព និង

www.elibraryofcambodia.org

Scanned with CamScanner

ទាមទារឱ្យបុគ្គលដែលសំដែងនោះ ទទួលខុសត្រូវនូវកំហុសរបស់ខ្លួន (គោលការណ៍នៃការទទួលខុសត្រូវនូវកំហុសរបស់ខ្លួន)។

តាមពិតទៅ អនីតិសង្វាសបានកើតឡើងដោយសារការមិនគោរពនូវលក្ខ-ខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍ ជាក់ស្តែងកង្វះខាត ឬ ភាពទន់ខ្សោយនៃការងារអត្រានុកូលដ្ឋាន ការផ្សព្វផ្សាយច្បាប់ និង ការប្រើប្រាស់រយៈពេលអន្តរកាលយូរចំពោះការងារអត្រានុកូលដ្ឋាន។ ស្ថានភាពបែបនេះ ធ្វើឱ្យមានវិបាកផ្នែកគតិយុត្តមួយក្នុងប្រព័ន្ធច្បាប់គ្រួសារកម្ពុជា។ ការគិតថាអាពាហ៍ពិពាហ៍ឈរលើលក្ខខណ្ឌប្រពៃណីក៏បាន ឬ ឈរលើមូលដ្ឋានគតិយុត្តក៏បានដោះ គួរតែបញ្ឈប់ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៧ ដោយសារថា រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យ លេខ ៨៩ អនក្រ.បក ដើម្បីកែសម្រួលចំណុច ក និង ខ មាត្រា៥៩ ស្នូនថ្មី នៃអនុ លេខ១០៦ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៥ ដោយបានពន្យារពេលការចុះសំបុត្រអត្រានុកូលដ្ឋានដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៦។

អនីតិសង្វាសត្រូវគោរពនូវលក្ខខណ្ឌនៃការបង្កើតរបស់វាមួយច្បាស់លាស់ បើទោះបីវាជាសមត្ថសង្វាសដោយសេរី ឬ គ្មានបទដ្ឋានគតិយុត្តណាមួយកំណត់ច្បាស់លាស់ក៏ដោយ។ ការទាមទារលក្ខខណ្ឌជាកំលាក់ក្នុងការបង្កើតអនីតិសង្វាសវាមានអានុភាពគតិយុត្តរបស់វាមួយច្បាស់លាស់។

ទាញចេញពីលក្ខខណ្ឌដែលទាមទារខាងលើ ជាគោលការណ៍ អនីតិសង្វាសមានរបបគតិយុត្តរបស់វាច្បាស់លាស់មួយ និង មិនដូចគ្នាជាមួយអានុភាពគតិយុត្ត

www.elibraryofcambodia.org
Scanned with CamScanner

របស់អាពាហ៍ពិពាហ៍បរហោះទេ។ ការយកបទប្បញ្ញត្តិស្តីពីអាពាហ៍ពិពាហ៍មកអនុវត្តក្នុងរឿងអនីតិសង្វាសដោយមិនបានសិក្សាអំពីផលវិបាកគតិយុត្ត វាបានបំពានទៅនឹងគោលការណ៍ទូទៅនៃការបែងចែកប្រភពនៃកាតព្វកិច្ច។ តែក្នុងស្ថានភាពមួយចំនួន ដើម្បីធានានូវការផ្តល់យុត្តិធម៌ដល់គូភាគីជាអនីតិសង្វាសជន ចៅក្រមចាំបាច់ត្រូវវិនិច្ឆ័យសេចក្តីដោយឈរលើមូលដ្ឋាននៃបញ្ញត្តិនៃអាពាហ៍ពិពាហ៍។ នេះជាគោលការណ៍នៃការមិនរើសអើង ឬ គោលការណ៍ស្មើភាព ដែលស្ថានភាពពីរស្រដៀងគ្នាអាចមានរបបគតិយុត្តដូចគ្នា។ ក៏ប៉ុន្តែ ការយករបបគតិយុត្តនៃសញ្ញាណគតិយុត្តណាមួយទៅអនុវត្តនៅក្នុងសញ្ញាណគតិយុត្តណាមួយទៀតនោះ មិនអាចប្រាស់ចាកពីគោលការណ៍ទូទៅដែលបែងចែងប្រភពនៃកាតព្វកិច្ចឲ្យដាច់ពីគ្នានោះទេ។ ជាក់ស្តែងអនីតិសង្វាសមិនបានផ្តល់នូវអភ័យឯកសិទ្ធិគ្រួសារ ឬសិទ្ធិពិសេសមួយចំនួនដល់អនីតិសង្វាសជននោះទេ។ ម្យ៉ាងទៀត អនីតិសង្វាសមិនបង្កើតឲ្យមានប្រព័ន្ធទ្រព្យសម្បត្តិរួមប្តីប្រពន្ធដូចគ្នានឹងអាពាហ៍ពិពាហ៍នោះទេ។ វិធីបកស្រាយបែបសទិសវិធី ឬ តាមវិធីប្រដូចនេះ ត្រូវប្រើដោយប្រយ័ត្នប្រយែងបំផុតក្នុងរឿងព្រហ្មទណ្ឌ ដើម្បីធានាបាននូវការគោរពជាអាទិ៍ គោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោស និង គោលការណ៍បកស្រាយច្បាប់ចង្អៀត។ ជាងនេះទៅទៀត ការអនុវត្តតាមវិធីបកស្រាយបែបនេះតម្រូវឲ្យមានការបែងចែក និង ស្គាល់ឲ្យបានច្បាស់លាស់នៃអនុភាពរបស់អនីតិសង្វាសនៅក្នុងអំឡុងពេលអត្ថិភាពរបស់វា និង ក្រោយការ

www.elibraryofcambodia.org
Scanned with CamScanner

រលាយនៃចំណងនេះ ព្រមទាំងពិនិត្យមើលដោយប្រយ័ត្នប្រយែងទៅលើទិដ្ឋភាពគតិយុត្តផ្សេងៗទៀតដែលនៅជុំវិញវា។

តែទោះជាយ៉ាងណាក៏ដោយ ក៏អនីតិសង្វាសមានរបបគតិយុត្តមួយផ្ទាល់របស់វា ដោយគ្រាន់តែថាផ្នែកខ្លះនៃអនុភាពគតិយុត្តរបស់អនីតិសង្វាសមានភាពដូចគ្នានឹងអនុភាពគតិយុត្តនៃអាពាហ៍ពិពាហ៍តែប៉ុណ្ណោះ៕

www.elibraryofcambodia.org

Scanned with CamScanner

មាតិកា

សេចក្តីផ្តើម ១

ជំពូកទី ១- អត្ថិភាពនៃអនីតិសង្ខារ ៦

ផ្នែកទី ១- មូលហេតុចំបង៖ បញ្ហាលក្ខណៈទម្រង់នៃអាពាហ៍ពិពាហ៍ ៦

កថាខណ្ឌទី ១- កង្វះបទដ្ឋានអនុវត្តន៍ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ... ៧

១- ការមិនគោរពលក្ខណៈឯកភាពនៃអាពាហ៍ពិពាហ៍ ៧

២- និយ័តកម្មចំពោះអាពាហ៍ពិពាហ៍ដែលមិនបានចុះបញ្ជី ៨

កថាខណ្ឌទី ២- រយៈពេលអន្តរកាល ១៣

ផ្នែកទី ២- លក្ខណៈសារធាតុនៃការបង្កើតអនីតិសង្ខារ ១៦

កថាខណ្ឌទី ១- សមត្ថសង្ខារតាមព្រឹត្តិន័យ ១៧

កថាខណ្ឌទី ២- លក្ខណៈនៃការរស់នៅរួមគ្នា ១៨

www.elibraryofcambodia.org

Scanned with CamScanner

កថាខណ្ឌទី ៣- លក្ខណៈនៃស្មេរភាព និង ឱរត្តភាព ១៩

កថាខណ្ឌទី ៤- រវាងបុគ្គលពីរនាក់៖ អាចខុសគ្នា ឬ ដូចគ្នា? ២១

កថាខណ្ឌទី ៥- ការរស់នៅដូចប្តីប្រពន្ធ ២៣

កថាខណ្ឌទី ៦- ការរួមបាយ រួមទឹក រួមដំណេក ២៤

កថាខណ្ឌទី ៧- ភស្តុតាងដើម្បីគាំទ្រលក្ខណសារធាតុនៃអនីតិសង្វាស ២៥

ជំពូកទី ២- អានុភាពក្នុងអំឡុងពេលអត្ថិភាពនៃអនីតិសង្វាស ៣០

ផ្នែកទី ១- អានុភាពផ្នែកបុគ្គល (ក្រៅបេតិកភណ្ឌ) ៣០

កថាខណ្ឌទី ១- រវាងអនីតិសង្វាសជន ៣០

ចំណុចទី ១- ផ្នែករដ្ឋប្បវេណី ៣១

១- បង្កើតចំណងញាតិ? ៣១

២- កាតព្វកិច្ចដែលកើតចេញពីអាពាហ៍ពិពាហ៍ ៣២

៣- ការទទួលបានអត្តាធិនភាព ៣៦

www.elibraryofcambodia.org

Scanned with CamScanner

ចំណុចទី ២- ផ្នែកព្រហ្មទណ្ឌ ៣៤

១- អភ័យឯកសិទ្ធិត្រួសារក្នុងរឿងព្រហ្មទណ្ឌ (អំពើលួច) ៣៨

២- បទល្មើសមានចែងក្នុងច្បាប់ស្តីពីឯកពន្ធភាព ៤០

៣- បទល្មើសផ្សេងទៀត ៤៤

កថាខណ្ឌទី ២- ចំពោះកូន ៤៤

ចំណុចទី ១- អំណាចមេបា៖ ទោល ឬ សហការ? ៤៤

ចំណុចទី ២- បុត្តភាព ៤៨

ផ្នែកទី ២- អាទិភាពផ្នែកទ្រព្យសម្បត្តិ (ផ្នែកបេតិកភណ្ឌ) ៥

កថាខណ្ឌទី ១- របបមាតិកភណ្ឌ? ៥៨

កថាខណ្ឌទី ២- អាហារគាតព្វកិច្ច ឬ អាហារកិច្ច ៥៤

កថាខណ្ឌទី ៣- លំនៅដ្ឋានរបស់អចិន្ត្រៃសង្ហាសជន ៥៨

ជំពូកទី ៣- អាទិភាពក្រោយការរលាយរំងៃអចិន្ត្រៃសង្ហាស ៦០

www.elibraryofcambodia.org

Scanned with CamScanner

ផ្នែកទី ១- ការរលាយ ៦០

កថាខណ្ឌទី ១- មូលហេតុនៃការរលាយ៖ ដូចគ្នាឬឯករាជាហ៍ពិពាហ៍? ៦០

កថាខណ្ឌទី ២- ឱតិវិធី ៦២

ចំណុចទី ១- បណ្តឹង ៦២

ចំណុចទី ២- ការពិនិត្យពាក្យបណ្តឹង ឬពាក្យសុំ ៦៤

ចំណុចទី ៣- ដំណើរការនៃឱតិវិធី៖ ច្បាប់ឱតិវិធីដែលត្រូវយកមកអនុវត្តន៍?..... ៦៦

ចំណុចទី ៤- ការវិនិច្ឆ័យសេចក្តី ៦៨

ផ្នែកទី ២- អានុភាពក្រោយការរលាយ ៧១

កថាខណ្ឌទី ១- អានុភាពផ្នែកបុគ្គល (ក្រៅបេតិកភណ្ឌ)..... ៧១

ចំណុចទី ១- រវាងអតីតសង្វាសជន ៧១

ចំណុចទី ២- ចំពោះកូន ៧៥

១- អ្នកមានអំណាចមេបា?..... ៧៦

www.elibraryofcambodia.org

Scanned with CamScanner

២- សិទ្ធិ និង ករណីយកិច្ចរបស់ឪពុកម្តាយដែលមិនរស់ជាមួយកូន ៧៧

កថាខណ្ឌទី ២- អនុភាពផ្នែកទ្រព្យសម្បត្តិ (ផ្នែកបេតិកភណ្ឌ) ៧៨

ចំណុចទី ១- ការជម្រះបញ្ជី..... ៧៨

១- កម្មសិទ្ធិរវិភាគ ៧៨

២- ក្រុមហ៊ុនកើតឡើងតាមរង្គហេតុ ៧៩

៣- សេចក្តីចម្រើនឥតហេតុ ៨១

ចំណុចទី ២- ការទាមទារសំណងនៃការខូចខាតករណីដែលអនីតិសង្វាសជនណា
ម្នាក់បានស្លាប់ដោយអំពើខុសច្បាប់ ករណីសាលាក្តីខ្ពែរក្រហមជាឃុត្តិសាស្ត្រ?
..... ៨៣

ចំណុចទី ៣- ការផ្ទេរទ្រព្យសម្បត្តិរវាងអនីតិសង្វាសជន សទ្ធាទាន ៨៨

សេចក្តីសន្និដ្ឋាន..... ៩១

ឧបសម្ព័ន្ធ ៩៨

www.elibraryofcambodia.org

Scanned with CamScanner

ឧបសម្ព័ន្ធទី១ ..... ៩៩

ឧបសម្ព័ន្ធទី២ ..... ១១៦

ឧបសម្ព័ន្ធទី៣ ..... ១៣៦

ឧបសម្ព័ន្ធទី៤ ..... ១៣៩

ឯកសារយោង ១៤៣

ការសិក្សារបស់អ្នកនិពន្ធ ១៥០

www.elibraryofcambodia.org

Scanned with CamScanner

អនីតិសង្វាស

សេចក្តីផ្តើម

ក្នុងសង្គមកម្ពុជា ប្រពៃណី ទំនៀមទំលាប់ និងសាសនា គឺជាគ្រឹះមុខនៃមនុស្សគ្រប់រូប។ ក្នុងនោះដែរ អាពាហ៍ពិពាហ៍រវាងជនប្រុស-ស្រី តែងតែត្រូវបានប្រារព្ធឡើងតាម សាសនា ប្រពៃណី និងទំនៀមទំលាប់តាំងពីបុរាណ។

ការស្ថិតក្រោមអាណាព្យាបាលចាវ៉ាង ចាវ៉ាងបាននាំមកដល់កម្ពុជានូវច្បាប់ទំនើប ហើយវាបានកែប្រែកម្ពុជាឲ្យស្គាល់សម័យកាលទំនើបមួយ។ ក្រោយពីទទួលបានឯករាជ្យពីសាធារណរដ្ឋចាវ៉ាងនៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ មក កម្ពុជានៅតែប្រកាន់យកក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ សម្រាប់គ្រប់គ្រងទំនាក់ទំនងឯកជនរៀងជនខ្មែរគ្រប់រូបរហូតដល់ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ជាពេលដែលវិស័យច្បាប់នៅកម្ពុជាលែងមានអត្ថិភាព។

របបកម្ពុជាប្រជាធិបតេយ្យរបស់ខ្មែរក្រហមបានបន្សល់ទុកឲ្យប្រជាជនកម្ពុជាគ្រប់រូបនូវមហាវិនាសកម្ម ជាពិសេសការយល់ដឹងរបស់គណៈរដ្ឋអំពីច្បាប់ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ពិតណាស់ ក្រោយពីរបបនេះត្រូវបានរំលំរណៈទៅនៅឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាគ្រប់រូបនៅតែប្រកាន់ខ្ជាប់នូវប្រពៃណី និងទំនៀម

www.elibraryofcambodia.org
Scanned with CamScanner

ចំណាប់ទាក់ទងនឹងអាពាហ៍ពិពាហ៍បានល្អ តែផ្ទុយទៅវិញការយល់ដឹងរបស់ពលរដ្ឋ ភាគច្រើនអំពីទិដ្ឋភាពគតិយុត្តនៃអាពាហ៍ពិពាហ៍ត្រូវបានលិចបាត់ បើទោះបីជាមានច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩ ដែលកំណត់អំពីនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ក៏ដោយ។ តែច្បាប់នេះមិនអាចអនុវត្តបាន ឬមិនត្រូវបានគេអនុវត្ត ដោយសារថាការចុះសំបុត្រអាពាហ៍ពិពាហ៍មើបតែចាប់បដិសន្ធិឡើងនៅកម្ពុជាចាប់ពីឆ្នាំ២០០០។ ដូចនេះ ថាតើការចុះសំបុត្រអាពាហ៍ពិពាហ៍ជាធាតុសារវន្តដើម្បីកំណត់របបគតិយុត្តនៃចំណងអាពាហ៍ពិពាហ៍ដែលមានចែងក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩ មែនឬទេ។ ស្ថានភាពនេះបានធ្វើឲ្យមានការច្រឡំគ្នារវាងនីតិ និងបដិនីតិ (le droit et l'anti-droit) ពោលគឺអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ និងអនីតិសង្វាស។ មាត្រា ៣ កថាខណ្ឌទី១នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ និងមាត្រា ៣ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃច្បាប់ស្តីពីឯកពន្ធភាពឆ្នាំ២០០៦ បានផ្តល់និយមន័យ **អាពាហ៍ពិពាហ៍** ច្បាស់លាស់ដោយកំណត់ថា "*គឺជាកិច្ចសន្យារវាងបុរសម្នាក់ និងស្ត្រីម្នាក់ដែលប្តេជ្ញាថា នឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចលុបចោលតាមទំនើងចិត្តរបស់ខ្លួន*"[1] ។ ចំណែកឯ និយមន័យនៃពាក្យ **អនីតិ**

[1] មាត្រា ៣ កថាខណ្ឌទី១ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ លេខ ៤៦ ក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩ និងមាត្រា ៣ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃ ច្បាប់ស្តីពីឯកពន្ធភាព លេខ នស/រកម/ ១០០៦/០២៦ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦,មាត្រា ៣ កថាខណ្ឌទី១ វាក្យខណ្ឌទី២ ។

www.elibraryofcambodia.org
Scanned with CamScanner

សង្វាស ត្រូវបានច្បាប់កម្ពុជាផ្តល់និយមន័យនោះទេ តែត្រូវបានគេព្យាយាមផ្តល់និយមន័យថា "*គឺជាស្ថានភាពរបស់បុរស និង នារីដែលរួមរស់នៅជាមួយគ្នាមួយភ្លែត ប្រពន្ធមានខាន់ស្លា ប៉ុន្តែឥតមានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ*"[2]។

ហើយម្យ៉ាងទៀត កម្ពុជាទើបតែស្គាល់នូវសន្តិភាពពេញលេញ តាមរយៈការធ្វើសមាហរណកម្មន្លែរក្រហមដែលសេសសល់ហើយដែលពួកគេភាគច្រើនគឺបានរៀបអាពាហ៍ពិពាហ៍តែតាមផ្នូវប្រពៃណី ទំនៀមទំលាប់ និងសាសនា ជាពិសេសការរៀបការដោយបង្ខំនៅក្នុងរបបន្លែរក្រហម ដោយមិនមានការចុះបញ្ជីអត្រានុកូលដ្ឋានត្រឹមត្រូវអ្វីនោះទេ។

ស្ថានភាពបែបនេះបានធ្វើឱ្យកំពុងជះឥទ្ធិពលយ៉ាងខ្លាំងដល់សង្គមកម្ពុជា ដោយសារថា អ្នកដែលបានរៀបអាពាហ៍ពិពាហ៍នៅមុនពេលការងារអត្រានុកូលដ្ឋានចាប់ផ្តើមនៅឆ្នាំ២០០០ នោះ តែងតែមកតុលាការដោយការដាក់ពាក្យបណ្តឹងសុំលែងលះគ្នា ព្រោះគាត់គិតថាគាត់បានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវ។ ការណ៍នេះផ្តល់ឱ្យតុលាការដែលជាអ្នកអនុវត្តច្បាប់ដែលទើបប្រកាសឱ្យប្រើថ្មី គួយ៉ាងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ (ច្បាប់មានតម្លៃគតិយុត្តខ្ពស់ជាងទំនៀមទំលាប់) ប្រឈមមុខនឹងវិវាទរវាងប្រពៃណី និងច្បាប់។ អានន័យថា នៅក្នុងប្រព័ន្ធច្បាប់ត្រួសារកម្ពុជាមានវិវាទ

2 សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច, *សព្វានុក្រមជាអាំង-ង្លេសនៃពាក្យច្បាប់*, (ភ្នំពេញ៖ ហ្វូណាន ២០០៥),ទំព័រទី៧៩ ។

www.elibraryofcambodia.org
Scanned with CamScanner

បទដ្ឋានគតិយុត្តមួយយ៉ាងធ្ងន់ ដោយមិនអាចបែងចែកឱ្យដាច់ស្រឡះរវាងសញ្ញាណនៃអាពាហ៍ពិពាហ៍ និងអនីតិសង្វាស ។

ភាគច្រើន តុលាការទទួលស្គាល់អត្ថិភាពនៃអនីតិសង្វាសដោយពិនិត្យមើលតែទៅលើនត្ថិភាពនៃសំបុត្រអាពាហ៍ពិពាហ៍ ដោយមិនបានពិនិត្យមើលទៅលើលក្ខខណ្ឌផ្សេងទៀត។ មានន័យថា សញ្ញាណគតិយុត្តមួយមានអត្ថិភាព លុះត្រាតែលក្ខខណ្ឌសារធាតុរបស់វាត្រូវបានបំពេញត្រឹមត្រូវ។ ហើយ អនីតិសង្វាសមិនអាចបង្កើតអនុភាពដូចគ្នាទៅនឹងអ្វីដែលអាពាហ៍ពិពាហ៍មានដោះទេ។ ក៏ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែងនៅតាមសាលាជម្រះក្តី ហាក់ដូចជាមិនអាចបែងចែកអនុភាពគតិយុត្តនៃអនីតិសង្វាសឱ្យដាច់ពីអាពាហ៍ពិពាហ៍ដោះទេ (បញ្ហាអំណាចរមបាអាហារភាគព្វកិច្ច ទ្រព្យសម្បត្តិរួម ជាដើម) បើទោះបីជាតុលាការលើកចោលបណ្តឹងផ្តាច់អនីតិសង្វាសរបស់ដើមចោទក៏ដោយ ដោយយល់ថាវាជាបណ្តឹងផ្តុយនឹងច្បាប់ (យោងតាមមាត្រា៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ការច្រានចោលបណ្តឹងនេះតុលាការមិនបានបង្ហាញទឡ្ហីករណ៍គតិយុត្តណាមួយច្បាស់លាស់ដោះទេ ដោយគ្រាន់តែសំអាងថា វាជាបណ្តឹងដែលផ្តុយនឹងច្បាប់ដូចមានចែងក្នុងមាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី (*ក្នុងករណីដែលបណ្តឹងមានលក្ខណៈផ្តុយនឹងច្បាប់ ហើយចំណុចខ្វះខាតនោះមិនអាចកែតម្រូវបានទេ តុលាការលើកបណ្តឹងនោះចោលដោយសាលក្រម ដោយមិនឆ្លងកាត់ការទាញរហូតដល់ផ្តាល់មាត់*)។ ការណ៍នេះ

www.elibraryofcambodia.org
Scanned with CamScanner

តុលាការកំពុងតែទទួលស្គាល់ថា អនីតិសង្វាសមានអត្ថភាពគតិយុត្តដូចគ្នាជាមួយនឹងអាពាហ៍ពិពាហ៍។ តុលាការបានទ្រានចោលបណ្តឹងផ្តាច់អនីតិសង្វាស តែបែរជាមានសមត្ថកិច្ចជម្រះចំណងនេះ ក្រោយពីគិតថាចំណងនេះផ្ទុយទៅនឹងច្បាប់។

ដូចនេះយើងនឹងព្យាយាមស្វែងរក និង វែកញែកឲ្យឃើញច្បាស់លាស់អំពីថាតើអនីតិសង្វាសមានអត្ថិភាពដូចម្តេច (**ជំពូកទី១**) របបគតិយុត្តក្នុងអំឡុងពេលអត្ថិភាពនៃអនីតិសង្វាស (**ជំពូកទី២**) និង របបគតិយុត្តក្រោយការរលាយនៃអនីតិសង្វាស (**ជំពូកទី៣**) ដើម្បីជាប្រយោជន៍នៃស្ថេរភាពគតិយុត្តនៅក្នុងនីតិគ្រួសារកម្ពុជា។

www.elibraryofcambodia.org
Scanned with CamScanner

ជំពូកទី ១- អត្ថភាពនៃអនីតិសង្វាស

ជាទូទៅ ក្នុងការអនុវត្តនៅតាមសាលាជម្រះក្តី ជាពិសេសនៅពេលដែលមានបណ្តឹងទាមទារសុំផ្តាច់អនីតិសង្វាស តុលាការតែងតែគិតថាចំណងអាពាហ៍-ពិពាហ៍ដែលមិនមានចុះសំបុត្រអាពាហ៍ពិពាហ៍ គឺជាអនីតិសង្វាស ហើយពេលខ្លះទៀតនោះ គូភាគីបានឆ្លើយសារភាពថាពួកគេពិតជាបានរស់នៅជាប្តីប្រពន្ធតាមបែបអនីតិសង្វាសពិតប្រាកដមែន។ ក៏ប៉ុន្តែ ការណ៍នេះមិនគ្រប់គ្រាន់សម្រាប់បញ្ជាក់អំពីអត្ថិភាពនៃអនីតិសង្វាសនោះទេ។ លក្ខណៈសារធាតុ ឬលក្ខណៈព្រឹត្តិការណ៍ដែលក្លាយជាលក្ខណៈចាំបាច់ទាមទារឱ្យមានការត្រួតពិនិត្យពីតុលាការផងដែរ។ ប្អូនអាចនិយាយម្យ៉ាងទៀតបានថា តុលាការមិនបានធ្វើការនីតិវិធីផ្សេងផ្តាត់លើភស្តុតាងដែលកើតចេញពីការសារភាពថាពិតប្រាកដដូចការរិះគន់របស់ពួកគេមែនដែរទេ។

ផ្នែកទី១- មូលហេតុចំបង បញ្ហាលក្ខខណ្ឌតម្រង់នៃអាពាហ៍ពិពាហ៍

ជាច្រើនស្តី អាពាហ៍ពិពាហ៍ដែលមិនត្រូវបានគោរពតាមបញ្ញត្តិនៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ (មាត្រា១១, មាត្រា១២, មាត្រា១៣, និងមាត្រា១៤) និងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ (ចាប់ពីមាត្រា៩៤៨ ដល់មាត្រា៩៥៧) នឹងមិនត្រូវបានចាត់ទុកថាជាអាពាហ៍ពិពាហ៍ស្របច្បាប់នោះទេ។ ក៏ប៉ុន្តែ ការមិន

www.elibraryofcambodia.org
Scanned with CamScanner

ប្រការខ្លាំងនូវបញ្ហាត្តិខាងលើនេះ មិនអ្នែនទាំងស្រុងចំណែងនោះក្លាយទៅជាអនីតិសង្វាស ជាស្ថិយប្រវត្តិនោះទេ។

អថាខណ្ឌទី ១. អន្ទះបន្ទានអនុវត្តន៍ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ

ចំណុចទី ១. ការមិនគោរពលក្ខខណ្ឌនៃអាពាហ៍ពិពាហ៍

មាត្រា ៣ អថាខណ្ឌទី១ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ និងមាត្រា ៣ អថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃច្បាប់ស្តីពីឯកភាពភាពឆ្នាំ២០០៦ បានឱ្យនិយមន័យនៃអាពាហ៍ពិពាហ៍ដោយបញ្ជាត្តិដូចគ្នាថា "*អាពាហ៍ពិពាហ៍គឺជាកិច្ចសន្យាអនាវិកមួយ ធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ដែលយល់ព្រមថា ខ្លួនមានសមត្ថសង្វាសជាមួយគ្នាតាមបញ្ជត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញតាមទំនើងចិត្តរបស់ខ្លួន*"។ អថាខណ្ឌទី២ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ សំដែងថា "*អាពាហ៍ពិពាហ៍នឹងមានអានុភាពពេញលក្ខណៈច្បាប់បាន លុះត្រាតែអាពាហ៍ពិពាហ៍នោះធ្វើឡើង ស្របតាមក្បួនខ្នាតដែលក្នុងច្បាប់នេះ*"។

ដោយសារថាជាកិច្ចសន្យាអនាវិកមួយ ដូចនេះការប្តឹងដល់មន្ត្រីអត្រាធុកូលដ្ឋានអំពីការរៀបអាពាហ៍ពិពាហ៍ ការប្រកាសជាសាធារណៈ ១០ថ្ងៃ មុនថ្ងៃរៀបអាពាហ៍ពិពាហ៍ ការចុះសំបុត្រអាពាហ៍ពិពាហ៍ក្រោមទម្រង់ជាលិខិតយថាភូត

www.elibraryofcambodia.org
Scanned with CamScanner

និងការចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានរវាងប្តី-ប្រពន្ធ និងសាក្សីគ្រប់អាយុចំនួនពីរនាក់ គឺជាលក្ខខណ្ឌចាំបាច់[3] ដែលត្រូវបំពេញដែលខុសអំពីកិច្ចសន្យាដែលកើតឡើងដោយការព្រមព្រៀងឱ្យមក ដែលវាមានអានុភាពតាលណាមានតែការព្រមព្រៀងរវាងគូភាគីប៉ុណ្ណោះ ជាការគ្រប់គ្រងតាមទិដ្ឋភាពច្បាប់។ ការងារអត្រានុកូលដ្ឋានទើបតែត្រូវបានកើតឡើងនៅពេលដែលមានអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន លេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ត្រូវបានប្រកាសឱ្យប្រើ។

ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩ ជាអ្នកកសាងឡើងវិញនូវចំណងផ្នែកស៊ីវិលរបស់បុគ្គល ដោយបានបង្កឱ្យមានបញ្ហាគតិយុត្តជាច្រើន ដោយសារថាការងារអត្រានុកូលដ្ឋានដែលច្បាប់តម្រូវមិនទាន់បានកើតឡើង។ ដូចនេះវាទាមទារឱ្យមានការធ្វើនីយ័តកម្មនៃអាពាហ៍ពិពាហ៍ដែលមិនបានចុះបញ្ជី។

ចំណុចទី ២- នីយ័តកម្មចំពោះអាពាហ៍ពិពាហ៍ដែលមិនបានចុះបញ្ជី

រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន ដែលមានគោលដៅចំបងកំណត់បែបបទ និងនីតិវិធី

3 ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ លេខ៨៦ ក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩, មាត្រា ១១ មាត្រា១២ មាត្រា១៣ និង មាត្រា១៤។

www.elibraryofcambodia.org
Scanned with CamScanner

នៃការងារអត្រានុកូលដ្ឋានៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អត្រានុកូលដ្ឋានគឺជាចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និងស្ថានភាពជាក់ស្តែងដែលជនោះមាននៅក្នុងក្រកូលគ្រួសារខ្លួន ក្នុងសង្គមជាតិ និងដែលបង្កឱ្យជនោះមានសិទ្ធិ និងករណីយកិច្ច។ ហើយ សំបុត្រអត្រានុកូលដ្ឋានរួមមាន សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រមរណភាព។ នេះជានិយមន័យផ្តល់ដោយមាត្រា២ នៃអនុក្រឹត្យដែល។ មាត្រា៣ នៃអនុក្រឹត្យនេះកំណត់ថា *"ការសុំចុះអត្រានុកូលដ្ឋានក្នុងសៀវភៅអត្រានុកូលដ្ឋានជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋម្នែរគ្រប់រូប"*។ ម្យ៉ាងទៀត វាជាកាតព្វកិច្ចធីត្បានុកូលដែលពលរដ្ឋត្រូវតែប្រតិបត្តិតាម[4] ។

មាត្រា៤៥ នៃអនុក្រឹត្យនេះ បញ្ញត្តិថា *"ពលរដ្ឋម្នែរដែលបានគ្នាជាប្តី ឬប្រពន្ធពិតប្រាកដមុនពេលមានអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាននេះចូលជាធរមាន ហើយគ្មានសំបុត្រអាពាហ៍ពិពាហ៍ប្រើប្រាស់ សាមីខ្លួនប្តី ប្រពន្ធអាចមកសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍បាន តាមគំរូណែនាំថ្មីនៅសាលាឃុំ ឬសង្កាត់ ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីពីរូបជាមិត្តជន និងជាមនុស្សគួរទុកចិត្តបាន ដែលបានដឹងឮផ្ទាល់ពីសាមីខ្លួនប្តី ប្រពន្ធនោះ និងធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬ

4 ឈាក ឥល ណុន ប្រធានសាលាដំបូងមត្តាចាត់ដំបង និង ឈាកសាស្ត្រាចារ្យ ហែល ចំរើន, កាលវិសេសប្បវត្តិ *Annale* (សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០០៦), *បញ្ហាលក្ខណៈច្បាស់លាស់នៃអាពាហ៍ពិពាហ៍*, ទំព័រ ៤៩ ចំណុច ខ (*អធិត្បានុកូលភាពនៃការបញ្ជាក់អាពាហ៍ពិពាហ៍តាមសាក្សី*)។

www.elibraryofcambodia.org
Scanned with CamScanner

សង្កាត់ជាមួយគ្នា ទៅមកបញ្ជាក់នៅចំណោះមុខមន្ត្រីអត្រានុកូលដ្ឋាន"។ មាត្រា៥៩ នៃអនុក្រឹត្យលេខ១០៣ នេះ បានចែងថា "*ការសុំបញ្ជាក់អត្រានុកូលដ្ឋាន រួមមានចុះសំបុត្របញ្ជាក់កំណើត សៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ សៀវភៅមរណភាព ត្រូវបានអនុវត្តចំពោះតែលើពលរដ្ឋខ្មែរ ហើយអនុវត្តតែក្នុងរយៈពេល៣ ឆ្នាំ ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន*" ពោលគឺចាប់ពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០។ ប៉ុន្តែបញ្ញត្តិនេះត្រូវបានកែសម្រួលដោយអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការកែសម្រួលមាត្រា ៨ និង មាត្រា ៥៩ នៃអនុក្រឹត្យលេខ ១០៣ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន។ តាមរយៈអនុក្រឹត្យលេខ ៦០ នេះ ការសុំបញ្ជាក់អត្រានុកូលដ្ឋានដែលមានសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ជាដើម ត្រូវបានពន្យារហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥ ទើបឈប់ ហើយចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៥ តទៅ ការបញ្ជាក់អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍អនុញ្ញាតឲ្យប្តឹងសុំតាមការស្ម័គ្រចិត្តនៃសហព័ទ្ធ[5]។

តែបន្ទាប់មក នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៤ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ១៧ អនក្រ.បក ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន

---

5 ណោក និល ណុត ប្រធានសាលាដំបូងរងខេត្តបាត់ដំបង និង ឯកោសាស្ត្រាចារ្យ រ៉ៃហ៊ែល ចំរើន, ការសិក្សាប្រៀបធៀប *Annale* (សាកលវិទ្យាល័យភូមិន្ទច្បាប់និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ឆ្នាំ២០០៦), *បញ្ហាលក្ខខណ្ឌទម្រង់ដើមអាពាហ៍ពិពាហ៍*, ទំព័រ៥៩ តំណុច ខ *(អត្ថិភាពនៃភាពដើមការបញ្ជាក់អាពាហ៍ពិពាហ៍តាមសាក្សី)*។

www.elibraryofcambodia.org
Scanned with CamScanner

ដោយមានកែសម្រួលមាត្រា ៥៩ថ្មីនៃអនុក្រឹត្យលេខ ៦០។ អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៤ ត្រង់មាត្រា៥៩ ថ្មីស្នួន ចំណុច ក មានសេចក្តីថា "*ការសុំចុះអត្រានុកូលដ្ឋាន ចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់ កំណើត សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍ សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព ត្រូវបានអនុវត្តតែលើពលរដ្ឋខ្មែរ **ចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥***"។

ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៥ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ១០៦ អនក្រ.បក ស្តីពីការកែសម្រួលចំណុច ក និងចំណុច ខ នៃមាត្រា៥៩ ថ្មីស្នួននៃអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៤ ដោយមានសេចក្តីថា"*ការសុំចុះអត្រានុកូលដ្ឋាន ចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍ សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព ត្រូវបានអនុវត្តតែលើពលរដ្ឋខ្មែរ **ចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ រហូតដល់ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០០៦*** "។ ផុតរយៈពេលនេះ អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ អនុញ្ញាតឲ្យប្តឹងសុំចុះតាមការស្នើត្រចិត្ត។

ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៦ រាជរដ្ឋាភិបាលបានបន្តចេញអនុក្រឹត្យមួយទៀតលេខ ៨៩ អនក្រ.បក ស្តីពីការកែសម្រួលចំណុច ក និង ចំណុច ខ មាត្រា៥៩ ថ្មីស្នួននៃអនុក្រឹត្យលេខ ១០៦ អនក្រ.បក ស្តីពីការកែសម្រួលចំណុច ក និងចំណុច ខ

www.elibraryofcambodia.org
Scanned with CamScanner

មាត្រា៥៩ ថ្មីស្នង។ មាត្រា ៥៩ ថ្មីស្នង នៃអនុក្រឹត្យលេខ ៨៩ អនក្រ.បក កំណត់ថា "*ការសុំចុះអត្រានុកូលដ្ឋាន ចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍ សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព ត្រូវបានអនុវត្តន៍តែលើពលរដ្ឋខ្មែរ **ចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៦***" ។ ជុតរយៈពេលនេះ ចំពោះអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ អនុញ្ញាតឲ្យប្តឹងសុំចុះតាមការស្ម័គ្រចិត្ត។

អនុក្រឹត្យទាំងប្រាំខាងលើនេះ ទទួលស្គាល់អាពាហ៍ពិពាហ៍ដែលគ្មានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ដោយបានបំពានទាំងស្រុងទៅលើមាត្រា៣ និង មាត្រា១៤ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដែលកំណត់ថាអាពាហ៍ពិពាហ៍គឺជាកិច្ចសន្យាឱឡារិក និងមានការចុះបញ្ជីអាពាហ៍ពិពាហ៍។ បំពានដោយសារថា មិនបានគោរពទៅតាមឋានានុក្រមនៃនីតិដែលច្បាប់ត្រូវស្ថិតនៅខ្ពស់ជាងបទបញ្ជារបស់រាជរដ្ឋាភិបាល (ពីវ៉ាមីតនៃបទដ្ឋានគតិយុត្តរបស់ណោក Hans Kelsen)។

ប៉ុន្តែ ស្ថានភាពជាក់ស្តែងនឹងបញ្ជាក់ថាវិវាទបទបញ្ជា និងច្បាប់ខាងលើនេះ មានប្រភពកើតចេញពីការលំបាកក្នុងការអនុវត្តជាក់ស្តែងដែលតម្រូវឲ្យទៅក្រមអនុវត្តអនុក្រឹត្យ ឬជៀសវាងមិនអនុវត្តច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ត្រង់លក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍។ ផ្ទុយទៅវិញ សំណួរចោទឡើងថាតើរយៈពេល

www.elibraryofcambodia.org
Scanned with CamScanner

អន្តរកាលនៃលក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍ នឹងត្រូវបញ្ចប់នៅពេលណាឱ្យច្បាស់លាស់។

អថាខណ្ឌទី ២- រយៈពេលអន្តរកាល

បើយើងពិនិត្យទៅលើការអនុវត្តនៅសាលាដំបូងខេត្តបាត់ដំបង ចៅក្រមប្រកាសទទួលស្គាល់អាពាហ៍ពិពាហ៍ក្រៅច្បាប់ជាអាពាហ៍ពិពាហ៍ស៊ីវិលត្រឹមថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០០៥ តែប៉ុណ្ណោះ អនុលោមតាមអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០២។ មានន័យថា អាពាហ៍ពិពាហ៍ដែលធ្វើចាប់ពីថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០០៥ ដែលមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ គឺជាអនីតិសង្វាស យោងទៅតាមគោលការណ៍សច្ចធារណ៍តាមផ្លូវតុលាការ។

សាលាដំបូងខេត្តបាត់ដំបងធ្វើដូចនេះ គឺជាវិធានការបណ្តោះអាសន្នក្នុងបំណងមួយធ្វើឱ្យអាពាហ៍ពិពាហ៍មុនថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៥ ស្របច្បាប់ ព្រោះថាពលរដ្ឋខ្មែរភាគច្រើនបានរៀបអាពាហ៍ពិពាហ៍តាមបែបប្រពៃណីជាពិសេសគឺពលរដ្ឋដែលរស់នៅក្នុងតំបន់ខ្មែរក្រហមដែលបានរៀបអាពាហ៍ពិពាហ៍ដោយមិនបាន

www.elibraryofcambodia.org
Scanned with CamScanner

ចុះបញ្ជី[6]។ ហើយម្យ៉ាងទៀត ទិដ្ឋភាពតតិយុត្តនៃអាពាហ៍ពិពាហ៍បានកប់លិចបាត់ ហើយការងារអត្រានុកូលដ្ឋានទើបតែចាប់ដំណើរការនៅឆ្នាំ២០០០ តែប៉ុណ្ណោះ។

ប៉ុន្តែនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៦ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ៨៩ អនក្រ.បក ដើម្បីកែសម្រួលចំណុច ក និងចំណុច ខ មាត្រា៥៩ ស្នូនថ្មីនៃអនុក្រឹត្យលេខ១០៦ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៥ បានពន្យារពេលការចុះសំបុត្រអត្រានុកូលដ្ឋានដល់**ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៦**។ ដូចនេះ យើងឃើញថារយៈពេលអន្តរកាលដែលតុលាការខេត្តបាត់ដំបងបានធ្វើ ហើយបានបញ្ឈប់នោះ វាមិនស្របទៅនឹងការចេញអនុក្រឹត្យជាបន្តបន្ទាប់របស់រាជរដ្ឋាភិបាលស្តីពីការកែសម្រួលអនុក្រឹត្យលេខ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន។ ដែលនោះជាបញ្ហារអសន្តិសុខតតិយុត្តមួយជាក់ច្បាស់។

ក្នុងគោលដៅដើម្បីធ្វើឲ្យអនីតិសង្វាសក្លាយទៅជាអាពាហ៍ពិពាហ៍ស៊ីវិលស្របច្បាប់នោះ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៧ ក្រសួងមហាផ្ទៃបានចេញសេចក្តីណែនាំលេខ ០០៨ សណន ស្តីពី ការចុះសៀវភៅអត្រានុកូលដ្ឋានឲ្យមានន័យត្រឹមភាពក្រោយបញ្ចប់ឃុទ្ធនាការចុះសៀវភៅអត្រានុកូលដ្ឋានចល័ត កំណត់នៅក្នុងចំណុច

---

6 ឃាក ឱលី ណុន ប្រធានសាលាដំបូងខេត្តបាត់ដំបង និង ឃាកសាស្ត្រាចារ្យ ប៉ែល ចំរើន, កាលវិភាគប្រវត្តិ *Annale* (សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០០៦), *បញ្ហាលក្ខណៈបច្ចេកទេសនៃអាពាហ៍ពិពាហ៍*, ទំព័រ៦៥។

www.elibraryofcambodia.org
Scanned with CamScanner

IV- ការសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ ចំពោះពលរដ្ឋម្នាក់ ដែលបានរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្តី ប្រពន្ធតែពុំមានសំបុត្រអាពាហ៍ពិពាហ៍ដូចតទៅ៖

"ពលរដ្ឋម្នាក់ដែលបានរស់នៅជាមួយគ្នាជាប្តី ប្រពន្ធ ឬបានរៀបអាពាហ៍-ពិពាហ៍តាមប្រពៃណីរួចហើយ តែពុំទាន់មានសំបុត្រអាពាហ៍ពិពាហ៍ប្រើប្រាស់ សាមីខ្លួនទាំងពីរនាក់ ត្រូវប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ (ការរៀបចំអាពាហ៍ពិពាហ៍ខាងស៊ីវិល) នៅសាលាឃុំ សង្កាត់សាមី ដែលខ្លួនរស់នៅពិតប្រាកដបច្ចុប្បន្ន។ ដើម្បីទទួលបានខ្នាសំបុត្រអាពាហ៍ពិពាហ៍ សាមីខ្លួនទាំងពីរនាក់ ត្រូវមានលិខិតស្នាម ដូចខាងក្រោម៖

- *ពាក្យសុំរៀបអាពាហ៍ពិពាហ៍*
- *លិខិតបញ្ជាក់ភាពនៅលីវ មេម៉ាយ ពោះម៉ាយ*
- *សេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួន (ប្រសិនបើមាន) ឬ*
- *សៀវភៅគ្រួសាររបស់សាមីខ្លួន (ប្រសិនបើមាន) ឬ*

www.elibraryofcambodia.org
Scanned with CamScanner

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរបស់សាមីខ្លួន (ប្រសិនបើមាន)។

មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ក្រោយពីពិនិត្យឃើញថា មានឯកសារគ្រប់គ្រាន់ និង ត្រឹមត្រូវ ហើយត្រូវចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ចំនួន ០៣ច្បាប់ ដោយមួយច្បាប់បិទផ្សាយជាសាធារណៈ នៅផ្ទះសាមីខ្លួនទាំងពីរបួនមួយច្បាប់បិទនៅសាលាឃុំ សង្កាត់សាមី និង មួយច្បាប់ទៀតរក្សាទុកជាឯកសារនៅសាលាឃុំ សង្កាត់សាមី។ ក្នុងរយៈពេលបិទផ្សាយប័ណ្ណប្រកាសអាពាហ៍ពិពាហ៍រយៈពេល ១០ថ្ងៃ បើគ្មានការប្តឹងជំទាស់ទេ សាមីខ្លួនទាំងពីរបួនអាចទៅសុំចុះឈ្មោះរៀបអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ (ការរៀបចំអាពាហ៍ពិពាហ៍ខាងស៊ីវិល) បាននៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ឃុំ សង្កាត់សាមី ដោយនាំសាក្សី ០២ រូប ដែលមានអាយុគ្រប់ការ និង មានទីលំនៅពិតប្រាកដរួមទៅជាមួយ" ។

ផ្នែកទី ២· លក្ខខណ្ឌសារធាតុនៃអនុសញ្ញា

ពាក្យ "**អធិតិសង្វាស**" ត្រូវបានគេប្រើប្រាស់នៅក្នុងច្បាប់នានាជាក់ស្តែងនៅក្នុងមាត្រា២២២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៧[7] ដោយមិនបានកំណត់របបគតិយុត្តរបស់វាឱ្យបានច្បាស់លាស់នោះទេ ។ ភាពីនៃចំនាក់ចំនងនេះ ម្លោងហៅថា

[7] ក្រមព្រហ្មទណ្ឌដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម ១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២២២ *(អំពើហិង្សាដែលប្រព្រឹត្តដោយសហព័ទ្ធ ឬ អធិតិសង្វាសជន)* ។

www.elibraryofcambodia.org
Scanned with CamScanner

អនីតិសង្វាសី ឬ អនីតិសង្វាសនី (តាមសន្ធានុក្រមបារាំងខ្មែរ) តែក្រមព្រហ្មទណ្ឌ មាត្រា២២២ ប្រើពាក្យ អនីតិសង្វាសជន។ ដូចនេះ ការប្រើពាក្យ អនីតិសង្វាសជន គឺវាស្របជាមួយបញ្ញត្តិច្បាប់។ ទោះជាយ៉ាងណាក៏ដោយ អនីតិសង្វាសត្រូវបានគេផ្តល់និយមន័យថា គឺជា "*ស្ថានភាពរបស់បុរស និង នារីដែលរួមរស់នៅជាមួយគ្នាដូចប្តីប្រពន្ធមានខាន់ស្លា ប៉ុន្តែឥតមានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ*" [8]។ រីឯនៅប្រទេសបារាំងវិញ អនីតិសង្វាស (le concubinage) ត្រូវគេកំណត់និយមន័យច្បាស់លាស់នៅក្នុងក្រមរដ្ឋប្បវេណីបារាំងថា គឺជា "*សមគ្គសង្វាសតាមព្រឹត្តិន័យ ដែលមានលក្ខណៈជាការ រស់នៅរួមគ្នាភ្ជាប់ជាមួយនូវលក្ខណៈស្ថេរភាព និង និរន្តរភាព រវាងបុគ្គលពីរនាក់ ដែលមានភេទខុសគ្នា ឬ ដូចគ្នា ហើយដែលរស់នៅជាមួយគ្នាដូចជាប្តីប្រពន្ធ*" [9]។ និយមន័យនេះ មានចំណាងកំណត់អំពីសញ្ញាណនៃអនីតិសង្វាសដែលអាចអនុវត្តខុសគ្នាអំពីអាពាហ៍ពិពាហ៍រវាងប្តីប្រពន្ធដែលកើតឡើងពីចំណងអាពាហ៍ពិពាហ៍។ ទាញចេញពីនិយមន័យទាំងនេះ យើងអាចកំណត់បានអំពីលក្ខខណ្ឌសារធាតុនៃអនីតិសង្វាសដែលមានដូចខាងក្រោមនេះ។

អថាខណ្ឌតី ១- សមគ្គសង្វាសតាមព្រឹត្តិន័យ (Union de fait)

---

8 សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច, *សន្ធានុក្រមបារាំង-ខ្មែរនៃពាក្យច្បាប់*, (ភ្នំពេញ៖ ហ៊ុណន ២០០៥),ទំព័រទី៧៩ ។

9 Code Civil Français, (DALLOZ, 2009), article 518-8 *Le concubinage est une union du fait, caractérisée par une vie commune présentant un caractère de stabilité et de continuité, entre deux personnes, de sexe différent ou de même sexe, qui vivent en couple.*

ប្រព័ន្ធបណ្ណាល័យ ហ៊ុន សែន HUN SEN LIBRARY R.U.P.P សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ

www.elibraryofcambodia.org

Scanned with CamScanner

អនីតិសង្វាសគឺជាការរួមសមគ្គសង្វាសមួយ, ជាចំណង, ជាសហគមន៍មួយ ដែលច្បាប់ និង យុត្តិសាស្ត្របានផ្តល់នូវអានុភាពវិជ្ជមាន និងអវិជ្ជមាន។ វាគឺជាព្រឹត្តិការណ៍មួយ តែជាព្រឹត្តិការណ៍ដែលបង្កើតអានុភាពគតិយុត្ត។ ម៉្យាងទៀត អនីតិសង្វាសត្រូវបានបែងចែកដាច់ពីអាពាហ៍ពិពាហ៍ដែលជាលិខិត ឬ សកម្មភាពគតិយុត្តមួយ រីឯអនីតិសង្វាសគឺជាសមគ្គសង្វាសសេរីមួយ (Union libre)[10] ដែលវាត្រូវបានបង្កើតដោយឆន្ទៈសេរីរបស់គូភាគី និងរលាយទៅវិញដោយសេរីផងដែរ។ ច្បាប់ស្តីពីឯកភាពភាព ត្រង់មាត្រា ៣ កថាខណ្ឌទី១ វាក្យខណ្ឌទី២ និង ច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ១៩៨៩ ត្រង់មាត្រា ៣ បញ្ញត្តិថា៖ "*អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យារវាងបុគ្គលភេទប្រុសមួយ ធ្វើឡើងដោយបុរស និង នារីម្នាក់ដែលប្តេជ្ញាថាខ្លួនឱ្យរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយមិនរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួនឡើយ*"។ តាមការបកស្រាយបែបបដិណេមវិធី ខុសគ្នាពីអនីតិសង្វាស អាពាហ៍ពិពាហ៍អាចត្រូវបានរលាយដោយតម្រូវឱ្យឆ្លងកាត់នីតិវិធីច្បាប់មួយឥតងាករាងដូចជាមានមូលហេតុ និងនីតិវិធីមួយច្បាស់លាស់ ពោលគឺមិនមែនរំលាយដោយទំនើងចិត្តរបស់ប្តីប្រពន្ធនោះទេ។

កថាខណ្ឌទី ២- លក្ខណៈនៃការរស់នៅរួមគ្នា (Vie commune)

10 Philippe MALAURIE, Hugues FULCHIRON, *LA FAMILLE* (Editions juridiques associés: DEFRÉNOIS, 2006), p158, paragraphe 312.

www.elibraryofcambodia.org
Scanned with CamScanner

ដូចគ្នានឹងប្តីប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ លក្ខណៈនៃការរស់នៅជាមួយគ្នាត្របដណ្តប់ទៅលើការរស់នៅក្រោមដំបូលផ្ទះតែមួយ និងដំណើរជីវិតរួមគ្នាមួយ។ តែបើនិយាយអំពីផ្នូរសម្ភារៈវិញ អនីតិសង្វាសមិនខុសអំពីអាពាហ៍ពិពាហ៍នោះទេ ព្រោះវាគឺជាព្រឹត្តការណ៍គតិយុត្តមួយ និងមានការរស់នៅរួមគ្នាដូចគ្នានឹងអាពាហ៍ពិពាហ៍។ ការរស់នៅជាមួយគ្នាមិនមែនជាលក្ខណៈជាសារវន្តក្នុងការកំណត់អំពីអត្ថិភាពនៃអនីតិសង្វាសនោះទេ តែវាត្រូវបានកំណត់ដោយលក្ខណៈស្ថេរភាព និងនិរន្តរភាពទៅវិញទេ។

កថាខណ្ឌទី ៣- លក្ខណៈនៃស្ថេរភាព និង និរន្តរភាព (Un caractère de stabilité et de continuité)

ទំនាក់ទំនងក្រៅអាពាហ៍ពិពាហ៍ដូចជាអនីតិសង្វាសជាដើម ឈានឡើងនូវភាពចំរុះច្រើនបែបដែលខ្លះ ស្ថិតជានិរន្តរ ខ្លះរយៈពេលខ្លី ខ្លះលាក់កំបាំង ខ្លះបើកចំហជាសាធារណៈ ខ្លះសង្គមទទួលស្គាល់ ឬខ្លះសង្គមមិនទទួលស្គាល់។ ក៏ប៉ុន្តែ ការទាក់ទងគ្នាម្តងម្កាល មិនបង្កើតជាអនីតិសង្វាសនោះទេ ពីព្រោះថាអនីតិសង្វាសត្រូវការអំឡុងពេលវេលាសមស្របមួយ ពោលអនីតិសង្វាសគឺជាស្ថានភាពនៃព្រឹត្តការណ៍ដែលមានរយៈពេលយូរជានិរន្ត។ លោក **Jean Carbonnier** បានលើកឡើងថា៖ *"អនីតិសង្វាស គុសអំពីអាពាហ៍ពិពាហ៍ ហើយទម្រង់នៃសមគ្គីសង្វាសក្រៅ*

www.elibraryofcambodia.org
Scanned with CamScanner

អាពាហ៍ពិពាហ៍ប្រភេទនេះគឺ មានលក្ខណៈជាទិវន្ត។ ហើយអនីតិសង្វាសរួមផ្សំដោយការរួមរស់នៅជាមួយគ្នា ការងារផ្ទះរួមគ្នា[11]។

អនីតិសង្វាសដែលជាសមគ្គសង្វាសដោយសេរីមួយ អាចត្រូវបានគេទទួលស្គាល់ថាវាបង្កើតអនុភាពគតិយុត្ត តែក្នុងករណីដែលស្ថានភាពនៃអនីតិសង្វាសមានស្ថេរភាពមួយច្បាស់លាស់ដូចគ្នាទៅនឹងអាពាហ៍ពិពាហ៍[12]។ ហើយប្រសិនបើលក្ខណៈនៃស្ថេរភាពនេះ មិនមានការរួមរស់នៅជាមួយគ្នានោះទេ ការចម្លងជំងឺអេដស៍ពីម្ខាក់ទៅម្ខាក់ ទីងត្រូវសងការខូចខាតទៅភាគីម្ខាងទៀត[13]។ ដូចគ្នាដែរ កម្ពុជាហាមឃាត់ដាច់ខាតចំពោះអ្នកដែលដឹងថាខ្លួនមាន មេរោគអេដស៍ ឬ ជំងឺអេដស៍ទៅប្រព្រឹត្តក្នុងចេតនាចំលងទៅអ្នកឯទៀត[14]។ ដូចនេះ ការទទួលខុសត្រូវផ្នែកអប្បរមណី ឬ ផ្នែកព្រហ្មទណ្ឌចំពោះការចម្លងជម្ងឺនេះ ទីងត្រូវកំណត់ដោយលក្ខណៈស្ថេរភាពនៃអនីតិសង្វាសនេះឯង។

---

11 Jean Carbonnier, *FLEXIBLE DROIT : POUR UNE SOCIOLOGIE DU DROIT SANS RIGUEUR* (France, 10ème édition L.G.D.J, 2007), page 163 (*Le concubinage : À la différence de la précédente, transitoire par définition, cette forme d'union hors mariage est durable. Elle implique cohabitation, ménage commun*).

12 Code Civil Français, (Edition Dalloz, 2014), *article 143, 1 Notion (Montpellier, 8 juillet 1982)*

13 Code Civil Français, (Edition Dalloz, 2014), *article 143, 1 Notion (Paris, 23 Septembre 1959)*

14 ច្បាប់ស្តីពីការបង្ការ និង ការប្រយុទ្ធប្រឆាំងការរីករាលដាលមេរោគអេដស៍ ជំងឺអេដស៍ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ លេខ នស /រកម/ ០៨០២/ ០១៥ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០២, *មាត្រា៨ មិន ៥០*។

www.elibraryofcambodia.org
Scanned with CamScanner

អនីតិសង្វាសដែលមានស្ថេរភាពផ្តល់ទៅឱ្យអនីតិសង្វាសនូវគុណសម្បត្តិគ្រប់គ្រាន់ក្នុងការរៀបចំបុណ្យសពរបស់អនីតិសង្វាសជន ដោយសារថាដីងអំពីឥទ្ធិពលរបស់សព[15] ។

ដោយឡែក អនីតិសង្វាសដែលគេដឹងឮជាសាធារណៈជាសហគមន៍ជីវិត និងផលប្រយោជន៍ដែលទាមទារឱ្យមានទំនាក់ទំនងស្ថិតស្ថេរមួយ ហើយត្រូវបានគេដឹងឮជាសាធារណៈ។

អថាខណ្ឌតី ៨ ខោខមុឌ្ឍលតីនោរ៉ាំ តេពនុសតូ ឬ ជុចតូ? (Entre deux personnes de sexe différent ou de même sexe)

នៅតាមបណ្តាប្រទេសអឺរ៉ុប ជាពិសេសនៅប្រទេសបារាំងដែលត្រូវបានគេស្គាល់ថាជាប្រទេសនៃសិទ្ធិមនុស្សនោះ មុនមានកំណែទម្រង់ច្បាប់ដែលអនុញ្ញាតទទួលស្គាល់នូវអាពាហ៍ពិពាហ៍ស្របច្បាប់រវាងបុគ្គលដែលមានភេទដូចគ្នា ដូចដែលមានចែងក្នុងមាត្រា១៤៣ នៃក្រមរដ្ឋប្បវេណីបារាំង និងដែលត្រូវបានប្រកាសឱ្យប្រើដោយច្បាប់លេខ ២០១៣-៤០៤ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ ២០១៣ [16] ក៏ដោយក៏អនីតិសង្វាសរវាងបុគ្គលដែលមានភេទដូចគ្នាត្រូវបានទទួលស្គាល់តាមរយៈច្បាប់ដែលប្រកាសឱ្យប្រើនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៩ មកម្ល៉េះ។ ដោយឡែកនៅ

15 Code Civil Français, (Edition Dalloz, 2014), *article 143, 1 Notion (Douai, 7 Juillet 1998)*
16 Code Civil Français, (Edition Dalloz, 2014), article 143

www.elibraryofcambodia.org
Scanned with CamScanner

ប្រទេសកម្ពុជា ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ ត្រង់មាត្រា ៣ និង ក្រមរដ្ឋប្បវេណីកម្ពុជាថ្មីឆ្នាំ២០០៧ ត្រង់មាត្រា៩៤៨ ទទួលស្គាល់តែអាពាហ៍ពិពាហ៍ដែលមានភេទផ្ទុយគ្នាតែប៉ុណ្ណោះ ក៏ប៉ុន្តែស្ថានភាពជាក់ស្តែងគេឃើញមានការកើតឡើងនៃការរស់នៅជាមួយគ្នា និងការយកគ្នាជាប្តីប្រពន្ធរវាងមនុស្សដែលមានភេទដូចគ្នា (រវាងបុរស និង បុរស និង រវាងនារី និង នារី) ដោយសារសង្គមកម្ពុជាកាន់តែស្គាល់ខ្លួនចំពោះបាវបនីយកម្ម ហើយសិទ្ធិសេរីភាពរបស់បុគ្គលម្នាក់ៗត្រូវបានទទួលស្គាល់យ៉ាងពេញលេញនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣[17]។

ដោយហេតុថា នៅក្នុងការអនុវត្តជាក់ស្តែងនៅតាមតុលាការ នៅពេលមានបណ្តឹងផ្តាច់អនីតិសង្វាសគឺគេតែងតែឃើញមានការប្តឹងពីបុគ្គលដែលមានភេទខុសគ្នា ដោយមូលហេតុលក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍មិនត្រូវបានបំពេញ (ការចុះសំបុត្រអាពាហ៍ពិពាហ៍)។ នេះដោយហេតុថាអនីតិសង្វាសនៅក្នុងក្រសែភ្នែកអ្នកអនុវត្តច្បាប់នៅកម្ពុជា គឺកើតឡើងមកពីមូលហេតុដោយការមិនបានបំពេញនូវលក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍តែមួយមុខប៉ុណ្ណោះ។ អត្ថិភាពនៃអនីតិសង្វាសរវាងបុគ្គល

17 លោកស្រី ចាំង ស្រីរតា, កញ្ញា លី រ៉ាន់ាថ, លោក ស៊ុន សុពុទ្ធិ, លោក ការ៉ន់ សិទ្ធប៊ុលីន និង លោក ហ៊ី ផុនា , ការងារស្រាវជ្រាវ និង តាក់តែងកិច្ចការជាក្រុម។ *អនីតិសង្វាស* (សាលាភូមិន្ទសេរីការី, ២០១៣), ទំព័រទី៨ និង ៩។

www.elibraryofcambodia.org
Scanned with CamScanner

ដែលមានភេទដូចគ្នាមិនទាន់ត្រូវបានលើកឡើងជាយុត្តិសាស្ត្រនៅសាលាជម្រះក្តីនោះទេ។ ដោយមានការបើកចំហរដល់សិទ្ធិសេរីភាព និងស្របទៅនឹងការរីកចម្រើនរបស់សង្គមកម្ពុជានោះ បុគ្គលដែលមានភេទដូចគ្នាគាន់តែមានភាពភ្ជាប់ពាក់ព័ន្ធក្នុងការបង្ហាញពីសមត្ថសង្វាសរបស់ពួកគេជាសាធារណៈ។

ម្យ៉ាងទៀត បញ្ហានឹងកើតឡើងនៅពេលដែលមានការដាក់ពាក្យសុំបញ្ឈប់អត្ថិភាពនៃអនីតិសង្វាសរវាងបុគ្គលដែលមានភេទដូចគ្នានៅចំពោះមុខតុលាការ ហើយថាតើតុលាការនឹងលើកពាក្យបណ្តឹងនោះចោលតាមមាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឬ ក៏ទទួលពាក្យបណ្តឹងនោះយកមកចាត់ការ ហើយសំនួរបន្ទាប់គឺថាតើត្រូវចាត់ការយ៉ាងដូចម្តេច។ ដូចដែលយើងបានបញ្ជាក់ខាងលើមកហើយថាអនីតិសង្វាសមិនមែនកើតឡើងដោយសារតែការមិនបានបំពេញនូវលក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍នោះទេ អ្វីដែលសំខាន់នោះគឺលក្ខខណ្ឌសារធាតុទៅវិញទេ។ ការទទួលស្គាល់នូវអនីតិសង្វាសរវាងបុគ្គលដែលមានភេទដូចគ្នាគឺជាការអនុវត្តយ៉ាងទន់ភ្លន់នូវច្បាប់ តែវារក្សាបាននូវស្ថេរភាពគតិយុត្តមួយដល់សង្គម ជាពិសេសស្ថាប័នអនុវត្តច្បាប់តែម្តង។ ក៏ប៉ុន្តែ ការទទួលស្គាល់បែបនេះវាផ្ទុយនឹងទំនៀមទំលាប់ដ៏ល្អរបស់សង្គមខ្មែរ។

អថាខណ្ឌទី ៥- ការរស់នៅជុំចន្លីប្រពន្ធ (qui vivent en couple)

www.elibraryofcambodia.org
Scanned with CamScanner

ការរស់នៅដូចជាប្តីប្រពន្ធនេះគឺជាធាតុសំខាន់មួយនៅក្នុងលក្ខណៈវិនិច្ឆ័យនៃអនីតិសង្វាស។ ហើយ អនីតិសង្វាសមិនមែនគ្រាន់តែជាការរស់នៅជាមួយផ្នូរសម្ភារៈ និងផ្នូរកាទតែប៉ុណ្ណោះនោះទេ ក៏ប៉ុន្តែអនីតិសង្វាសក៏ជាចំណងដែលកើតឡើងពីព្រឹត្តិការណ៍ និងដែលបង្កើតអាទុភាពតាមផ្នូរច្បាប់ផងដែរ[18] ។

ដើម្បីអាចចាត់ទុកថាជាប្តីប្រពន្ធ អនីតិសង្វាសត្រូវរំលេចឡើងនូវភាពដែលអាចមើលឃើញពីលក្ខណៈខាងក្រៅមួយចំនួន នេះបើយោងលើទ្រឹស្តីនៃសភាពខាងក្រៅ (la théorie de l'apparence)។ ឧទាហរណ៍ បុរស និងនារី រួមរស់នៅជាមួយគ្នាមិនត្រឹមតែក្នុងជីវភាពប្រចាំថ្ងៃទេ ពួកគាត់សម្រេកវិស្សមកាលជាមួយគ្នាចូលរួមជីវភាពក្នុងសង្គមជាមួយគ្នា មានកូនជាមួយគ្នា។ល។

កថាខណ្ឌទី ៦- ការរួមបាយ រួមទឹក រួមគ្នា (Boire, manger, coucher ensemble...)

លោក **Loysel** បានលើកឡើងថា៖ "*ការរួមបាយ រួមទឹក រួមដំណេកគឺវាជាអាពាហ៍ពិពាហ៍សម្រាប់ខ្ញុំ។ ក៏ប៉ុន្តែ វាត្រូវមានការព្រាហ្មណ៍នៅព្រះវិហារ*" ពីក្នុងន័យនៃឧត្តរិកភាពនៃអាពាហ៍ពិពាហ៍នេះឯង។ ចំណែកឯលោក **Jean Carbonnier** បានលើកឡើងផងដែរថា៖ "*អនីតិសង្វាសខុសអំពីអាពាហ៍ពិពាហ៍ ហើយទម្រង់នៃ*

18 Philippe MALAURIE, Hugues FULCHIRON, *LA FAMILLE* (Editions juridiques associés: DEFRÉNOIS, 2006), p160, paragraphe 316.

www.elibraryofcambodia.org
Scanned with CamScanner

សមត្ថសង្វាសក្រៅអាពាហ៍ពិពាហ៍ប្រហែលនឹង គឺមានលក្ខណៈជាទូទៅ។ ហើយ អនីតិសង្វាស រួមផ្សំដោយ ការរួមរស់នៅជាមួយគ្នា និងការងារផ្ទះរួមគ្នា" [19]។

នៅបណ្តាប្រទេសអឺរ៉ុប អាពាហ៍ពិពាហ៍ត្រូវប្រព្រឹត្តជាឧឡារិកដើម្បីបង្កើតបានជាចំណងផ្នូវច្បាប់មួយហើយត្រូវឆ្លងកាត់ពីព្រះវិហារគ្រិស្តដែលបញ្ជាក់អំពីការផ្តាស់ប្តូរឆន្ទៈរវាងប្តីប្រពន្ធនៅចំពោះមុខគ្រួសារ សាច់ញាតិ និងសង្គម។ ដូចនេះ អាពាហ៍ពិពាហ៍គឺជាស្ថាប័នមួយ រីឯអនីតិសង្វាសមិនមែនជាស្ថាប័ននោះទេ[20]។ ដូចគ្នានៅក្នុងសង្គមខ្មែរដែរ ពីបុរាណកាលមកអាពាហ៍ពិពាហ៍តម្រូវឲ្យមានការប្រារព្ធពិធីបែបប្រពៃណី និងសាសនាដើម្បីជាការប្រកាសជាសាធារណៈជ្រាប់ដល់គ្រួសារ សាច់ញាតិ និងសង្គមអំពីចំណងស្របច្បាប់របស់ពួកគេ[21]។ អនីតិសង្វាសដែលរាប់បញ្ចូលនូវការរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធ ការរួមបាយរួមទឹក ការរួមដំណេក ក៏អាចធ្វើឡើងជាសាធារណៈផងដែរ។

អថាខណ្ឌទី ៧ តម្រុតាមដើម្បីគាំទ្រលក្ខខណ្ឌសារធាតុនៃអនីតិសង្វាស

19 Jean Carbonnier, *FLEXIBLE DROIT : POUR UNE SOCIOLOGIE DU DROIT SANS RIGUEUR* (France, 10ème édition L.G.D.J, 2007), page 163 (*Le concubinage : À la différence de la précédente, transitoire par définition, cette forme d'union hors mariage est durable. Elle implique cohabitation, ménage commun*).

20 Philippe MALAURIE, Hugues FULCHIRON, *LA FAMILLE* (Editions juridiques associés: DEFRÉNOIS, 2006), p160, paragraphe 317

21 ឆយ ឈីហាង, ប្រែង ពិសិដ្ឋ..., *ដំណឹរវិវត្តន៍អាពាហ៍ពិពាហ៍ថ្មី* (ភ្នំពេញ ៧ មករា ឆ្នាំ២០០៨)។

www.elibraryofcambodia.org
Scanned with CamScanner

ការប្រកាសអំពីនត្ថិភាពនៃអាពាហ៍ពិពាហ៍ដោយឈរលើមូលដ្ឋានគតិយុត្តខាងលើ អាចជាសច្ចធារណ៍តាមផ្លូវតុលាការអំពីអត្ថិភាពនៃអនីតិសង្វាស។

នៅប្រទេសកម្ពុជាសព្វថ្ងៃ ការងារគ្រប់គ្រងស្ថិតិប្រជាជននៅមានលក្ខណៈទន់ខ្សោយនៅឡើយ។ ភាពទន់ខ្សោយនេះបានបង្កទៅជាផលអវិជ្ជមានផ្នែកគតិយុត្តយ៉ាងខ្លាំង ពីព្រោះថាបើទោះបីជាមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ក៏ដោយ ក៏បុរសនិង នារីដែលរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ទទួលបានឱ្យការធ្វើសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារដោយទទួលស្គាល់ភាពជាប្តីប្រពន្ធឱ្យគ្នា។ តាមពិតទៅ សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ មិនមែនជាលិខិតអត្រានុកូលដ្ឋាននោះទេ ព្រោះវាមិនបានធ្វើឡើងដោយមន្ត្រីអត្រានុកូលដ្ឋាន ដូច្នេះវាមិនអាចបញ្ជាក់អំពីអត្ថិភាពនៃអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់នោះទេ។ ផ្ទុយទៅវិញ វាអាចជាភស្តុតាងដែលបញ្ជាក់អំពីអត្ថិភាពនៃអនីតិសង្វាសបាន។ ក៏ប៉ុន្តែ នៅសាលាជម្រះក្តីមួយចំនួន មិនមានការតម្រូវឱ្យភាគីដាក់សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅមកជូនតុលាការនោះទេ គឺការដាក់ភស្តុតាងដោយឆន្ទៈសេរីរបស់ភាគី។ តែក្នុងស្ថានភាពជាក់ស្តែង នៅពេលមានបណ្តឹងផ្តាច់អនីតិសង្វាស ភាគីទាំងសងខាងភាគច្រើនបានយល់ស្របគ្នាអំពីការរស់នៅជាមួយគ្នាជាអនីតិសង្វាស។ ទោះជាយ៉ាងណាក៏ដោយ ក៏តុលាការអាចតម្រូវឱ្យភាគីដាក់ភស្តុតាងបានទោះបីមានការរអ៊ូរទាំដូចគ្នាក៏ដោយ ដោយយោងទៅតាមការបកស្រាយនៃមាត្រា១២៣ នៃក្រមនីតិវិធី

www.elibraryofcambodia.org

Scanned with CamScanner

រដ្ឋប្បវេណី ដែលបង្កប់នូវ *គោលការណ៍សង្គតិភាពរណ៍តាមផ្លូវតុលាការ*។ ក្នុងគ្រប់ករណី តុលាការត្រូវធ្វើនីតិវិធីផ្ទៀងផ្ទាត់លើភស្តុតាងដែលបានដាក់ជូនមកខ្លួនដោយគូភាគី បើទោះបីជាភស្តុតាងនោះជាសម្តីសារភាពរបស់គូភាគីក៏ដោយ។ ការផ្ទៀតផ្ទាត់នេះ គឺដើម្បីពិនិត្យមើលទៅលើភាពពិតប្រាកដ ភាពត្រឹមត្រូវ និងភាពដែលអាចឱ្យចៅក្រមជឿទៅលើភស្តុតាងទាំងនោះបាន។

ក្នុងសភាពជាសមគ្គសង្វាសសេរី[22] អនីតិសង្វាសអាចត្រូវបានបង្ហាញតាមគ្រប់មធ្យោបាយផ្សេងទៀតដូចជា តាមទូរស័ព្ទ តាមរយៈការដាក់អាសយដ្ឋានរួមគ្នា វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ ការចុះក្នុងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ សារអេឡិចត្រូនិចនានា រូបថតពេលរៀបប្រារព្ធពិធីអាពាហ៍ពិពាហ៍ (អាពាហ៍ពិពាហ៍តាមផ្លូវប្រពៃណី) ឬកំជាប់ពាក្យ បងប្អូនសាច់ញាតិ លិខិតអញ្ជើញចូលរួមអាពាហ៍ពិពាហ៍ ការបញ្ជាក់ពី មេភូមិ មេឃុំ ឬចៅសង្កាត់ ការដឹងឮថាបុរស និងនារីពិតជាបានរៀបអាពាហ៍ពិពាហ៍តាមផ្លូវប្រពៃណីមែនជាដើម។

ទន្ទឹមនឹងនោះដែរ ដោយសារថាអនីតិសង្វាសមិនត្រូវបានបញ្ញត្តិនៅក្នុងច្បាប់ទេនោះ នោះលក្ខខណ្ឌទម្រង់ជាលាយលក្ខណ៍អក្សរក៏មិនមានដែរ ពោលគឺគេអាច

22 Philippe MALAURIE, Hugues FULCHIRON, *LA FAMILLE* (Editions juridiques associés; DEFRÉNOIS, 2006), *Union de fait*, p158, paragraphe 312

www.elibraryofcambodia.org
Scanned with CamScanner

បញ្ជាក់បានដោយសេរី ព្រោះវាជាសម្ព័ន្ធសង្វាសដែលកើតឡើងតាមព្រឹត្តិយដោយសេរីតាមឆន្ទៈរបស់គូភាគី។

ទស្សនទានរបស់ក្រុមអ្នកច្បាប់ជប៉ុនគិតថា ប្រទេសជប៉ុន និងកម្ពុជាមានស្ថានភាពដូចគ្នាគឺ *"ដោយសារតែមិនបានបំពេញលក្ខខណ្ឌអាពាហ៍ពិពាហ៍ដូចមានចែងក្នុងមាត្រា៩៥៥[23] និងមាត្រា៩៥៦[24] នៃក្រមរដ្ឋប្បវេណីកម្ពុជា អាពាហ៍ពិពាហ៍មិនកើតឡើងទេ ប៉ុន្តែករណីអាពាហ៍ពិពាហ៍ដែលបានប្រព្រឹត្តឡើងជាក់ស្តែងក្នុង*

---

23 ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស ររម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ (ច្បាប់ជាធរមានចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១), មាត្រា៩៥៥ (ការដាក់ពាក្យ សុំរៀបអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍)៖ *១. អាពាហ៍ពិពាហ៍មិនមានអនុភាព ដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និង ការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។ ២. ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និង ការចុះបញ្ជីអាពាហ៍ពិពាហ៍ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើ ត្រូវធ្វើតាមនីតិវិធីដែលបានកំណត់នៅក្នុងបទប្បញ្ញត្តិស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន។*

24 ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៥៦ (ការទទួលពាក្យសុំ រៀបអាពាហ៍ពិពាហ៍) ៖ *ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ពុំអាចទទួលយកបានឡើយ បើបានទទួលស្គាល់ថាអាពាហ៍ពិពាហ៍ នោះផ្ទុយនឹងបញ្ញត្តិចាប់ពីមាត្រា ៩៥៨ (អាយុត្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍) រហូតដល់មាត្រា ៩៦៩ (ការរៀបអាពាហ៍ពិពាហ៍របស់ជនជាតិក្រៅអាណាព្យាបាលទូទៅ) ខាងលើនេះ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត។*

www.elibraryofcambodia.org
Scanned with CamScanner

សង្គមគឺជាអនីតិសង្វាស" [25] ។ ទស្សនៈទាំងនេះកំពុងតែបង្កើតសច្ចធារណ៍នៃអត្ថិភាពនៃអនីតិសង្វាស ដោយមិនបានពិចារណាទៅលើលក្ខណៈផ្សេងទៀត។ នៅប្រទេសជប៉ុន មូលហេតុដែលនាំឲ្យកើតមានអនីតិសង្វាសមានដូចតទៅនេះ៖ ទី១ ករណីមានឧបសគ្គចំពោះការរៀបអាពាហ៍ពិពាហ៍ ដោយសារភាគីម្ខាងបានរៀបអាពាហ៍-ពិពាហ៍រួចហើយ ឬ មិនទាន់ត្រប់អាយុជាដើម, ទី២ ករណីភាគីមិនរៀបអាពាហ៍-ពិពាហ៍ដោយសារស្ថានភាពផ្លូវចិត្តរបស់ភាគី ដូចជាមិនចង់មានចំណងផ្លូវច្បាប់ ឬ មិនចង់ប្តូរត្រកូលជាដើម, ទី៣ ករណីឃើតឃើរក្នុងការដាក់ពាក្យសុំរៀបអាពាហ៍-ពិពាហ៍ និង ទី៤ គឺដោយសារមានករណីខ្លះ ទោះបីជាភាគីចង់រៀបអាពាហ៍ពិពាហ៍ក៏ដោយ ប៉ុន្តែពួកគេមិនមានលទ្ធភាពផ្នែកហិរញ្ញវត្ថុគ្រប់គ្រាន់អាចធ្វើទៅតាមប្រពៃណីបាន ឬ តាមច្បាប់បាន ហេតុនេះហើយទើបត្រូវតែជ្រើសរើសយកអនីតិសង្វាស។ ម្យ៉ាងទៀត មានការយល់ឃើញថាអាពាហ៍ពិពាហ៍តាមប្រពៃណីមានសារៈសំខាន់ជាងការដាក់ពាក្យសុំ។ ហើយស្ថានភាពនេះមានភាពប្រហែលទៅនឹងអ្វីដែលកំពុងតែកើតមាននៅក្នុងប្រទេសកម្ពុជា[26]។

---

25 Ms. MIURA YASUKO, សាស្ត្រាចារ្យនៃវិទ្យាស្ថានស្រាវជ្រាវ និង បណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌, (២០១៣, សិក្ខាសិលាស្តីពីអនីតិសង្វាស និង សន្តតិកម្ម), *ស្តីពីអនីតិសង្វាស*, ទំព័រទី១

26 Ms. MIURA YASUKO, សាស្ត្រាចារ្យនៃវិទ្យាស្ថានស្រាវជ្រាវ និង បណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌, (២០១៣, សិក្ខាសិលាស្តីពីអនីតិសង្វាស និង សន្តតិកម្ម), *ស្តីពីអនីតិសង្វាស*, ទំព័រទី១

www.elibraryofcambodia.org
Scanned with CamScanner

ក៏ប៉ុន្តែ ភស្តុតាងដែលសាមីខ្លួនអាចបង្ហាញបានដោយសេរីនោះ វាមិនមែនជាភស្តុតាងដែលមិនអាចប្រកែកបាននោះទេ។ ដូច្នេះ ក្នុងការអនុវត្តជាក់ស្តែងទាមទារឲ្យចៅក្រមត្រូវពិនិត្យមើលទៅលើលក្ខណសារធាតុផ្សេងទៀតដែលអាចឲ្យយើងវិនិច្ឆ័យទទួលស្គាល់នូវអត្ថិភាពនៃអនីតិសង្វាស។

ជំពូកទី ២· អនុគាមកុងអំឡុងពេលអត្ថិភាពនៃអនីតិសង្វាស

ដោយសារអនីតិសង្វាសជាព្រឹត្តិការណ៍គតិយុត្តរវាងបុគ្គលពីរនាក់ នោះវាបង្កើតអនុភាពគតិយុត្តផ្នែកបុគ្គល (ក្រៅបេតិកភណ្ឌ) និង អនុភាពគតិយុត្តផ្នែកទ្រព្យសម្បត្តិ (ផ្នែកបេតិកភណ្ឌ)។ ក៏ប៉ុន្តែ អនុភាពគតិយុត្តទាំងនេះ យើងគួរតែពិចារណាចាប់ពីពេលដែលការងារអន្ត្រានុក្ខលដ្ឋានបានចប់សព្វគ្រប់ គោលគឺចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៧ (យោងតាមអនុក្រឹត្យលេខ៨៩ អនក្រ.បក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៦)។

ផ្នែកទី ១· អនុគាមផ្នែកបុគ្គល (ក្រៅបេតិកភណ្ឌ)

យើងព្យាយាមវែកញែករវាងអនុភាពរវាងអនីតិសង្វាសជនទាំងពីរ និងរវាងអនីតិសង្វាសជនជាមួយក្នុន។

ក·ចាខណ្ឌទី ១· នោងអនីតិសង្វាសជន

www.elibraryofcambodia.org
Scanned with CamScanner

ជាចំណាងរដ្ឋប្បវេណីដែលកើតឡើងតាមរយៈហេតុ អនីតិសង្វាសបង្កើតអានុភាពផ្នែករដ្ឋប្បវេណី ហើយយើងក៏ពិនិត្យមើលផងដែរថាចំណងនេះមានបង្កើតអានុភាពគតិយុត្តនៅក្នុងវិស័យច្រហ្មទណ្ឌដែរឬយ៉ាងណា។

ចំណុចទី ១ ផ្នែករដ្ឋប្បវេណី

១- បន្ទើតចំណងញាតិ?

ត្រូវចាត់ទុកថាមានទំនាក់ទំនងជាញាតិគឺ ទីមួយរវាងញាតិណោហិតក្នុង ៦ (ប្រាំមួយ) ថ្នាក់ ទីពីរ សហព័ទ្ធ និង ទី៣ ញាតិពន្ធក្នុង ៣ (បី) ថ្នាក់ [27]។ ញាតិត្រូវបានកំណត់ជាបញ្ជីមួយច្បាស់លាស់។ អ្វីដែលមិនមានចែងក្នុងបញ្ជីនេះទេ មិនត្រូវបានទទួលស្គាល់ជាញាតិនោះទេ។ ម្យ៉ាងទៀត សហព័ទ្ធនៅទីនេះកើតឡើងដោយសារមានការរៀបអាពាហ៍ពិពាហ៍តាមផ្នូវច្បាប់។ ដូចនេះតាមការបកស្រាយបែបបដិណោមវិធី អនីតិសង្វាសមិនបង្កើតទំនាក់ទំនងជាញាតិនោះទេ។ ដូចនេះរវាងអនីតិសង្វាសជនទាំងពីរ មិនមានការកកើតឡើងនូវសិទ្ធិ និងកាតព្វកិច្ចដូចដែលញាតិមានឱ្យគ្នានោះទេ ជាពិសេសគឺទំនាក់ទំនងជាប្តី ប្រពន្ធតាមផ្នូវច្បាប់។

---

27 ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, អាត្រា៤៣៨ *ទំហំរបស់ញាតិ*។

បណ្ណាល័យ ហ៊ុន សែន HUN SEN LIBRARY R.U.P.P

www.elibraryofcambodia.org
Scanned with CamScanner

ដោយហេតុថាអនីតិសង្វាសជាសមគ្គីសង្វាសដោយសេរី វាមិនបង្កើតកាតព្វកិច្ចរួមរស់នៅជាមួយគ្នា កាតព្វកិច្ចស្មោះត្រង់ និង កាតព្វកិច្ចជួយសង្គ្រោះគ្នាទៅវិញទៅមកដូចអាពាហ៍ពិពាហ៍ទេ។

២- តើកាតព្វកិច្ចដែលកើតចេញពីអាពាហ៍ពិពាហ៍?

អាពាហ៍ពិពាហ៍តាមច្បាប់បង្កើតអាណត្តិភាពជាកាតព្វកិច្ចទៅដល់សហព័ទ្ធទាំងសងខាងដែលមានដូចជា កាតព្វកិច្ចរួមរស់នៅជាមួយគ្នា កាតព្វកិច្ចសហការ និង កាតព្វកិច្ចសង្គ្រោះគ្នាទៅវិញទៅមក[28] ។ តាមពិតទៅ កាតព្វកិច្ចស្មោះត្រង់ជាកាតព្វកិច្ចសំខាន់មួយផងដែរនៅក្នុងទំនាក់ទំនងនៃអាពាហ៍ពិពាហ៍ ព្រោះថាការអនុវត្តកិច្ចសន្យាអាពាហ៍ពិពាហ៍តម្រូវឲ្យគូភាគីអនុវត្តកាតព្វកិច្ចរៀងៗខ្លួនដោយស្មោះត្រង់ និង សុចរិត[29]។

---

28 ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៦ *ករណីកិច្ចរួមរស់នៅជាមួយគ្នា សហការ និង សង្គ្រោះគ្នាទៅវិញទៅមក*។

29 ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ លេខ នស/រកម/០២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៥ *គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់៖ ការប្រើសិទ្ធិ និងការអនុវត្តករណីយកិច្ច ត្រូវធ្វើឡើងដោយសុចរិត ផ្អែកតាមភាពស្មោះត្រង់*។

www.elibraryofcambodia.org
Scanned with CamScanner

ករណីយកិច្ចរួមរស់នៅជាមួយគ្នា សំដៅទៅដល់ករណីយកិច្ចនៃសហព័ទ្ធក្នុងការមានទំនាក់ទំនងផ្លូវភេទជាមួយគ្នា និងដោយសារការភ្ជាប់ជាមួយនូវគោលការណ៍នៃភាពផ្តាច់មុខក្នុងទំនាក់ទំនងរបស់ពួកគេ បង្កើតបានជាសច្ចធារណ៍នៃបិតុភាព[30]។

ករណីយកិច្ចសហការ សំដៅទៅដល់ការបំពេញបេសកកម្មរបស់ប្តី និងប្រពន្ធ ដែលមានតួនាទីរៀងៗខ្លួន និង បំពេញឲ្យគ្នាទៅវិញទៅមក ហើយដែលត្រូវអនុវត្តរួមគ្នា និងស្មើភាពគ្នា ក្នុងការដឹកនាំគ្រួសារ និងការអប់រំកូន។ ជាក់ស្តែង គឺការអនុវត្តអំណាចមេបារបស់ឪពុក ឬម្តាយ ទៅលើកូនរបស់ខ្លួន។

ករណីយកិច្ចសង្គ្រោះគ្នាទៅវិញទៅមក សំដៅទៅដល់ករណីយកិច្ចជួយគ្នារវាងប្តី ប្រពន្ធ ក្នុងផ្លូវសម្ភារៈ និងផ្លូវចិត្ត នៅក្នុងការរស់នៅប្រចាំថ្ងៃ (គេហកិច្ចការថែទាំគ្នាពេលមានជម្ងឺ -ល-)។ អាហារកាតព្វកិច្ចគឺជាឧទាហរណ៍ស្រាប់នៃករណីយកិច្ចនេះ។

រីឯករណីយកិច្ចស្មោះត្រង់ ឈរលើគោលគំនិតថាអាពាហ៍ពិពាហ៍គឺមិនមែនជាការសន្យាក្នុងការស្រលាញ់នោះទេ តែជាការសន្យាក្នុងការថែរក្សានូវជំនឿទុកចិត្តរវាងប្តី ប្រពន្ធ។ អ្វីដែលមានអាទិភាពជាងគេនៅក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍គឺ

30 Raymond Guillien et Jean Vincent, *LEXIQUE DES TERMES JURIDIQUES*, (Dalloz: 16ème édition 2007), page 127

www.elibraryofcambodia.org
Scanned with CamScanner

ការស្មោះត្រង់ផ្នែកអាទេ ដែលហាមឃាត់មិនឱ្យមានការផិតឡើយ[31] ។ ការមិនគោរពកាតព្វកិច្ចស្មោះត្រង់ អាចនឹងនាំឱ្យមានការដាក់ទណ្ឌកម្មផ្នែករដ្ឋប្បវេណី និងព្រហ្មទណ្ឌ។ នៅក្នុងទណ្ឌកម្មផ្នែករដ្ឋប្បវេណី អំពើផិតត្រូវបានចាត់ទុកជាមូលហេតុនៃការលែងលះដោយសារកំហុស[32] ដោយសារថាវាផ្ទុយនឹងគោលការណ៍ប្តីមួយប្រពន្ធមួយ (ឯកពន្ធភាព) [33]។ " *ត្រូវចាត់ទុកជាថានីត គឺការរួមសេវនកិច្ចរវាងបុរសដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬការរួមសេវនកិច្ចរវាងស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍មិនទាន់រលាយជាមួយបុរសដទៃក្រៅពីប្តីរបស់ខ្លួន* "[34]។ អំពើផិត ក៏ត្រូវទទួលទណ្ឌកម្មផ្នែកព្រហ្មទណ្ឌផងដែរ ដោយសារវាផ្ទុយនឹងគោលការណ៍ស្មោះត្រង់ ហើយដែលត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌ និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ដល់ ១ (មួយ) ឆ្នាំ និង ផ្តន្ទាទោសពិន័យជាប្រាក់ពី ២០០,០០០ (ពីររយពាន់) រៀល

---

31 Philippe MALAURIE, Hugues FULCHIRON, *LA FAMILLE*, (Editions juridiques associés: DEFRENOIS, 2006), p578, paragraphe 1473.

32 ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៨៧៨ កថាខណ្ឌទី១ ចំណុច ក *មូលហេតុនៃការលែងលះ*។

33 រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣, មាត្រា៤៥ កថាខណ្ឌទី៤៖ *អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និង តាមគោលការណ៍ស្ម័ត្រចិត្ត ប្តីមួយប្រពន្ធមួយ* ។

34 ច្បាប់ស្តីពីឯកពន្ធភាពដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១០០៦/០២៦ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦, មាត្រា៧

www.elibraryofcambodia.org
Scanned with CamScanner

ដល់ ១,០០០,០០០ (មួយលានរៀល) ឬ ផ្ដន្ទាទោសណាមួយនៃទោសទាំងពីរ [35]។ រីឯ "*ទ្វេពន្ធភាព គឺសំដៅដល់បុរស ឬស្ត្រីណាដែលមានចំណងអាពាហ៍ពិពាហ៍ពីមុន មិនទាន់រលាយនៅឡើយ រហើយទៅចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មីមួយទៀត*" [36] ហើយដែលត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌ និងត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ដល់ ១ (មួយ) ឆ្នាំ និងផ្ដន្ទាទោសពិន័យជាប្រាក់ពី ២០០,០០០ (ពីរសែនពាន់) រៀល ដល់ ១,០០០,០០០ (មួយលានរៀល) ឬផ្ដន្ទាទោសណាមួយនៃទោសទាំងពីរ[37]។ ផ្ទុយពីអាពាហ៍ពិពាហ៍ ក្នុងករណីអនីតិសង្វាស គេមិនឃើញមានបទប្បញ្ញត្តិព្រហ្មទណ្ឌ ឬ រដ្ឋប្បវេណីដែលចែងផ្ដន្ទាទោសដល់អនីតិសង្វាសជនណាអំពីភាពមិនស្មោះត្រង់នោះទេ[38] ។

អនីតិសង្វាសមិនបានបង្កើតឲ្យមានកាតព្វកិច្ចខាងលើទាំងនេះទេ ព្រោះថាកាតព្វកិច្ចខាងលើជាកាតព្វកិច្ចស៊ីវិល ដែលអាចត្រូវបានបង្កើតដោយច្បាប់តែប៉ុណ្ណោះ ហើយនេះក៏ជាព្រំដែនមួយច្បាស់លាស់រវាងអាពាហ៍ពិពាហ៍ និង

---

35 ច្បាប់ស្តីពីឯកពន្ធភាពដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១០០៦/០២៦ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦, មាត្រា១០។

36 ច្បាប់ស្តីពីឯកពន្ធភាពដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១០០៦/០២៦ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦, មាត្រា៤។

37 ច្បាប់ស្តីពីឯកពន្ធភាពដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១០០៦/០២៦ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦, មាត្រា៩។

38 Philippe MALAURIE, Hugues FULCHIRON, *LA FAMILLE*, (Editions juridiques associés DEFRENOIS, 2006), p162, paragraphe 321.

www.elibraryofcambodia.org

Scanned with CamScanner

អនីតិសង្វាសផងដែរ។ ដោយឡែក ស្ថានភាពដែលតុលាការទទួលស្គាល់នូវអត្ថិភាពនៃករណីយកិច្ចទាំងនេះនៅក្នុងអនីតិសង្វាស គឺហាក់ដូចជាកំពុងតែទទួលស្គាល់នូវករណីយកិច្ចផ្នែករដ្ឋប្បវេណីដែលកើតចេញពីអាពាហ៍ពិពាហ៍ចំពោះអនីតិសង្វាស។

៣- ការទទួលបានអត្ថាធិប្បាយ?

វាមានភាពច្បាស់លាស់ណាស់ដែលអនីតិសង្វាសមិនបានផ្តល់អត្ថាធិប្បាយដល់អនីតិជនអាយុចាប់ពី ១៦ ឆ្នាំ ដូចរឿងដែលក្រមរដ្ឋប្បវេណីបានបញ្ជាក់អំពីអានុភាពនៃអាពាហ៍ពិពាហ៍នោះទេ។ មាត្រា ៩៦៨ នៃក្រមរដ្ឋប្បវេណីកម្ពុជា សំដែង *"ប្រសិនបើអនីតិជនបានរៀបអាពាហ៍ពិពាហ៍ អនីតិជននោះត្រូវបានចាត់ទុកថាបានដល់នីតិភាពដោយអាពាហ៍ពិពាហ៍នោះ ក្នុងការអនុវត្តក្រមរដ្ឋប្បវេណីនេះ"*។ នៅប្រទេសជប៉ុន ការអនុវត្តអាចធ្វើឱ្យឋានៈភាគីនៃកិច្ចសន្យាស្ថិតក្នុងអស្ថេរភាព ហេតុនេះគេបកស្រាយថា មាត្រានេះមិនអនុវត្តន៍ចំពោះករណីអនីតិសង្វាសទេ[39]។

ចំណុចទី ២- ផ្នែកព្រហ្មទណ្ឌ

ខុសគ្នាពីអាពាហ៍ពិពាហ៍ដែលជាចំណងគតិយុត្តស៊ីវិល ហើយដែលបង្កើតបានជាសិទ្ធិពិសេសមួយចំនួនដល់សហព័ទ្ធជាប្តី ឬ ប្រពន្ធ ក្នុងវិស័យព្រហ្មទណ្ឌ

39 Ms. MIURA YASUKO, សាស្ត្រាចារ្យនៃវិទ្យាស្ថានស្រាវជ្រាវ និង បណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌, (២០១៣, សិក្ខាសិលាស្តីពីអនីតិសង្វាស និង សន្តតិកម្ម), *ស្តីពីអនីតិសង្វាស*, ទំព័រទី៣។

www.elibraryofcambodia.org
Scanned with CamScanner

អនីតិសង្វាសមិនបានផ្តល់នូវអ្វីដូចដែលអាជ្ញាធរបានផ្តល់នោះទេ។ លោក សាស្ត្រាចារ្យ ស៊ុម សុខម្ហ បានលើកឡើងថា "*វិធីបកស្រាយរបៀបសទិសវិធី ឬ តាមវិធីប្រដូចនេះ ត្រូវប្រើដោយប្រយ័ត្នប្រយែងបំផុតក្នុងរឿងព្រហ្មទណ្ឌ ដើម្បីធានាបាននូវការគោរពជាអាទិ៍ គោលការណ៍នីតិកុលភាពនៃបទល្មើស នីតិកុលភាពនៃទណ្ឌកម្ម និង គោលការណ៍បកស្រាយច្បាប់ចង្អៀត*" [40]។ មាត្រា ៥ នៃក្រមព្រហ្មទណ្ឌកម្ពុជា ថែមទាំងបានបញ្ញត្តិផងដែរថា " *ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយតឹងរឹង។ ទៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬ ប្រព្រឹត្តតាមសទិសភាពបានឡើយ*"។

១- អត្ថន័យឯកសិទ្ធិគ្រួសារក្នុងរឿងព្រហ្មទណ្ឌ (អំពើលួច)

"*បើទោះបីជាមានអំពើលួច ក៏ដោយ ក៏អត្ថន័យឯកសិទ្ធិគ្រួសារ បានផ្តល់ឱ្យចារីនូវការរួចផុតពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ បើកាលណាអំពើលួចនោះប្រព្រឹត្តឡើង ទៅលើទ្រព្យសម្បត្តិរបស់សហព័ន្ធជន*" [41]។ ដោយសារថា ក្នុងរឿង

---

40 សាស្ត្រាចារ្យ ស៊ុម សុខម្ហ, *បទប្បកទេស និង វិធីសាស្ត្របកស្រាយបទដ្ឋានគតិយុត្តនានា*, (រាជបណ្ឌិតសភាវិញ្ញាជីវៈតុលាការ, កញ្ញា ២០០៩), ទំព័រទី៦ ចំណុច ១-១- វិធីបកស្រាយ ឬធ្វើវិចារណកិច្ចតាមសទិសវិធី ឬតាមវិធីប្រដូច។

41 ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម ០១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៥ *អត្ថន័យឯកសិទ្ធិគ្រួសារ*

www.elibraryofcambodia.org
Scanned with CamScanner

ព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយតឹងរ៉ឹង ដើម្បីឲ្យចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្តន៍ ឬ ប្រព្រឹត្តតាមទិសភាពបានឡើយ [42] ដូច្នេះយើងអាចបកស្រាយបានថា ពាក្យ "*សហព័ទ្ធ*" ដែលចែងក្នុងមាត្រា ៣៥៥ ស្តីពីអភ័យឯកសិទ្ធិគ្រួសារ ក្នុងអំពើលួចនេះ ត្រូវបកស្រាយតឹងរ៉ឹង ពោលគឺជាសហព័ទ្ធដែលកើតចេញពីអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ ឬអាចនិយាយម្យ៉ាងទៀតបានថា មិនមែនជាសហព័ទ្ធជាអាពាហ៍ពិពាហ៍ដែលមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ (អនីតិសង្វាស)។

ហើយពាក្យថា "*ទ្រព្យសម្បត្តិ*" នៅទីនេះ អាចជាទ្រព្យសម្បត្តិរួម[43] ឬ ទ្រព្យសម្បត្តិដោយឡែក[44] ហើយអាចជាទ្រព្យសកម្ម ឬ ទ្រព្យអកម្ម។ ជាវិបាក

---

42 ក្រមព្រហ្មទណ្ឌ ដដែល, មាត្រា៥ *ការបកស្រាយច្បាប់ព្រហ្មទណ្ឌ*

43 ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៧៣ (ទ្រព្យសម្បត្តិរួម)៖ *ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយណា ដែល ប្តីប្រពន្ធទាំងសងខាង ឬ តែម្ខាងទទួលបានមកក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដែលកំណត់ទុកក្នុងចំណុច ខ និង ចំណុច ក ដែលមាត្រា ៩៧២ (ទ្រព្យសម្បត្តិដោយឡែក) ខាងលើនេះ។*

44 ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៧២ (ទ្រព្យសម្បត្តិដោយឡែក)៖ *ទ្រព្យសម្បត្តិដោយឡែកដែលកំណត់ដូចខាងក្រោមនេះ គឺជាទ្រព្យសម្បត្តិដោយឡែក ដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់សហព័ទ្ធណាម្នាក់៖*

ក. ទ្រព្យសម្បត្តិ ដែលសហព័ទ្ធមាន នៅមុនពេលរៀបអាពាហ៍ពិពាហ៍។

www.elibraryofcambodia.org
Scanned with CamScanner

អំពើលួចទ្រព្យសម្បត្តិរបស់អនីតិសង្វាសជនណាម្នាក់ ដោយអនីតិសង្វាសជនណាម្នាក់ទៀត ត្រូវចាត់ទុកជាអំពើលួច ហើយដែលមិនអាចទទួលបានខ្លួវអភ័យឯកសិទ្ធិគ្រួសារដូចមានចែងក្នុងកថាខណ្ឌទី២ នៃមាត្រា៣៥៥ នៃក្រមព្រហ្មទណ្ឌនោះទេ។ ម្យ៉ាងទៀត ទ្រព្យសម្បត្តិក្នុងចំណងអនីតិសង្វាសមិនមែនជាទ្រព្យសម្បត្តិដែលស្ថិតនៅក្នុងប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធនោះទេ ពោលគឺវាជាទ្រព្យសម្បត្តិនៅក្រោមរបបតតិយុត្តនៃកម្មសិទ្ធិអវិភាគ។ មានន័យថា បើសហព័ទ្ធណាម្នាក់លួចទ្រព្យសម្បត្តិរួម ឬ ទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធណាម្នាក់ទៀតនោះ វាជាអំពើលួច តែត្រូវរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ (ទទួលខុសត្រូវផ្នែករដ្ឋប្បវេណីនៅតែមាន បើសិនជាមានការទាមទារពីជនរងគ្រោះ) ដោយសារអភ័យឯកសិទ្ធិគ្រួសារ។ ផ្ទុយទៅវិញ បើអនីតិសង្វាសជនណាម្នាក់លួចទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់អនីតិសង្វាសជនណាម្នាក់ទៀត ឬ ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិអវិភាគនៃពួកគេទាំងពីរ ជនខាងដើមនេះត្រូវទទួលខុសត្រូវទាំងផ្នែកព្រហ្មទណ្ឌ និង ផ្នែករដ្ឋប្បវេណី បើសិនជាមានការទាមទារពីជនរងគ្រោះ ពីព្រោះថាអនីតិសង្វាសមិនបានបង្កើតជាអភ័យឯកសិទ្ធិគ្រួសារក្នុងរឿងព្រហ្មនោះទេ។

ខ- ទ្រព្យសម្បត្តិ ដែលសហព័ទ្ធទទួលបាន ដោយប្រទានកម្ម សន្តតិកម្ម អប្បិយទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។

គ- ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដែលបានកំណត់ក្នុងចំណុច ក និង ចំណុច ខ ខាងលើនេះ។

www.elibraryofcambodia.org
Scanned with CamScanner

២- បទល្មើសមានខែចក្ខុចប្បាប់ស្តីពីឯកតន្ធភាព

ដូចដែលយើងបានលើកឡើងខាងលើហើយថា "*ត្រូវចាត់ទុកជាថាធិត គឺ ការរួមរស់វន់កិច្ចរវាងបុរសដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ ជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬ ការរួមរស់វន់កិច្ចរវាងស្ត្រីដែលមានចំណង អាពាហ៍ពិពាហ៍មិនទាន់រលាយជាមួយបុរសដទៃក្រៅពីប្តីរបស់ខ្លួន*"[45]។ អំពើធិត ក៏ត្រូវទទួលទណ្ឌកម្មផ្នែកព្រហ្មទណ្ឌដោយសារវាផ្ទុយនឹងគោលការណ៍ស្មោះត្រង់។ រីឯ "*ទ្វេពន្ធភាព គឺសំដៅដល់បុរស ឬ ស្ត្រីណាដែលមានចំណងអាពាហ៍ពិពាហ៍ពីមុន មិនទាន់រលាយនៅឡើយ ហើយទៅចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មីមួយទៀត*"[46] ហើយ ដែលត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌ។ ហើយ "*ត្រូវចាត់ទុកថាសួន់ បុរស និង ស្ត្រីណាដែលជាប់ចំណងជាញាតិសោហិត ឬ ញាតិពន្ធនឹងគ្នា ហើយរួម រស់វន់កិច្ចជាមួយគ្នា*"[47]។

---

45 ច្បាប់ស្តីពីឯកតន្ធភាពដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១០០៦/០២៦ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦, មាត្រា៧។

46 ច្បាប់ស្តីពីឯកតន្ធភាពដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១០០៦/០២៦ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦, មាត្រា៤។

47 ច្បាប់ស្តីពីឯកតន្ធភាពដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១០០៦/០២៦ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦, មាត្រា៥ និង ៦។

www.elibraryofcambodia.org
Scanned with CamScanner

ដោយឡែកច្បាប់ស្តីពីឯកពន្ធភាពនេះត្រង់មាត្រា៨ បានផ្តល់សិទ្ធិពិសេសទៅដល់សហព័ន្ធស្នើសុំកុំឲ្យចោទប្រកាន់ទៅព្រះរាជអាជ្ញា ហើយក្នុងករណីនេះព្រះរាជអាជ្ញាអាចសម្រេចមិនធ្វើបណ្តឹងអាជ្ញាបាន[48] ប្រសិនបើមានបណ្តឹងរបស់សហព័ន្ធណាមួយស្នើសុំកុំឲ្យចោទប្រកាន់។ នេះគ្រាន់តែជាសិទ្ធិពិសេសមួយដែលទទួលស្គាល់តែចំពោះរវាងសហព័ន្ធនៅក្នុងបទផិតតែប៉ុណ្ណោះ[48]។

ដូចនេះ ច្បាប់ស្តីពីឯកពន្ធភាពមិនអនុវត្តន៍ទៅលើអនីតិសង្វាសជនឆ្លងទេ ដោយហេតុថាមាត្រា២ នៃច្បាប់នេះបានកំណត់អំពីវិសាលភាពនៃច្បាប់នេះដោយបញ្ជាក់ថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានចំណងអាពាហ៍ពិពាហ៍ ត្រូវគោរពគោលការណ៍ឯកពន្ធភាពដោយស្មគ្រចិត្ត ប្តីមួយប្រពន្ធមួយ ដោយមានចុះបញ្ជីអាពាហ៍ពិពាហ៍ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ។

---

48 ច្បាប់ស្តីពីឯកពន្ធភាពដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១០០៦/០២៦ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦, មាត្រា៨៖ *ក្នុងករណីដែលមានចែងក្នុងមាត្រា៧ ខាងលើ (អំពើផិត) ព្រះរាជអាជ្ញាអាចសម្រេចមិនធ្វើបណ្តឹងអាជ្ញាបាន ប្រសិនបើមានបណ្តឹងរបស់សហព័ន្ធណាមួយស្នើសុំកុំឲ្យចោទប្រកាន់។*

www.elibraryofcambodia.org
Scanned with CamScanner

ជាប្រត្យក្ស គេមិនឃើញមានបទប្បញ្ញត្តិព្រហ្មទណ្ឌ ឬ រដ្ឋប្បវេណី ផ្តន្ទាទោស ដល់អនីតិសង្វាសជនណាអំពីភាពមិនស្មោះត្រង់ចំពោះភាគីម្ខាងទៀតនោះទេ[49] ។

៣- បទល្មើសផ្សេងទៀត

ហិង្សាបង្កឡើងដោយអនីតិសង្វាសជន៖ ដូចដែលយើងបានលើកឡើងខាងលើហើយថា ច្បាប់កម្ពុជាមិនបានឲ្យនិយមន័យ និង របបគតិយុត្ត នៃអនីតិសង្វាសទេ តែបែរជាមានការទទួលស្គាល់នូវអត្ថិភាពនៃសញ្ញាណអនីតិសង្វាសក្នុងច្បាប់មួយចំនួន។ ក្រមព្រហ្មទណ្ឌកម្ពុជាត្រង់មាត្រា២២២ បានចែងផ្តន្ទាទោសអំពើហិង្សាប្រព្រឹត្តដោយសហព័ទ្ធ ឬ អនីតិសង្វាសជន។

ត្រង់នេះបញ្ជាក់តែច្បាស់ថា សហព័ទ្ធជាបុគ្គលដែលមានទំនាក់ទំនងគតិយុត្តកើតចេញពីអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ រីឯអនីតិសង្វាសជន គឺជាបុគ្គលដែលមានទំនាក់ទំនងក្រៅអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ ការបកស្រាយនេះស្របទៅនឹងវិធានៃការបកស្រាយច្បាប់ព្រហ្មទណ្ឌតឹងរឹង ដូចដែលយើងបានបរិយាយក្នុងចំណុចទី២ ខាងលើ។

49 Philippe MALAURIE, Hugues FULCHIRON, *LA FAMILLE*, (Editions juridiques associés: DEFRENOIS, 2006), p162, paragraphe 321.

www.elibraryofcambodia.org
Scanned with CamScanner

ការបំពានផ្នូរភេទរវាងអនីតិសង្វាសជន?៖ តាមច្បាប់កម្ពុជា ការបំពានផ្នូរភេទមានវិសាលភាពគ្របដណ្តប់ទៅលើគ្រប់ទំនាក់ទំនងបុគ្គល។ ច្បាស់ជាងនេះទៅទៀត សង្គមកម្ពុជានៅតែចាត់ទុកថាមានការបំពានផ្នូរភេទនៅក្នុងគ្រួសារ ទោះក្នុងរវាងសហព័ទ្ធទាំងពីរក្តី ឬ អនីតិសង្វាសជនទាំងពីរក្តី។ អំពើហិង្សាក្នុងគ្រួសារសំដៅផងដែរទៅដល់ការបំពានខាងផ្នូរភេទទៅលើភាគីម្ខាងទៀត ហើយវាមានរូបភាពជា ការរំលោភសេពសន្ថវៈ ការបៀតបៀនកេរ្តិ៍ឈ្មោះ និង ការធ្វើអាស្រូវភេទ[50]។

ជារួម ច្បាប់ស្តីពីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារអនីតិជនបានផ្តល់សិទ្ធិពិសេសមួយដល់ជនរងគ្រោះក្នុងការបង្កើតបណ្តឹងអាជ្ញា ដោយមាត្រា ៣៦ នៃច្បាប់នេះចែងថា៖ *"ការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌពុំអាចធ្វើបានឡើយ បើមានសំណើពីជនរងគ្រោះជានីតិជនដោយបទល្មើសនោះជាបទមជ្ឈិម ឬបទលហុ។ ក្នុងករណីដែលមានអំពើហិង្សាក្នុងគ្រួសារកើតឡើងជាថ្មីម្តងទៀតដែលល្មើសនឹងច្បាប់ព្រហ្មទណ្ឌ តុលាការត្រូវតែធ្វើការចោទប្រកាន់ជនមុខសញ្ញារួបនោះតាមនីតិវិធីព្រហ្មទណ្ឌ ទោះបីជាមានការស្នើសុំពីជនរងគ្រោះម្តងទៀតក៏ដោយ "*។

50 ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារអនីតិជន ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ លេខ នស/រកម/១០០៥/០៣១ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥, មាត្រា២, មាត្រា ៣ និង មាត្រា៧។

www.elibraryofcambodia.org
Scanned with CamScanner

ក្នុងករណីនេះ "អនីតិសង្វាស-ជនមិនអំនួនឯងជាទទួលបានផ្តួរសិទ្ធិពិសេសខាងលើនោះទេ ពីព្រោះថាអាត្រា២ នៃច្បាប់ដដែលបញ្ញត្តិថា *អំពើហិង្សាក្នុងគ្រួសារ គឺសំដៅលើអំពើហិង្សាដែលកើតមាន និង អាចកើតមានទៅលើ៖ ១ ប្តី ឬ ប្រពន្ធ ២ កូនក្នុងបន្ទុក ជនទាំងឡាយណារបស់នៅក្រោមដំបូលផ្ទះ និង ក្នុងបន្ទុក។* វិសាលភាពនៃបញ្ញត្តិនោះទំនងជាមិនអាចអនុវត្តនៅក្នុងករណីអនីតិសង្វាសដោយសារថាវាត្រូវបកស្រាយតឹងរឹង។ ទោះជាយ៉ាងណាក៏ដោយ ការបកស្រាយបញ្ញត្តិច្បាប់ខាងលើនេះនៅតែជាសមត្ថកិច្ច និងឥទ្ធានុសិទ្ធិរបស់តុលាការនៅពេលដោះស្រាយរឿងក្តីដែលប្តឹងមកខ្លួន។

កថាខណ្ឌទី ២- ចំពោះអ្នក

ចំណុចទី ១- អំណាចមេបា៖ ឆោល ឬ សហការ?

មានតែអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ទេដែលបានបង្កើតឱ្យមានអំណាចមេបាសហការ ដែលជាផ្នែកមួយនៃករណីយកិច្ចសហការគ្នារបស់សហព័ទ្ធ[51] ។ មាត្រា ១០៣៦ បញ្ញត្តិថា "*ពីពុកម្តាយដែលមានចំណងអាពាហ៍ពិពាហ៍ ត្រូវប្រើប្រាស់អំណាចមេបាដោយសហការគ្នា។ ប៉ុន្តែ បើពីពុក ឬ ម្តាយ ពុំអាចប្រើប្រាស់អំណាច*

51 ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៨៦ *ករណីយកិច្ចរួមរស់នឹងគ្នា សហការ និង សង្គ្រោះគ្នាទៅវិញទៅមក*។

www.elibraryofcambodia.org
Scanned with CamScanner

រមែចាបានទេ, ឪពុក ឬ ម្តាយម្នាងទៀតត្រូវប្តឹងរំលាចរមែចានោះ " ដូច្នេះតាមរយៈការបកស្រាយច្បាប់បែបបដិណាមវិធី នោះអនីតិសង្វាសមិនបង្កើតឲ្យមានអំណាចមេបាសហការ ឬអំណាចមេបារួមនោះទេ។ អំណាចមេបាទោលនេះ គឺមានភាពដូចគ្នាទៅនឹងករណីក្រោយការលែងលះគ្នា។ អំណាចមេបាសហការ ជាអនុភាពតតិយុត្តនៃអាពាហ៍ពិពាហ៍ មិនមែនជាអនុភាពរបស់អនីតិសង្វាសនោះទេ។ ដូច្នេះក្នុងអំឡុងពេលអត្ថិភាពរបស់ខ្លួន អនីតិសង្វាសបង្កើតឲ្យមានអ្នកមានអំណាចមេបា និង អ្នកគ្មានអំណាចមេបា។ ជាក់ស្តែង អំណាចមេបាដូចមានចែងនៅក្នុងមាត្រា១៨ (សិទ្ធិលុបចោលសកម្មភាព) មាត្រា១៩ (ការចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នករាណាព្យាបាលសម្រាប់អនីតិជនអនុញ្ញាតឲ្យចាត់ចែង) មាត្រា ២០ (អនីតិជនដែលត្រូវបានអនុញ្ញាតឲ្យប្រកបរបរជីវកម្ម) និង មាត្រា ៩៥៣ (ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន) នៃក្រមរដ្ឋប្បវេណី ជាអំណាចមេបាទោលប្រសិនជាឪពុកម្តាយរបស់អនីតិជននោះ ស្ថិតក្នុងចំណងអនីតិសង្វាស។ ដូចនេះគ្រាន់តែអ្នកមានអំណាចមេបាម្នាងណាយល់ព្រមទៅលើសកម្មភាពរបស់កូនជាអនីតិជន វាគឺជាការគ្រប់គ្រាន់។

ទោះជាយ៉ាងណាក៏ដោយ អ្នកដែលមានអំណាចមេបាត្រូវមានករណីយកិច្ចពិភាក្សាគ្នាជាមួយនឹងអ្នកដែលគ្មានអំណាចមេបាអំពីចំណុចសំខាន់ៗទាក់ទងទៅនឹងកូន។ មាត្រា១០៤២ (ក្នុងករណីលែងលះគ្នា) ចែងថា "*លើកដែលតែករណីដែល*

www.elibraryofcambodia.org
Scanned with CamScanner

មានភាពចាំបាច់បង្ខាប់ អ្នកដែលមានអំណាចមេបា ត្រូវពិភាក្សាជាមួយនឹងពុក ឬ ម្តាយ ដែលពុំមានអំណាចមេបា អំពីចំណុចដែលទាក់ទងទៅកូន ដូចមានកំណត់ខាងក្រោម៖ ក- ការអប់រំកូន ដែលហួសពីកម្រិតនៃកាតព្វកិច្ចអប់រំដែលជាករណីយកិច្ចកំណត់ដោយច្បាប់។ ខ- ការផ្លាស់ប្តូរទីសំណាក់របស់កូនពី រាជធានី ខេត្តមួយ ទៅរាជធានី ខេត្តមួយទៀត។ គ- វិជ្ជាជីវៈ ឬ អាជីវកម្មរបស់កូន។ ឃ- ការចាត់ចែងទ្រព្យសម្បត្តិសំខាន់របស់កូន។ ង- ចំណុចសំខាន់ៗផ្សេងទៀត ដែលទាក់ទងទៅនឹងការគ្រប់គ្រងថែរក្សាកូន និង ទ្រព្យសម្បត្តិរបស់កូន"។ ក្នុងករណីនេះ បើសិនជាការពិភាក្សាគ្នាមិនបានសម្រេចទេ នោះឆន្ទៈរបស់អ្នកមានអំណាចមេបាត្រូវមានអាទិភាព[52]។

ហេតុដូច្នេះ មានតែឪពុក ឬ ម្តាយតែម្ខាងទេ ដែលមានអំណាចមេបាលើកូន ហើយជាអំណាចមេបាទោលទៀតផង ដូចគ្នាក្នុងករណីលែងលះគ្នាដែរ ព្រោះមិនមានអត្ថិភាពនៃចំណងអាពាហ៍ពិពាហ៍នោះទេ[53]។ កាន់តែប្រត្បិតប្រត្បង ស្ថានភាពពីរដែល

---

52 សេង ឌីណា, *ការចិញ្ចឹងពីច្បាប់, ក្នុងករណីពុកម្តាយលែងលះគ្នា តើកូនត្រូវបានទៅនៅជាមួយណាជាអ្នកគ្រប់គ្រង?*, ផ្សាយថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៣ តាមរយៈ: WWW.khmer.rfi.fr

53 ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, អត្ថាទ១០៣៨ *ការសម្រេចអំពីអំណាចមេបា នៅពេលលែងលះគ្នា*

www.elibraryofcambodia.org
Scanned with CamScanner

មានភាពស្រដៀងគ្នារាល់ចស្ថិតនៅក្រោមរបប៉ប៉តិយុត្តតែមួយ ដែលនេះជាខ្លឹមសារនៃគោលការណ៍នៃការរើសអើង (le principe de la non-discrimination)។

ចំណុចទី ២- បុគ្គភាព

បុគ្គភាពនៅទីនេះ គឺសំដៅដល់បុគ្គភាពតាមផ្លូវច្បាប់ គោលគឺមានការចុះអត្រានុកូលដ្ឋាន ឬមានសេចក្តីសម្រេចរបស់តុលាការ (សាលក្រម សាលដីកា ឬសេចក្តីសម្រេច)។ វាជាចំណងស៊ីវិលចងភ្ជាប់អនីតិសង្វាសជនណាម្នាក់ទៅនឹងកូន។

បុគ្គភាពនៅក្នុងករណីអនីតិសង្វាស កើតឡើងតាមរយៈបីករណីដូចតទៅ៖ ទី១ មាតុភាព និង បណ្តឹងទាមទារឱ្យបញ្ជាក់អត្ថិភាពនៃមាតុភាព (ពីកូន ឬ ពីម្តាយ ទី២ ការសន្មតបិតុភាព និង ទី៣ ការទទួលស្គាល់ (តាមរយៈមន្ត្រីអត្រានុកូលដ្ឋាន ឬតាមមតកសាសន៍) និង បណ្តឹងទាមទារឱ្យទទួលស្គាល់។

ផ្នែកទី ២- អនុគាតផ្នែកទ្រព្យសម្បត្តិ (ផ្នែករបបិតិកតណ្ឌ)

អថាខណ្ឌទី ១- របបមាតិកតណ្ឌ?

www.elibraryofcambodia.org
Scanned with CamScanner

ពាក្យថា *របបមាតិកភណ្ឌ* [54] កើតមានតែក្នុងករណីមានអាពាហ៍ពិពាហ៍តាមផ្នូវច្បាប់តែប៉ុណ្ណោះ។ ផ្ទុយទៅវិញ អនីតិសង្វាសមិនបង្កើតរបបមាតិកភណ្ឌឬប្រពន្ធទ្រព្យសម្បត្តិរួមប្តីប្រពន្ធនោះទេ។

ដើម្បីគាំទ្រការអះអាងខាងលើ យើងត្រូវឆ្លើយទៅនឹងសំណួរថា ប្រសិនបើយើងទទួលស្គាល់ថាមានរបបទ្រព្យសម្បត្តិរួមប្តីប្រពន្ធដែលកំណត់ដោយច្បាប់រវាងអនីតិសង្វាសជន ថាតើអនីតិសង្វាសជនទាំងពីរអាចបង្កើតប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា ដូចមានចែងក្នុងមាត្រា ៩៦៩ និង ៩៧០ នៃក្រមរដ្ឋប្បវេណី បានដែរឬទេ។ តាមពិតទៅ ដើម្បីអាចបង្កើតឲ្យមានប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា ទាមទារឲ្យមានទ្វបុរេលក្ខខណ្ឌមួយសំខាន់ជាងគេ គឺអត្ថិភាពនៃអាពាហ៍ពិពាហ៍។ ដូចនេះ តាមការបកស្រាយបញ្ញត្តិនេះ ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា មិនអាចកើតឡើងរវាងអនីតិសង្វាសបានឡើយ។ តាមរយៈការបកស្រាយច្បាប់តាមអនុលោមវិធី ឬវិធីពន្លាតន័យ (raisonnement *a fortiori*) បើប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យាមិន

---

54 ពាក្យថា *របបមាតិកភណ្ឌ* ដែលភាសាចារឹងគេហៅថា **le régime matrimonial** ដែលមានន័យថា៖ *ជាបណ្តុំវិធានផ្នែករបបតិកភណ្ឌនៅអំឡុងពេលអាពាហ៍ពិពាហ៍ ឬក្រោយការរលាយវិនាសអាពាហ៍ពិពាហ៍ ដែលចែងអំពីទ្រព្យសម្បត្តិរបស់សហព័ន្ធ (ការទាត់ចែង ការប្រើប្រាស់ និង ការគ្រប់គ្រងថែរក្សា) និង អំពីបញ្ហាសាច់ញាតិរវាងអាពាហ៍ពិពាហ៍ ទាំងនៅក្នុងទំនាក់ទំនងរវាងសហព័ន្ធទាំងពីរ និង រវាងសហព័ន្ធទាំងពីរជាមួយនឹងតតិយជន។* សូមមើល Gérald Cornu, Association Henri Capitant, *Vocabulaire juridique* (7ème Edition puf, 2005), page 772។ ជាភាសាអង់គ្លេស គេហៅថា **marriage settlement** (WWW.oxforddictionaries.com , Jan 20, 2014)។

www.elibraryofcambodia.org
Scanned with CamScanner

អាចកើតឡើង ឯនោះប្រព័ន្ធទ្រព្យសម្បត្តិរួមប្តីប្រពន្ធក៏មិនអាចកើតឡើងបានផងដែរ។ ដូចនេះ អនីតិសង្វាសមិនបង្កើតរបបមាតិកភណ្ឌនោះទេ។ ក៏ប៉ុន្តែ វានៅតែមានរបបគតិយុត្តផ្នែកទ្រព្យសម្បត្តិរបស់វាផ្ទាល់ផងដែរ។

ជាដំបូង ទ្រព្យសម្បត្តិរបស់អនីតិសង្វាសជននីមួយៗ ត្រូវបានកំណត់ដោយ *គោលការណ៍ខ្លួនទីពីងខ្លួន* ឬ *សក់អ្នកណា ក្បាលអ្នកហ្នឹង* (Chacun pour soi)។ អនីតិសង្វាសជនម្នាក់ៗ នៅតែជាកម្មសិទ្ធិករនៃទ្រព្យសម្បត្តិដែលខ្លួនមាននៅមុនពេលដែលមានការរួមរស់នៅជាមួយគ្នា ឬ ការដាក់បញ្ចូលគ្នា។ ក្នុងអំឡុងពេលរួមរស់នៅជាមួយគ្នា ម្នាក់ៗទទួលបានទ្រព្យសម្បត្តិរៀងៗខ្លួន។ តែប្រសិនបើគេមិនអាចធ្វើការបែងចែកបានថាទ្រព្យណាមួយជារបស់អ្នកណាទេនោះ ទ្រព្យទាំងនោះគួរតែត្រូវបានគេសន្មតថាជាទ្រព្យកម្មសិទ្ធិរវិភាគ[55]។ របបនៃកម្មសិទ្ធិរវិភាគលើទ្រព្យសម្បត្តិរវាងអនីតិសង្វាសជនក៏ត្រូវបានសាលាដំបូងខេត្តព្រះសីហនុធ្លាប់ទទួលស្គាល់ និង យកមកធ្វើការបែងចែកទ្រព្យសម្បត្តិរវាងពួកគេដែរ[56]។ ក៏ប៉ុន្តែ ក្នុងស្ថានភាព

---

55 Philippe MALAURIE, Hugues FULCHIRON, *LA FAMILLE*, (Editions juridiques associés DEFRENOIS, 2006), p162, paragraphe 323.

56 សូមមើលឧបសម្ព័ន្ធទី១ ៖ សាលាដំបូងខេត្តព្រះសីហនុ, *សាលក្រមលេខ ២៧ ច ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៤, សំណុំរឿងរដ្ឋប្បវេណីលេខ ១៤១ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៣,* សំអាងហេតុចំណុចទី៣ (ការបែងចែកទ្រព្យសម្បត្តិរអនីតិសង្វាសជន)។

www.elibraryofcambodia.org
Scanned with CamScanner

ខ្លះ សាលាដំបូងខេត្តព្រះសីហនុ បានទទួលស្គាល់ថាអធិតិសង្ខាសបង្កើតឲ្យមានរបប
ទ្រព្យសម្បត្តិរួមប្តីប្រពន្ធដែលកំណត់ដោយច្បាប់[57]។

ឱឃាយអំពីការគ្រប់គ្រង និងថែរក្សាទ្រព្យសម្បត្តិអវិភាគរបស់ពួកគេវិញ
ក្នុងករណីដែលមិនមានការព្រមព្រៀងគ្នាទៅលើការគ្រប់គ្រង និងថែរក្សាទ្រព្យនោះ
ទេ ជាគោលការណ៍បញ្ញត្តិស្តីពីកម្មសិទ្ធិអវិភាគ ត្រូវយកមកអនុវត្តន៍។

ក្នុងការអនុវត្តជាក់ស្តែងនៅមន្ទីរអៀបចំដែនដី នគរូបនីយកម្ម សំណង់ និង
សុរិយោដី (*ស្ថាប័ន ដ.ន.ស.ស.*) ខេត្តព្រះសីហនុ ទោះបីជាប្តីប្រពន្ធគ្មានចុះសំបុត្រ
អាពាហ៍ពិពាហ៍ក្តី ក៏នៅក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុបានសរសេរថា
ជាទ្រព្យរួមប្តីប្រពន្ធ[58]។ ក៏ប៉ុន្តែសំណួរចោទឡើងថាតើបញ្ញត្តិស្តីពីរបបទ្រព្យសម្បត្តិ
រួមប្តីប្រពន្ធដែលកំណត់ក្នុងក្រមរដ្ឋប្បវេណីថ្មី អាចយកមកអនុវត្តន៍បានដែរឬទេ? បើ
បានយកត្រឹមកម្រិតណា? ពិតណាស់ កម្មសិទ្ធិអវិភាគ និងរបបទ្រព្យសម្បត្តិរួមប្តី
ប្រពន្ធ មានរបបគតិយុត្តមិនដូចគ្នានោះទេ។ បើយើងយកបញ្ញត្តិស្តីអំពីទ្រព្យរួមមក
អនុវត្តនៅក្នុងរឿងអធិតិសង្ខាស វាបង្កជាបញ្ហាដោយសារថាបើក្នុងករណីដែល
អធិតិសង្ខាសជនណាម្នាក់ទៅមានចំណែងអធិតិសង្ខាសជាមួយនឹងតតិយជនផ្សេង

57 សូមមើលនៅបន្ទាប់ទំព័រ៖ សាលាដំបូងខេត្តព្រះសីហនុ, *សាលក្រមលេខ ០៩ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤, សំណុំរឿងរដ្ឋប្បវេណីលេខ ១៩១ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១*។

58 សូមមើលនៅបន្ទាប់ទំព័រ៖ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ។

www.elibraryofcambodia.org
Scanned with CamScanner

ទៀត ថាតើវាបង្កើតឲ្យមានរបបទ្រព្យរួមមួយទៀតដែរឬយ៉ាងណា ពីព្រោះថា អនីតិសង្វាសជនមិនគោរពតាមគោលការណ៍ឯកពន្ធភាព (ប្តីមួយប្រពន្ធមួយ) នោះទេ។ បើសិនបុគ្គលម្នាក់មានចំណងអនីតិសង្វាសច្រើនក្នុងពេលតែមួយ តើគ្រប់ចំណងនោះ វាសុទ្ធតែមានរបបទ្រព្យសម្បត្តិរួមប្តីប្រពន្ធដែរឬទេ? ជានេះបញ្ហាដែលចោទឡើង។ ក៏ប៉ុន្តែ តាមវិធានបកស្រាយច្បាប់មានលក្ខណៈជាប្រព័ន្ធ ឈរលើរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ច្បាប់ស្តីពីឯកពន្ធភាព និងក្រមរដ្ឋប្បវេណីថ្មី ដោយសារថាកម្ពុជាប្រកាន់គោលការណ៍ប្តីមួយប្រពន្ធមួយ ដូចនេះ របបទ្រព្យសម្បត្តិរួមប្តីប្រពន្ធសម្រាប់បុគ្គលម្នាក់មានតែមួយគត់។ ដូចនេះ គេមិនអាចយកបញ្ញត្តិស្តីពីទ្រព្យសម្បត្តិរួមប្តីប្រពន្ធទៅអនុវត្តនៅក្នុងរឿងក្តីអនីតិសង្វាសបាននោះទេ ឧទាហរណ៍ មាត្រា៩៧៤ (ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ) មាត្រា៩៧៥ ការទទួលខុសត្រូវដោយសាមគ្គីភាពចំពោះកាតព្វកិច្ច និងមាត្រា៩៧៦ (ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ)។

មិនតែប៉ុណ្ណោះ បើសិនជាតុលាការទទួលស្គាល់ថាមានអនីតិសង្វាសជនទាំងពីរមានរបបទ្រព្យសម្បត្តិរួមប្តីប្រពន្ធជាមួយគ្នា នោះមានន័យថា ភាគីទាំងសងខាងក៏មានទ្រព្យសម្បត្តិដោយឡែក ដូចមានចែងក្នុងមាត្រា៩៧២ នៃក្រមដែរ។ អាចនិយាយបានថា បញ្ញត្តិស្តីពីទ្រព្យសម្បត្តិដោយឡែកក៏ត្រូវយកមកអនុវត្តន៍ដែរ តួយ៉ាងមាត្រា៩៧៧ ដែលចែងអំពីការអាស្រ័យនៅដោយសហព័ទ្ធណាម្ខាងលើអចលនៈ

www.elibraryofcambodia.org
Scanned with CamScanner

ទ្រព្យដោយឡែកសហព័ទ្ធម្ខាងទៀត ទោះបីជាអចលនទ្រព្យនោះត្រូវបានចាត់ចែងហើយក៏ដោយ។

បញ្ហាមួយទៀតដែលចោទឡើងនោះ គឺនៅពេលមានបណ្តឹងផ្តាច់អនីតិ-សង្វាស តុលាការបានយករបបទ្រព្យសម្បត្តិរួមប្តីប្រពន្ធមកធ្វើជាមូលដ្ឋានក្នុងការវិនិច្ឆ័យសេចក្តី ផ្ទុយទៅវិញនៅក្នុងអំឡុងពេលនៃការប្រព្រឹត្តទៅរបស់អនីតិសង្វាស តើតុលាការអាចយករបបទ្រព្យសម្បត្តិរួមប្តីប្រពន្ធទៅធ្វើជាមូលដ្ឋានក្នុងការសម្រេចអំពីវិវាទលើការគ្រប់គ្រង និងការថែរក្សាទ្រព្យសម្បត្តិ ព្រមទាំងការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធរវាងអនីតិសង្វាសជនបានដែរឬយ៉ាងណា។

អនុលោមតាមមាត្រា ៩៧១ នៃក្រមរដ្ឋប្បវេណីនោះទេ ដែលបានសំដែងថា "*ប្តី ប្រពន្ធត្រូវមានចំណែកបន្ទុកលើសោហ៊ុយដែលកើតចេញពីអាពាហ៍ពិពាហ៍ដោយពិចារណាទៅលើទ្រព្យសម្បត្តិ ប្រាក់ចំណូល និងស្ថានភាពផ្សេងៗទៀត* (ផ្នែកមួយនៃអនុភាពនៃអាពាហ៍ពិពាហ៍)" នោះអនីតិសង្វាសជនមិនមានកាតព្វកិច្ចទាក់ទងនឹងបន្ទុកសោហ៊ុយអាពាហ៍ពិពាហ៍។ តែការយកបទប្បញ្ញត្តិមាត្រា៩៧១ នៃក្រមខាងលើមកអនុវត្តក្នុងករណីនេះ នឹងបំពានទៅលើប្រយោជន៍របស់កូន។ ជាដំណោះស្រាយ កថាខណ្ឌទី៣ មាត្រា១០៤០ នៃក្រមដដែល សំដែងថា"*ឪពុកដែលមិនបានរស់ជាមួយកូនដែលបានទទួលស្គាល់ អាចពិភាក្សា និងកំណត់ជាមួយម្តាយអំពីរបៀបជួបប្រាស្រ័យទាក់ទង និងសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់*

www.elibraryofcambodia.org
Scanned with CamScanner

គ្រងថែរក្សាកូន"។ បុគ្គភាពរវាងកូនទៅនឹងឪពុកឬម្តាយគឺជាលក្ខខណ្ឌជាសារវន្ត ដំបូងបំផុតក្នុងការអនុវត្តបទប្បញ្ញត្តិនេះ។ "*ក្នុងករណីមិនមានពុំបានសម្រេច ឬ បើពុំអាចធ្វើការពិភាក្សាបានទេ ការចូលខ្លួនអន្តរាគមន៍របស់តុលាការគឺជាការចាំបាច់ក្នុងការកំណត់ និងផ្តាស់ប្តូរសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន ដោយយកប្រយោជន៍របស់កូនជាអាទិភាព និងដោយពិចារណាទៅលើស្ថានភាពនៃជីវភាព និងស្ថានភាពសេដ្ឋកិច្ចរបស់ឪពុកម្តាយ*"[59]។

ដោយឡែក បើគិតទៅតាមភាពសមហេតុសមផល បំណុលដែលធ្វើឡើងដោយអនីតិសង្វាសជនណាម្នាក់ដើម្បីបន្ទុកគ្រួសារ ឬ ការរស់វត្ថុនរបស់ឪពុកគេ ត្រូវចាត់ទុកថាជាបំណុលផ្ទាល់ខ្លួន ពោលគឺគ្មានអនុភាពគតិយុត្តទៅលើអនីតិសង្វាសជនម្ខាងទៀតនោះទេ។ តែបើជាប្តី ប្រពន្ធក្នុងចំណងអាពាហ៍ពិពាហ៍ របបគតិយុត្តនៃកាតព្វកិច្ចដោយសាមគ្គីត្រូវយកមកអនុវត្តដូចមានចែងក្នុងមាត្រា៩២១ ដល់មាត្រា ៩៣៥ នៃក្រមរដ្ឋប្បវេណី។ ក៏ប៉ុន្តែ ក្នុងករណីមួយចំនួនបំណុលដែលធ្វើឡើងដោយអនីតិសង្វាសជនណាម្នាក់ ក្នុងគោលដៅដើម្បីបន្ទុកសោហ៊ុយគ្រួសារ អាចក្លាយជា

---

[59] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា១០៤០ កថាខណ្ឌទី៤ ដល់ទី៧។

www.elibraryofcambodia.org
Scanned with CamScanner

កាតព្វកិច្ចដោយសាមគ្គីបាន។ ក្នុងករណីនេះ កាតព្វកិច្ចដោយសាមគ្គីនេះ ឈរលើមូលដ្ឋានដោយជាក់លាក់ ឬ ដោយតុល្យភាព[60]។

អថាខណ្ឌទី ២- រដ្ឋការកាតព្វកិច្ច ឬ រដ្ឋការកិច្ច

ជាទូទៅ នៅពេលដែលមានការផ្តាច់អនីតិសង្វាស អនីតិសង្វាសជន ឬ អនីតិសង្វាសនី តែងតែទាមទារអាហារកាតព្វកិច្ចពីភាគីម្ខាងទៀតដើម្បីជាផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ដើម្បីជាប្រយោជន៍របស់កូន ក៏ព្រោះតែគេយល់ថាពួកគេគឺជាប្តីប្រពន្ធ។ ក្នុងទ្រឹស្តីនៃទីតិគ្រួសារ អាហារកាតព្វកិច្ចរវាងប្តីប្រពន្ធកើតឡើងតែក្នុងករណីមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់តែប៉ុណ្ណោះ។ មាត្រា ៧៦ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារដែលនៅជាធរមាននៅឡើយ ទទួលស្គាល់ការទាមទារអាហារកិច្ចបានតែក្នុងករណីមានការលែងលះតែប៉ុណ្ណោះ មានន័យថាត្រូវមានចំណងអាពាហ៍ពិពាហ៍។ រីឯនៅក្នុងក្រមរដ្ឋប្បវេណីវិញមាត្រា១១៤០ បានទទួលស្គាល់អាហារកាតព្វកិច្ចនៅរវាងញាតិតែប៉ុណ្ណោះ។

នៅក្នុងនីតិវិធីនៃសាលាឃុំ ឬ សង្កាត់ មេឃុំ ឬ ចៅសង្កាត់បានសម្រេចឱ្យមានការលែងលះគ្នាចំពោះបុគ្គលដែលស្ថិតនៅក្នុងចំណងអនីតិសង្វាស[61] ហើយ

60 ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៤២២ (ការបង្កើតកាតព្វកិច្ចដោយសាមគ្គី)

www.elibraryofcambodia.org
Scanned with CamScanner

សម្រេចឲ្យមានភាវប្រគល់អំណាចមេបាទៅឱ្យម្តាយតាមការទាមទាររបស់ម្តាយ និងជាងនេះទៅទៀត ថែមទាំងសម្រេចអំពីអាហារកិច្ចចិញ្ចឹមកូនជាបន្ទុករបស់អនីតិសង្វាសជនជាបុរស។ ពិតណាស់តួនាទីរបស់មេឃុំ ចៅសង្កាត់ពិតជាដើរតួនាទីសំខាន់ក្នុងការផ្សះផ្សាគូវិវាទ[62] ក៏ប៉ុន្តែ អ្វីដែលមេឃុំ ចៅសង្កាត់ធ្វើ គឺជាការបង្កើតកាតព្វកិច្ចផ្លូវច្បាប់ដែលច្បាប់មិនមានបញ្ញត្តិទាល់តែសោះ។ ប៉ុន្តែ អាហារកិច្ច ឬអាហារកាតព្វកិច្ចដែលដើមចោទបានទាមទារដើម្បីចិញ្ចឹមកូននោះ មិនខុសច្បាប់នោះទេ ព្រោះថាឪពុកម្តាយមានអាហារកាតព្វកិច្ចចិញ្ចឹមកូនរបស់ខ្លួន ទោះជាកូននោះជាអនីតិជន ឬអនីតិជនក៏ដោយ[63] (កូនដែលបានចុះក្នុងសំបុត្រកំណើតមានឪពុក និង

61 សំណុំរឿងរដ្ឋប្បវេណីលេខ ៦៣ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៩ ដែលហានកម្មវត្ថុផ្តាច់អនីតិសង្វាស សុំសិទ្ធិត្រប់ត្រងកូន និង ទាមទារអាហារកិច្ចចិញ្ចឹមកូន។

62 ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៨២ (*ប្រព្រឹត្តិអំពើប៉ះពាល់ដល់ភាព*) កថាខណ្ឌទី ២។

63 ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា១១៤០ *ទំហំ និង លំដាប់នៃជនដែលមានការណីយកិច្ចត្រូវផ្តល់អាហារកាតព្វកិច្ច* ។

www.elibraryofcambodia.org
Scanned with CamScanner

ម្ដាយស្ថិតក្នុងចំណងអនីតិសង្វាស) ឈើកឡែងតែអាហារកាតព្វកិច្ចដែលអនីតិសង្វាសជនណាម្នាក់ទាមទារជាប្រយោជន៍ផ្ទាល់ខ្លួន [64]។

ជាទូទៅគ្នាគឺតែងតែយល់ស្របគ្នាថា កូននេះជារបស់ពួកគេក្នុងចំណងអនីតិសង្វាស ដូច្នេះទៅក្រមមិនចាំបាច់ត្រូវការបញ្ជាក់ដោយភស្តុតាងអ្វេះទេ[65]។ ផ្ទុយទៅវិញ ការទទួលស្គាល់តែប៉ុណ្ណឹងមិនគ្រប់គ្រាន់ទេ ចាំបាច់ត្រូវមានសំបុត្រអត្រានុក្កូលដ្ឋាន (សំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើត) ទើបអាចបញ្ជាក់អំពីចំណងស៊ីវិលរបស់ ឪពុក ឬ ម្ដាយ ជាមួយនឹងកូនបាន។

---

64 ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ លេខ ៥៦ក្រ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៩, មាត្រា៧៦ (នៅជាធរមាន)៖

ក្នុងករណីដែលឪពុកម្ដាយលះគ្នា ភាគីដែលគ្មានកំហុស បើឈ្លះមាត អាចស្នើសុំអាហារកិច្ចពីភាគីម្ខាងទៀតបាន។ ភាគីខាងក្រោយនេះត្រូវតែជួយឧបត្ថម្ភទៅតាមលទ្ធភាពរបស់ខ្លួន។

កំរិតអាហារកិច្ចត្រូវសម្រេចទៅតាមការយល់ព្រមរបស់ភ្នាគីទាំងសងខាង។

ក្នុងករណីដែលភ្នាគីទាំងសងខាងមិនឯកភាពគ្នា តុលាការប្រជាជនត្រូវសម្រេចសេចក្ដី។ បើជនដែលទទួលអាហារកិច្ចរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ជនោះឈប់មានសិទ្ធិទទួលអាហារកិច្ចទៀតហើយ។

65 ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា១២៣ (*តម្រូវការណ៍ដែលការសម្រេចសេចក្ដីដោយភស្តុតាង*) កថាខណ្ឌទី២៖ *អង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខតុលាការ និង អង្គហេតុ [...]*។

www.elibraryofcambodia.org
Scanned with CamScanner

ក្នុងករណីផ្តាច់អនីតិសង្វាស បើសិនជាតុលាការទទួលស្គាល់អត្ថិភាពនៃអាហារកាតព្វកិច្ចរវាង អនីតិសង្វាសជនទាំងពីរនាក់នោះ គឺជាការយកបញ្ញត្តិស្តីពីអាពាហ៍ពិពាហ៍យកមកអនុវត្ត ពោលគឺទទួលស្គាល់គុណសម្បត្តិភាគីទាំងពីរជាសហព័ទ្ធដោយតុល្លភាព។ បញ្ហានឹងចោទឡើងនៅពេលដែល អនីតិសង្វាសជនណាម្នាក់មិនបានអនុវត្តតាមសេចក្តីសម្រេចរបស់តុលាការនៅក្រោយពេលផ្តាច់ចំណងនេះ ពីព្រោះថាការមិនអនុវត្តន៍នូវអាហារកិច្ច ឬអាហារកាតព្វកិច្ចគឺជាបទល្មើសព្រហ្មទណ្ឌថ្នាក់មជ្ឈឹម[66]។ ដូចនេះ តុលាការត្រូវតែបែងចែកឱ្យដាច់ស្រឡះរវាងអានុភាពនៃការលែងលះ និងការផ្តាច់អនីតិសង្វាស ព្រោះក្នុងករណីនេះ ការទទួលខុសត្រូវព្រហ្មទណ្ឌវា កើតឡើងពីសំណុំរឿងរដ្ឋប្បវេណីដោយមិនអាចបែងចែកឱ្យដាច់ពីគ្នាបាន។

បើយើងអនុញ្ញាតឱ្យមានអត្ថិភាពនៃអាហារកាតព្វកិច្ចនៅក្នុងចំណងអនីតិសង្វាស ហើយទទួលស្គាល់វានៅក្នុងរឿងព្រហ្មទណ្ឌ ឬ មិនទទួលស្គាល់វា នេះជា

---

[66] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម ០១០៩/០៣២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣២៩- *ការរោះបង់ក្រសារ៖ ការមិនគោរពតាមសេចក្តីសម្រេចស្តាពររបស់តុលាការ ដោយមិនក្រមបង់ក្នុងរយៈពេល ៣ (បី) ដែ ដាច់តិច នូវអាហារកាតព្វកិច្ចដល់សហព័ទ្ធ ឬ អតីតសហព័ទ្ធរបស់ខ្លួន ដល់ក្មួនជាអនីតិជន ដល់បង្កាញ្ញាតិ ឬ បុព្វញ្ញាតិ ផ្សេងទៀតរបស់ខ្លួនឯង ផ្តន្ទាទោសដាក់ពន្ធនាគារពី ០១ (មួយ) ដែ ទៅ ០១ (មួយ) ឆ្នាំ និង ពិន័យជាប្រាក់ពី ១០០,០០០ (មួយរយពាន់) រៀល ទៅ ២,០០០,០០០ (ពីរលាន) រៀល។*

www.elibraryofcambodia.org
Scanned with CamScanner

អសន្តិសុខគតិយុត្ត និង ធ្វើឱ្យអានុភាពនៃតារាល័ងលះ និង អានុភាពនៃអនីតិសង្វាស ដូចគ្នា។ និយាយឱ្យច្បាស់ជាងនេះគឺ បញ្ហាអត្ថិភាពនៃកាតព្វកិច្ចជួយសង្គ្រោះគ្នាទៅវិញទៅមកវាងអនីតិសង្វាសជនទាំងពីរដែលជាកាតព្វកិច្ចស៊ីវិល[67] កើតចេញពីអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ ក៏ប៉ុន្តែ បើសិនជាអនីតិសង្វាសជនណាម្នាក់ឃល់ព្រមតាមការទាមទារអាហារកាតព្វកិច្ចដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួនពីភាគីម្ខាងទៀត នោះដោយឈរទៅលើគោលការណ៍សេរីភាពក្នុងការចុះកិច្ចសន្យា វាក៏ក្លាយទៅជាកាតព្វកិច្ចស៊ីវិលផងដែរ តែការមិនគោរពកាតព្វកិច្ចបែបនេះមិនអាចបង្កើតជាបទល្មើសព្រហ្មទណ្ឌនោះទេ។

គថាខណ្ឌទី ៣- លំនៅដ្ឋានរបស់អនីតិសង្វាសជន

ដូចយើងបានបរិយាយខាងលើរួចមកហើយថា "*មន្ទីរ ស.ន.ស.ស. ទោះបីជាប្តីប្រពន្ធគ្មានចុះសំបុត្រអាពាហ៍ពិពាហ៍ក្តី ក៏នៅក្នុងប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុ*

---

67 Gérald Cornu, Association Henri Capitant, *Vocabulaire juridique* (7ème Édition puf, 2005), page154 et 596+ ***កាតព្វកិច្ចស៊ីវិល*** *ជាភាសាបារាំងគេហៅថា* **Obligation civile** *ជាកាតព្វកិច្ចដែលការអនុវត្តដោយបង្ខំរបស់វាអាចត្រូវបានទាមទារតាមផ្លូវតុលាការបាន ហើយខុសពីកាតព្វកិច្ចធម្មជាតិ (obligation naturelle)។* ***កាតព្វកិច្ចធម្មជាតិ*** *(obligation naturelle) ជាកាតព្វកិច្ចដែលការអនុវត្តដោយបង្ខំរបស់វាមិនបង្កើតឱ្យមានការទាមទារតាមផ្លូវតុលាការនោះទេ ដោយសារវាជាការអនុវត្តន៍ករណីយកិច្ចផ្លូវចិត្ត (devoir moral) (ឧទាហរណ៍បំណុលដែលបំណុលដែលហួសអាជ្ញាយុកាល ជាដើម)។*

www.elibraryofcambodia.org
Scanned with CamScanner

ចានធ្វើសរសេរថា ជាទ្រព្យរួមប្តីប្រពន្ធ "។ ដូចនេះជាបញ្ហាថាតើយកបញ្ញត្តិណាមកអនុវត្ត? ម្យ៉ាងទៀត ក្នុងករណីភតិសន្យាលើអចលនវត្ថុដើម្បីធ្វើជាលំនៅដ្ឋាន ក្រមរដ្ឋប្បវេណីកម្ពុជាត្រង់មាត្រា ៦២០ (សិទ្ធិរំលាយកិច្ចសន្យារបស់សន្តតិជននៅក្នុងករណីដែលភតិក:ទទួលមរណភាព) បញ្ញត្តិថា "*ប្រសិនបើគ្មានបំណងចង់បន្តភតិសន្យាតទៅទៀតទេ សន្តតិជនរបស់ភតិក:អាចរំលាយកិច្ចសន្យានោះបាន* "។ តែក្រមរដ្ឋប្បវេណីត្រង់មាត្រា ១១៤៩ (បុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាសន្តតិជន ជាអាទិ៍) មិនបានកំណត់ឲ្យបានច្បាស់ថាអ្នកណាខ្លះជាសន្តតិជននោះទេ ដូចនេះថាតើអចិន្ត្រៃយ៍ជន អាចក្លាយជាសន្តតិជនបានដែរឬទេនៅក្នុងករណីនេះ។ តែបើសន្តតិកម្មតាមច្បាប់ អចិន្ត្រៃយ៍ជនមិនមែនជាសន្តតិជននោះទេ។ ដូចនេះមានតែអចិន្ត្រៃយ៍ជនដែលជាសន្តតិជនតាមមតកសាសន៍ ឬដែលមានឱស្ស័យពិសេសទេ ទើបមានសិទ្ធិបន្តភតិសន្យាបាន។

ក្នុងករណីប្រទេសជប៉ុនវិញ មានឃុត្តិសាស្ត្ររបស់តុលាការកំពូលបានទទួលស្គាល់ថា "*ករណីដែលក្រោយពេលប្តីនៃអចិន្ត្រៃយ៍ជនទទួលមរណភាព បើភតិបតីទាមទារឲ្យប្រគល់ផ្ទះវិញនោះ ប្រពន្ធនៃអចិន្ត្រៃយ៍ជនអាចលើកឡើងអំពីសិទ្ធិជួលរបស់សន្តតិជន ហើយបដិសេធការប្រគល់ផ្ទះវិញបាន* "។ ហើយមាត្រា

www.elibraryofcambodia.org
Scanned with CamScanner

៣៦ នៃច្បាប់ស្តីពីការជួលដី ឬ ផ្ទះ ចែងថា ក្នុងករណីដែលគ្មានសន្តតិជន សហព័ទ្ធ នៃអនីតិសង្វាសទទួលបន្តនូវសិទ្ធិជួលអគារសម្រាប់ស្នាក់នៅ[68]។

ជំពូកទី ៣- អនុគាមន៍ក្រោយការលាយនៃអនីតិសង្វាស

ផ្នែកទី ១- ការលាយ

កថាខណ្ឌទី ១- មូលហេតុនៃការលាយ៖ ដូចគ្នានឹងអតាហ៍តិតាហ៍?

ការរួមរស់ជាមួយគ្នាដោយសេរី ការលាយទៅវិញក៏ដោយសេរី។ ផ្ទុយពីអតាហ៍តិតាហ៍ដែលត្រូវរលាយទៅវិញដោយឆ្លងកាត់នីតិវិធីមួយច្បាស់លាស់ និងតឹងរ៉ឹង ក្នុងប្រភេទជាច់ណាងដែលកើតឡើងតាមព្រឹត្តិន័យ អនីតិសង្វាសក៏ត្រូវរលាយវិញទៅតាមព្រឹត្តិន័យវិញដែរ ពីព្រោះថាវាកើតឡើងដោយឆន្ទៈសេរីរបស់គូភាគី (គោលការណ៍ស្វ័យភាពនៃឆន្ទៈ ឬ ស្វ័យភាពនៃបុគ្គលឯកជន) ហើយក៏វារលាយទៅវិញដោយតាមឆន្ទៈសេរីរបស់គូភាគីវិញដែរ ដែលអន្តរាគមណ៍របស់តុលាការក្នុងរឿងនេះជារឿងមិនចាំបាច់ទាល់តែសោះ។

នៅប្រទេសជាច្រើន មិនមានវិធានច្បាប់ជាក់លាក់ណាមួយត្រូវបានបញ្ញត្តិក្នុងករណីដែលមានការផ្តាច់ដោយការព្រមព្រៀងរវាងអនីតិសង្វាសជនទាំងពីរនោះទេ។

---

68 Ms. MIURA YASUKO, សាស្ត្រាចារ្យនៃវិទ្យាស្ថានស្រាវជ្រាវ និង បណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌, (ឆ្នាំ២០១៣, សិក្ខាសិលាស្តីពីអនីតិសង្វាស និង សន្តតិកម្ម), *ស្តីពីអនីតិសង្វាស*, ទំព័រទី៧។

www.elibraryofcambodia.org
Scanned with CamScanner

ការផ្តាច់អាចធ្វើដោយគ្មានអន្តរាគមន៍របស់ចៅក្រម។ ក៏ប៉ុន្តែ ក្នុងករណីដែលមានការមិនយល់ស្រប់គ្នា ចៅក្រមក្នុងរឿងត្រួសារ អាចត្រូវបានគេប្តឹងមកខ្លួន ដូចជាបញ្ហាទាក់ទងនឹងអំណាចមេបា លំនៅដ្ឋានរបស់កូន សិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន និងអាហារកាតព្វកិច្ចជាដើម[69]។

រីឯនៅប្រទេសជប៉ុនវិញ ចំពោះការលំលាយអនីតិសង្វាស តុលាការមិនមានការពាក់ព័ន្ធដោយផ្ទាល់ទេ (ក្នុងករណីដែលមានបញ្ហានៅពេលលំលាយ គេអាចដាក់ពាក្យសុំសន្ធានកម្មទៅតុលាការបាន ប៉ុន្តែបានត្រឹមតែធ្វើការចចារតែប៉ុណ្ណោះ[70]។

ដោយឡែកនៅកម្ពុជា គេមិនអាចយកមូលហេតុនៃការលែងលះដែលមានចែងក្នុងមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណីមកធ្វើជាមូលហេតុនៃការផ្តាច់អនីតិសង្វាសបាននោះទេ ពីព្រោះថាមាត្រា៩៧៨ ចែងអំពីមូលហេតុនៃការផ្តាច់ចំណងកិច្ចសន្យាអាពាហ៍ពិពាហ៍ ហើយមាត្រានេះបានផ្តល់អំណាចដល់តុលាការក្នុងការសម្រេចអនុញ្ញាតឱ្យលែងលះគ្នា ឬមិនអនុញ្ញាតទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន និង ឈរលើមូលហេតុដូចមានចែងនៅក្នុងក្រម។ មានន័យថា អាពាហ៍ពិពាហ៍មិនអាចរលាយទៅវិញ

69 Direction de l'information légale et administrative, *Séparation des concubins, article* publié le 12 décembre 2011, WWW.service-public.fr date de consultation le 16 janvier 2014

70 Ms. MIURA YASUKO, សាស្ត្រាចារ្យនៃវិទ្យាស្ថានស្រាវជ្រាវ និង បណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌, (២០១៣, សិក្ខាសិលាស្តីពីអនីតិសង្វាស និង សន្តតិកម្ម), *ស្តីពីអនីតិសង្វាស*, ទំព័រទី៥ (តើគេអាចដាក់ពាក្យបណ្តឹងនៅពេលលំលាយអនីតិសង្វាសដែរឬទេ)។

www.elibraryofcambodia.org

Scanned with CamScanner

តាមចំនើងចិត្តរបស់គូភាគីបានឡើយទេ ហើយវាស្របជាមួយនឹងមន័យនៃអាពាហ៍ពិពាហ៍ដែលកំណត់ក្នុងមាត្រា៣ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃច្បាប់ស្តីពីឯកពន្ធភាព និងមាត្រា៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩។ ផ្ទុយទៅវិញ អធិតិសង្ខាសជាចំណងគតិយុត្តដែលកើតឡើងតាមព្រឹត្តិន័យ នោះវាក៏ត្រូវរលាយទៅវិញតាមព្រឹត្តន័យដែរ។ ជាក់ស្តែង សាលាដំបូងខេត្តព្រះសីហនុ តែងតែច្រានចោលការទាមទារផ្តាច់អធិតិសង្ខាសរបស់ដើមចោទ តែបែរជាសម្រេចវិនិច្ឆ័យអំណាចរមេបា ទ្រព្យសម្បត្តិជារបស់ដើម[71]។ ក្នុងទិដ្ឋភាពនេះ យើងអាចបកស្រាយបានថា នៅក្នុងនីតិកម្មកម្ពុជា អធិតិសង្ខាសត្រូវរលាយដោយសារឆន្ទៈសេរីរបស់គូភាគីដោយមិនទាមទារឲ្យបំពេញលក្ខខណ្ឌ និងនីតិវិធីអ្វីផ្សេងទៀតឡើយ។

កថាខណ្ឌទី ២. និតិវិធី

ចំណុចទី ១. បណ្តឹង

71 សូមមើលឧបសម្ព័ន្ធទី២៖ សាលាដំបូងខេត្តព្រះសីហនុ, *សាលក្រមលេខ ០៩ ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០១២, សំណុំរឿងរដ្ឋប្បវេណីលេខ ១៩១ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១*, សេចក្តីសម្រេចបញ្ចប់។

www.elibraryofcambodia.org
Scanned with CamScanner

- បណ្តឹង៖ នៅក្នុងរឿងក្តីអនីតិសង្វាស ជាញឹកញាប់គឺដើមចោទតែងតែ "*សុំផ្តាច់សមត្ថសង្វាសពីចុងចម្លើយ ឬ ផ្តាច់អចិន្ត្រៃយ៍សង្វាស ឬ ប៉ាប៉ាកាល់ទៅជាអចិន្ត្រៃយ៍សង្វាស*"។

តែចាប់ពីឆ្នាំ ២០១៣ មក សាលាដំបូងខេត្តព្រះសីហនុ មានការកែកម្មវត្ថុពី "*បណ្តឹងផ្តាច់អចិន្ត្រៃយ៍សង្វាស*" ទៅជា "*បណ្តឹងសុំបញ្ជាក់នូវភាពឆ្លងអាពាហ៍ពិពាហ៍*"[72]។ តើបណ្តឹងចុងក្រោយនេះ វាជាបណ្តឹងដែលផ្តុយច្បាប់ដែរឬទេ។ លក្ខណៈសំខាន់ៗនៃបណ្តឹងមាន ៥ ចំណុចដូចតទៅ៖ ទី១ ការដាក់ពាក្យបណ្តឹង និងការបញ្ជូនពាក្យបណ្តឹងដែលមានសុពលភាព ទី២ មានភាគីត្រឹមត្រូវ ហើយជាភាគីមានសមត្ថភាព ទី៣ ចុងចម្លើយស្ថិតនៅក្រោមសិទ្ធិជម្រះក្តីរបស់ព្រះរាជាណាចក្រកម្ពុជា ទី៤ តុលាការដែលចាត់ការត្រូវមានសមត្ថកិច្ចលើរឿងក្តីនោះ និងទី៥ ផលប្រយោជន៍ក្នុងការធ្វើបណ្តឹង មានន័យថាមានផលប្រយោជន៍ ឬភាពចាំបាច់តាមផ្លូវច្បាប់រវាងភាគីនៃបណ្តឹង ក្នុងការទាមទារសាលក្រមស្តីពីការទាមទារតាមផ្លូវបណ្តឹងដែលត្រូវបង្ហាញក្នុងបណ្តឹងដោយដើមចោទ[73]។ នៅត្រង់នេះ ផលប្រយោជន៍ ឬភាព

---

72 សូមមើលឧបសម្ព័ន្ធទី៤៖ សាលាដំបូងខេត្តព្រះសីហនុ, សំណុំរឿងរដ្ឋប្បវេណីលេខ ៦០ ចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០១៣, *ពាក្យបណ្តឹង ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៣*។

73 ក្រុមការងារជំនុំដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីអំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគទី១៖ នីតិវិធីបណ្តឹង*, (ភ្នំពេញ, ២០០៨), ទំព័រទី១២១ និង ១២២ (លក្ខណៈបណ្តឹងសំខាន់ៗ)។

www.elibraryofcambodia.org
Scanned with CamScanner

ចាំបាច់តាមផ្លូវច្បាប់ ក្នុងការធ្វើបណ្តឹងបញ្ជាក់អំពីនត្ថិភាពនៃអាពាហ៍ពិពាហ៍ ហាក់ដូចជាមិនមានឡើយ ព្រោះថាគោលដៅរបស់វា គឺបញ្ហាផ្លូវចិត្ត និងផ្លូវសីលធម៌ក្នុងសង្គមកម្ពុជាតែប៉ុណ្ណោះ ព្រមទាំងមានការគោលដៅផ្តាច់អនីតិសង្វាសផងដែរ។ ក៏ប៉ុន្តែ ការទទួលស្គាល់អំពីនត្ថិភាពនៃអាពាហ៍ពិពាហ៍ក៏មិនមានន័យថាមានអត្ថិភាពនៃអនីតិសង្វាសដោយស្វ័យប្រវត្តិដែរ។ ម្យ៉ាងទៀត ការទាមទារសុំបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍នេះ អាចត្រូវបានទទួលស្គាល់ដោយតុលាការបានតែក្នុងករណីដែលមានមូលហេតុរបស់វាត្រឹមត្រូវ។ ដូចនេះ សំណួរចោទឡើងថា តើអ្វីទៅជាមូលដ្ឋានរបស់តុលាការក្នុងការសម្រេចអំពីការបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍។ ជាទូទៅចំនួនជាមានសច្ចធារណ៍តាមផ្លូវតុលាការដែលថា បើគ្មានសំបុត្រអាពាហ៍ពិពាហ៍នោះវាមាននត្ថិភាពនៃអាពាហ៍ពិពាហ៍។

ចំណុចទី ២- ការពិនិត្យពាក្យបណ្តឹង ឬពាក្យសុំ

ការពិនិត្យពាក្យបណ្តឹង ឬពាក្យសុំ៖ មាត្រា ៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា កំណត់អំពីលក្ខខណ្ឌនៃបណ្តឹងដោយចាត់ទុកពន្ធសម្រាប់ដាក់ពាក្យសុំក៏ជាលក្ខខណ្ឌសុពលភាពនៃបណ្តឹង។ ជាក់ស្តែងនៅសាលាដំបូងខេត្តព្រះសីហនុ តុលាការបានប្រើគោលការណ៍សច្ចធារណ៍តាមផ្លូវតុលាការដោយកំណត់ដូចតទៅ៖ ករណីទីមួយ- ចំពោះពាក្យសុំ ត្រូវបង់ពន្ធដាក់ពាក្យសុំចំនួនស្មើ ៥ ០០០ (ប្រាំពាន់)

www.elibraryofcambodia.org
Scanned with CamScanner

រៀល ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ (ទាក់ទងការបញ្ជូនពាក្យសុំ) ស្មើ ៥០ ០០០ (ប្រាំម៉ឺន) រៀល។ រីឯ ករណីទីពីរ- ចំពោះពាក្យបណ្តឹង ត្រូវបង់ពន្ធដាក់ពាក្យសុំចំនួន ស្មើ ១០ ០០០ (មួយម៉ឺន) រៀល ហើយប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ (ទាក់ទងការបញ្ជូនពាក្យបណ្តឹង) ស្មើ ១០០ ០០០ (ដប់ម៉ឺន) រៀល។ ចំណែករឿងក្តីដែលមានកម្មវត្ថុលែងលះគ្នា ពន្ធដាក់ពាក្យសុំតាមមាត្រា ៦១ កំណត់ចំនួន ៥៥ ០០០ (ប្រាំម៉ឺនប្រាំពាន់)[74] រៀល ហើយប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ (ទាក់ទងការបញ្ជូនពាក្យបណ្តឹង) ស្មើ ១០០ ០០០ (ដប់ម៉ឺន) រៀល។ ពន្ធជាលក្ខណសុពលភាពនៃពាក្យសុំ យោងតាមមាត្រា៧៨ នៃក្រមដដែល។

ក្នុងកាលៈទេសៈខ្លះ បណ្តឹងដែលមានកម្មវត្ថុផ្តាច់អនុតិសង្ឃាស ទាមទារអំណាចមេបា ទាមទារអាហារភាតព្វកិច្ច និងបែងចែកទ្រព្យរួម ត្រូវបង់ពន្ធតាមករណីទីមួយខាងលើ (ក្នុងប្រភេទជាពាក្យសុំ)។ ផ្ទុយទៅវិញ នៅពេលខ្លះ បណ្តឹងប្រភេទដូចគ្នានេះត្រូវបង់ពន្ធ តាមករណីទីពីរខាងលើ (ក្នុងប្រភេទនៃពាក្យបណ្តឹង)។ ពិតណាស់ ដោយសារថាពន្ធជាលក្ខណសុពលភាពនៃបណ្តឹង ដូចនេះការបង់ពន្ធ

---

74 ប្រកាសលេខ ៥៤ កយ.ប្រក./០៩ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលឧបសម្ព័ន្ធ ១ និង ឧបសម្ព័ន្ធ៤ នៃប្រកាសលេខ ២៨ កយ.ប្រក/០៧ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីប្រភេទពាក្យសុំដែលតម្រូវឲ្យបង់ពន្ធ ចំនួនទឹកប្រាក់ ដែលពន្ធដាក់ពាក្យសុំ និង ចំនួនពន្ធដែលត្រូវបង់ ដើម្បីធ្វើសកម្មភាពក្រៅពីពាក្យសុំទៅតុលាការឲ្យសម្រេចសេចក្តី និង មាត្រដ្ឋានសម្រាប់គណនាប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ និង តម្លៃកម្មវត្ថុនៃបណ្តឹង, *ឧបសម្ព័ន្ធ៤ថ្មី, ទំព័រទី១៣, ឧបសម្ព័ន្ធទី១*។

www.elibraryofcambodia.org
Scanned with CamScanner

មិនត្រឹមត្រូវប្រាកដជាប៉ះពាល់ដល់លក្ខខណ្ឌនៃបណ្តឹង។ តែក្នុងការអនុវត្តជាក់ស្តែងនៅសាលាដំបូងខេត្តព្រះសីហនុ មិនដែលមានភាគីណាមួយឥរិយាបថពោះបញ្ហាខាងលើនោះទេ។

ចំណុចទី ៣- ដំណើរការនៃនីតិវិធី

ដំណើរការនៃនីតិវិធី៖ ច្បាប់នីតិវិធីដែលត្រូវយកមកអនុវត្ត?៖ បន្ទាប់ពីទទួលបាន *ពាក្យសុំ ឬ ពាក្យបណ្តឹងស្តីពីអនីតិសង្វាស* ឬ *ផ្តាច់សមត្ថសង្វាសពីចុងចម្លើយ* រួចមក សាលាដំបូងខេត្តព្រះសីហនុបានដំណើរការនីតិវិធីរឿងក្តីផ្តាច់អនីតិសង្វាស ដោយឈរលើច្បាប់ស្តីពីនីតិវិធីបណ្តឹងស្តីពីហានៈបុគ្គល ឬ នីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង ដោយធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (ការទាញហេតុផលផ្តាល់មាត់តាមឧទ្ធានុសិទ្ធិរបស់ចៅក្រម) រួចចេញដីកាសម្រេចក្នុងករណីមានការព្រមព្រៀងគ្នារវាងភាគី ឬ ដោយឈរលើក្រមនីតិវិធីរដ្ឋប្បវេណីដែលជាបញ្ញត្តិទូទៅ៖ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ការទាញហេតុផលផ្តាល់មាត់ ឬ លើកពាក្យបណ្តឹងចោលតាមមាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ នៅដំណាក់កាលនីតិវិធីត្រៀម ជាទូទៅភាគីតែងតែថ្លែងអំពីមូលហេតុដែលនាំឲ្យមានការ *ផ្តាច់សមត្ថសង្វាសពីចុងចម្លើយ ឬ ផ្តាច់អនីតិសង្វាស* ឧទាហរណ៍ដូចជាអំពើហិង្សា អំពើផិត ជាដើម និងអំពីប្រវត្តិនៃដំណើរអនីតិ-សង្វាសរបស់ខ្លួន ព្រម

www.elibraryofcambodia.org

Scanned with CamScanner

ទាំង សិទ្ធិគ្រប់គ្រងកូន (អំណាចអមបា) ឬពេលខ្លះទាមទារអាហារកាតព្វកិច្ចដើម្បីកូន ឬ ផ្ទាល់ខ្លួន។ គោលដៅនៃនីតិវិធីនេះ គឺដើម្បីរៀបចំការអះអាង និងចំណុចវិវាទនៃរឿងក្តី។

ការចាត់ចែងរក្សាការពារ ដែលចែងក្នុងមាត្រា ៩៨៣ នៃក្រមរដ្ឋប្បវេណី អាចយកមកអនុវត្តនៅក្នុងរឿងក្តីផ្តាច់អនីតិសង្វាសបានដែរឬទេ? បើបាន តើនៅក្នុងចំហំណា? មាត្រានេះកំណត់ថា "*តុលាការដែលទទួលបណ្តឹងលែងលះគ្នា ក្នុងករណីចាំបាច់ អាចចេញដីកាសម្រេចបង្គាប់ឲ្យធ្វើការចាត់ចែងរក្សាការពារចំពោះការបំរែបំរលំនៅសង្វាស ការគ្រប់គ្រងថែរក្សាកូន ការគ្រប់គ្រងរក្សាទ្រព្យសម្បត្តិ អាហារកាតព្វកិច្ចរបស់សហព័ទ្ធ បន្ទុកនៃសោយហ៊ុយអាពាហ៍ពិពាហ៍ និងសោហ៊ុយចិញ្ចឹមបីបាច់កូន ជារៀងទី តាមពាក្យសុំ ឬ ដោយឥស្សានុសិទ្ធិ*" ។ តាមធាតុពិតរបស់វាបញ្ញត្តិនេះ អាចអនុវត្តន៍បានតែក្នុងរំណាក់កាលនៃនីតិវិធីនៃការលែងលះគ្នាតែប៉ុណ្ណោះ។ ដូចនេះ ការចាត់ចែងរក្សាការពារក្នុងរឿងក្តីអនីតិសង្វាសគួរតែអាចអនុវត្តដោយឈរលើមាត្រា៩៨៣ នៃក្រមខាងលើបាន ឬប្រតិបត្តិតាមជំពូកគន្លឹះទី៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាវិញ ក្នុងក្របខណ្ឌនៃការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន។

www.elibraryofcambodia.org
Scanned with CamScanner

ការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវបានធ្វើក្នុងករណីដែលតុលាការផ្អែករលើក្រមនីតិវិធីរដ្ឋប្បវេណី ឬ មិនបានធ្វើ បើសិនជាតុលាការយកច្បាប់ស្តីពីនីតិវិធីបណ្តឹងស្តីពីឋានៈបុគ្គល ឬ នីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង។

ចំណុចទី ៤- ការខកនិថ្នាំយសេចក្តី

ការវិនិច្ឆ័យសេចក្តី៖ ក៏ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែងនៅសាលាដំបូងខេត្តព្រះសីហនុ តុលាការបានខ្ចីបញ្ញត្តិស្តីពីអាពាហ៍ពិពាហ៍នៅក្នុងក្រមរដ្ឋប្បវេណីទៅអនុវត្តនៅក្នុងរឿងក្តីអនីតិសង្វាស (ឧទាហរណ៍ទ្រព្យសម្បត្តិរួមប្តីប្រពន្ធ ជាដើម) បើទោះបីជាតុលាការលើកចោល *បណ្តឹងសុំផ្តាច់អនីតិសង្វាស ឬ ផ្តាច់សមត្ថសង្វាសពីគុងចរម្លើយ* របស់ដើមចោទក៏ដោយ ដោយយល់ថាវាជាបណ្តឹងផ្ទុយនឹងច្បាប់ (យោងតាមមាត្រា៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ការត្រាន់ចោលបណ្តឹងនេះតុលាការ មិនបានបង្ហាញទម្លឹករណ៍គតិយុត្តណាមួយច្បាស់លាស់នោះទេ ដោយត្រាន់តែសំអាងថា វាជាបណ្តឹងដែលផ្ទុយនឹងច្បាប់ ដូចមានចែងក្នុងមាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី (*ក្នុងករណីដែលបណ្តឹងមានលក្ខណៈផ្ទុយនឹងច្បាប់ ហើយចំណុចខ្វះខាតនោះមិនអាចកែតម្រូវបានទេ តុលាការលើកបណ្តឹងនោះចោល ដោយសាលក្រម ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់*)។ វាប្រែហែលទំនងជាខុសទៅនឹងលក្ខខណ្ឌបណ្តឹងសំខាន់ៗទាំងប្រាំ ដែលយើងបានបរិយាយខាង

www.elibraryofcambodia.org
Scanned with CamScanner

លើ។ ការណ៍នេះ តុលាការកំពុងតែទទួលស្គាល់ថា អនីតិសង្វាសមានអានុភាពដូចគ្នា និងអាពាហ៍ពិពាហ៍[75]។

ក្នុងន័យទូទៅ ពាក្យថា *សមគ្គសង្វាស ឬ សមគ្គសំវាស* ត្រូវបានគេផ្តល់ឱ្យមន័យថា *ការនៅរួមព្រមចិត្តព្រមគំនិត, ការនៅរួមសុខរួមទុក្ខ (របស់ប្តីប្រពន្ធ)*[76]។ ក្នុងន័យនីតិសាស្ត្រ ពាក្យថា*សមគ្គសង្វាស មានន័យថា ជាការរួមរស់នៅជាមួយគ្នារវាងប្តីប្រពន្ធដោយមានការដាក់បណ្តាលគ្នាទៅវិញទៅមក* ហើយវាត្រូវបានបែងចែកជាពីរប្រភេទគឺ ទីមួយហៅថាជា **សមគ្គសង្វាសតាមច្បាប់** នៅក្នុងក្របខណ្ឌនៃអាពាហ៍ពិពាហ៍តាមច្បាប់ (Union de droit) និង ទីពីរ ហៅថាជា **សមគ្គសង្វាសតាមព្រឹត្តន័យ** នៅក្នុងក្របខណ្ឌនៃអាពាហ៍ពិពាហ៍ដែលមិនបានចុះបញ្ជី ឬ អនីតិសង្វាស (Union du fait)[77]។ សមគ្គសង្វាសតាមច្បាប់ (Union de droit) ត្រូវបានគេប្រើនៅក្នុងន័យមន័យនៃអាពាហ៍ពិពាហ៍ ដូចមានចែងនៅក្នុងមាត្រា ៣ កថាខណ្ឌទី១ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ និង មាត្រា ៣

---

75 សូមមើលឧបសម្ព័ន្ធទី៣៖ សាលាដំបូងខេត្តព្រះសីហនុ, *សាលក្រមលេខ ០៩ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៣, សំណុំរឿងរដ្ឋប្បវេណីលេខ ១៩១ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១*។

76 សម្តេចព្រះសង្ឃរាជ ជួន ណាត, *វចនានុក្រមឆ្លងអក្ខរាភិធាន (ល-អ)*, (ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត, កម្ពុជាលេខ១៦៥, បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៨), ទំព័រទី ១២៧៩។

77 Gérald Cornu, Association Henri Capitant, *Vocabulaire juridique* (7ème Édition puf, 2005), page 927, le mot « **Union** ».

www.elibraryofcambodia.org
Scanned with CamScanner

កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃច្បាប់ស្តីពីឯកភាពភាព ឆ្នាំ២០០៦ ដោយកំណត់ថា៖ "*អាពាហ៍ពិពាហ៍គឺជាកិច្ចសន្យារដ្ឋប្បវេណីមួយ ធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលប្តេជ្ញាថា ខ្លួនទីងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញតាមចំណើងចិត្តរបស់ខ្លួន*" ។ រីឯ សមគ្គសង្វាសតាមព្រឹត្តិន័យ ឬ ហៅថា អនីតិសង្វាស មិនមានចែងនៅក្នុងច្បាប់ណាមួយនោះទេ តែមានតែក្រមព្រហ្មទណ្ឌ ត្រង់មាត្រា២២២ តែប៉ុណ្ណោះ ដែលយកបានលើកឡើងអំពីសញ្ញាណនេះ តែមិនមានឲ្យនិយមន័យយ៉ាងដូចម្តេចនោះទេ។ ការទ្រានចោលបណ្តឹងរបស់ដើមចោទដែលសុំផ្តាច់សមគ្គសង្វាសពីចុងចម្ងៃយ (ក្នុងរឿងក្តីអនីតិសង្វាស) នេះ ហាក់ដូចជាមិនសមស្របទៅតាមនិយមន័យនៃពាក្យសមគ្គសង្វាសទាល់តែសោះ ព្រោះថាអនីតិសង្វាសក៏ជាសមគ្គសង្វាសមួយដែរ ដោយគ្រាន់តែជាសមគ្គសង្វាសតាមព្រឹត្តិន័យ។ ដូចនេះ ចាំបាច់ទាមទារឲ្យមានការសរសេរកម្មវត្ថុនៃបណ្តឹង និង ការប្រើពាក្យនៅក្នុងសេចក្តីសម្រេចរបស់តុលាការឲ្យបានត្រឹមត្រូវ ជាក់ស្តែងបើមានចំណងអាពាហ៍ពិពាហ៍ត្រូវប្រើពាក្យថា "***សុំលែងលះគ្នា***" តែបើគ្មានចំណងអាពាហ៍ពិពាហ៍ទេត្រូវប្រើពាក្យ "***តាមទារផ្តាច់អនីតិសង្វាស***" ជាដើម ដៀសវាងការប្រើពាក្យ "***សុំផ្តាច់សមគ្គសង្វាស***"។ ទោះជាយ៉ាងណាក៏ដោយ បណ្តឹងទាមទារផ្តាច់អនីតិសង្វាសជាបណ្តឹងមានកម្មវត្ថុខុសច្បាប់។

www.elibraryofcambodia.org
Scanned with CamScanner

ងាកមកមើលការប្តឹងឈ្នះកម្មវត្ថុបណ្តឹងពីការ *សុំផ្តាច់អនីតិសង្វាស* ឬ *ផ្តាច់សមគ្គសង្វាស* ទៅជាបណ្តឹងដែលមានកម្មវត្ថុ *បណ្តឹងសុំបញ្ជាក់នូវភាពនៃអាពាហ៍ពិពាហ៍* វិញ តុលាការបានទទួលអំពីនភ្តិភាពនៃអាពាហ៍ពិពាហ៍ ផ្ទុយទៅវិញ តុលាការបានយកបញ្ហាភ្តិស្តីពីអនុភាពនៃអាពាហ៍ពិពាហ៍ និងការលែងលះគ្នា មកអនុវត្តនៅក្នុងរឿងក្តីទាមទារឲ្យបញ្ជាក់នូវភាពនៃអាពាហ៍ពិពាហ៍នេះ។ តាមពិតទៅ បណ្តឹងសុំបញ្ជាក់នូវភាពនៃអាពាហ៍ពិពាហ៍គឺជាបណ្តឹងខុសច្បាប់ ដោយសារលក្ខខណ្ឌនៃបណ្តឹង (លក្ខខណ្ឌនៃបណ្តឹងទាំងប្រាំ) ជាពិសេសត្រង់ផលប្រយោជន៍នៃការធ្វើបណ្តឹងដែលមិនមានអត្ថិភាពនៅក្នុងអនីតិសង្វាស។

ផ្នែកទី ២- អនុគាតត្រាយការលាយ

កថាខណ្ឌទី ១- អនុគាតផ្នែកបុគ្គល (ត្រូវបានកត់សម្គាល់)

ចំណុចទី ១- នៅឯអនីតិសង្វាសជន

សំណងការខូចខាត ក្នុងករណីមានកំហុស?៖ ដោយហេតុថាវាមិនមានជាចំណងដែលមានអនុភាពចាប់បង្ខំរវាងអនីតិសង្វាសជនទាំងសងខាង ដូច្នេះការផ្តាច់ចំណងនេះ មិនផ្តល់សិទ្ធិណាមួយឲ្យភាគីដែលត្រូវគេបោះបង់ចោល ដូចជាសិទ្ធិទទួលនូវសំណងដែលកើតឡើងដោយព្យសនកម្មឡើយ។ វាមិនដូចគ្នានឹងអាពាហ៍-ពិពាហ៍នោះទេ។ សាលដីការបស់សភាវរដ្ឋប្បវេណីទីមួយនៃតុលាការកំពូលបានឹង

www.elibraryofcambodia.org
Scanned with CamScanner

(La Cour de Cassation) ចុះថ្ងៃទី១៧ ខែមីថុនា ឆ្នាំ១៩៥៣ បានលើកឡើងថា ***ការផ្តាច់ចំណងអធម្មានុរូបមិនបង្កើតជាកំហុសស៊ីវិលដែលត្រូវបើកឱ្យមានសិទ្ធិទទួលបានសំណងការខូចខាតនោះទេ*** (***la rupture d'une liaison illégitime ne constitue pas en elle-même une faute civile susceptible d'ouvrir droit à des dommages intérêts [...]***) [78]។

ទោះបីជា ការផ្តាច់មិនមែនជាកំហុសក្តី ក៏ប៉ុន្តែស្ថានភាពដែលនាំឱ្យមានការផ្តាច់អនីតិសង្វាសមួយចំនួនក៏អាចត្រូវចាត់ទុកថាមានកំហុសដែរ។ ដូចគ្នាឱ្យករណីនៃការផ្តាច់កំជាប់ពាក្យដែលការផ្តាច់មិនមែនជាកំហុសនោះទេ ផ្ទុយទៅវិញការផ្តាច់ដោយគ្មានមូលហេតុត្រឹមត្រូវទៅវិញទេ ដែលនាំឱ្យកើតមានព្យសនកម្មចំពោះភាគីម្ខាងទៀត ភាគីដែលផ្តាច់នោះត្រូវទទួលខុសត្រូវ[79]។ ឧទាហរណ៍ដូចជាក្នុងករណីដែលអនីតិសង្វាសជន បានបោះបង់ចោលអនីតិសង្វាសនីដែលទើបតែឆ្លងទន្លេដោយ

---

78 Philippe MALAURIE, Hugues FULCHIRON, *LA FAMILLE*, (Editions juridiques associés: DEFRENOIS, 2006), p166, paragraphe 328.

79 ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៩៤៥ (ការសងជំនួន) កំណត់ថា៖ *ក្នុងករណីដែលកំជាប់ពាក្យបានរលាយ ភាគីដែលបានលើកជំនួនអាំពេលកំជាប់ពាក្យ ដោយសង្ឃឹមថាមិនមានអាពាហ៍ពិពាហ៍ អាចទាមទារឱ្យភាគីម្ខាងទៀត សងជំនួនដោះមកវិញបាន។* ហើយ មាត្រា ៩៤៦ (ការទទួលខុសត្រូវចំពោះការបដិសេធចោលដោយមិនត្រឹមត្រូវ) កំណត់ថា៖ *ក្នុងករណីដែលភាគីម្ខាងបានបដិសេធកំជាប់ពាក្យដែលបានភ្ជាប់រវាងភាគីចោល **ដោយគ្មានមូលហេតុត្រឹមត្រូវ** ភាគីម្ខាងទៀតអាចទាមទារសំណងនៃការខូចខាតដែលកើតឡើងដោយសារការបដិសេធចោលនោះបាន។*

www.elibraryofcambodia.org
Scanned with CamScanner

ឥតស្រណោះទាំងផ្នែកសម្ភារៈ និង ផ្នែកសីលធម៌។ ការផ្តាច់អធិតិសង្ខាសមិនបង្កើតទៅជាកំហុសនោះទេ ប៉ុន្តែសំណងការខូចខាតអាចត្រូវបានសម្រេចដោយសេចក្តីសម្រេចរបស់តុលាការនៅពេលការផ្តាច់នោះមានកំហុស[80]។

បើទោះបីជា ការផ្តាច់អធិតិសង្ខាសមិនទាំងឲ្យមានសិទ្ធិក្នុងការទាមទារសំណងក៏ដោយ ក៏ការទាមទារសំណងនៃការខូចខាតអាចឈរទៅលើមូលដ្ឋាននៃគោលការណ៍សមធម៌បានផងដែរក្នុងករណីដែលមានការរំលាយដោយឯកតោភាគី។

នៅប្រទេសជប៉ុន នៅពេលដែលគេទទួលស្គាល់ការទាមទារប្រាក់ជម្ងឺចិត្តដោយភាគីម្ខាងទៀត ក្នុងទម្រង់ជាប្រាក់សំណងការខូចខាតដោយផ្អែកលើអំពើអធិតិក្បាឧក្រុលចំពោះភាគីម្ខាងទៀត ក្នុងករណីដែលការទទួលខុសត្រូវនៃការបែកបាក់អាពាហ៍ពិពាហ៍ជាបន្ទុករបស់ភាគីម្ខាងទៀត (ឧទាហរណ៍ បានប្រព្រឹត្តអំពើផិតក្បត់ ឬ បានបង្កហិង្សាជារឿម)។ ចំពោះការរំលាយអធិតិសង្ខាសក៏ត្រូវបានទទួលស្គាល់ការទាមទារប្រាក់ជម្ងឺចិត្តនេះដែរ[81]។

---

80 Direction de l'information légale et administrative, *Séparation des concubins, article* publié le 12 décembre 2011, WWW.service-public.fr, date de consultation le 16 janvier 2014.

81 Ms. MIURA YASUKO, សាស្ត្រាចារ្យនៃវិទ្យាស្ថានស្រាវជ្រាវ និង បណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌, (ឆ២០១៣, សិក្ខាសិលាស្តីពីអធិតិសង្ខាស និង សន្តតិកម្ម), *ស្តីពីអធិតិសង្ខាស*, ទំព័រទី៥។

www.elibraryofcambodia.org

Scanned with CamScanner

សិទ្ធិទទួលបានសន្តតិកម្មរបស់អនីតិសង្វាសជនណាម្នាក់៖ ទាក់ទងទៅនឹងសិទ្ធិទទួលមរតករបស់អនីតិសង្វាសជនណាម្នាក់ យើងអាចបកស្រាយដោយឈរលើទង្គឹកវណ៌ដែលមានចែងក្នុងក្រមរដ្ឋប្បវេណីកម្ពុជា។ មាត្រា១២៩៩ កថាខណ្ឌទី១ នៃក្រមនេះ បានផ្តល់សិទ្ធិទៅឲ្យ "*បុគ្គលដែលមានឱសរ្ជ័យពិសេស*" ក្នុងការទទួលបានមរតករបស់មតកជន។ យោងតាមបញ្ញត្តិនេះ បុគ្គលដែលមានឱសរ្ជ័យពិសេសនេះ អាចជា "*ជនដែលមានជីវភាពជាមួយគ្នានឹងមតកជន ជនដែលបានខិតខំរមែលរែទាំព្យាបាលមតកជន និង ជនដែលមានឱសរ្ជ័យពិសេសផ្សេងទៀត*"។ តែតុលាការអាចបែងចែកមរតកឲ្យបានតែក្នុងករណីដែល តុលាការឃើញថាសមរម្យមរតកជាផ្នែកដែលនៅសល់ក្រោយការជម្រះ មានពាក្យសុំរបស់ជនខាងលើ និង ចំនួនសរុបនៃតម្លៃដែលត្រូវចែកទៅឲ្យ មិនត្រូវលើសពីចំនួនពាក់កណ្តាលនៃមរតកដែលនៅសល់នោះទេ។ បើយោងទៅតាមវិសាលភាពនៃន័យមសាររបស់អនីតិសង្វាស អនីតិសង្វាសជនម្នាក់មានសិទ្ធិទទួលមរតកតាំ អនីតិសង្វាសជនម្ខាងទៀតដែលបានទទួលមរណភាពបានក្នុងលក្ខខណ្ឌដូចបានលើកឡើងខាងលើ។

ដូចដែលយើងបានលើកឡើងក្នុងជំពូកទី២ផ្នែកទី២ កថាខណ្ឌទី៣ ខាងលើរួចមកហើយថាក្នុងករណីកតិសន្យាលើអចលនវត្ថុដើម្បីធ្វើជាលំនៅដ្ឋានក្រមរដ្ឋប្បវេណីកម្ពុជាត្រង់មាត្រា៦២០ (សិទ្ធិរំលាយកិច្ចសន្យារបស់សន្តតិជននៅក្នុងករណីដែលតតិកៈទទួលមរណភាព) បញ្ញត្តិថា "*ប្រសិនបើគ្មានបំណងចង់បន្តកតិសន្យាតទៅ*

www.elibraryofcambodia.org
Scanned with CamScanner

ទៀតទេ សន្តតិជនរបស់ភតិកៈអាចរំលាយកិច្ចសន្យានោះបាន"។ តែក្រមរដ្ឋប្បវេណីត្រង់មាត្រា១១៤៩ (បុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាសន្តតិជន ជាអចិន្ត្រៃយ៍) មិនបានកំណត់ឲ្យបានច្បាស់ថាអ្នកណាខ្លះជាសន្តតិជននោះទេ ដូចនេះថាតើអនីតិសង្វាសជន អាចក្លាយជាសន្តតិជនបានដែរឬទេនៅក្នុងករណីនេះ។ តែបើសន្តតិកម្មតាមច្បាប់ អនីតិសង្វាសជនមិនមែនជាសន្តតិជននោះទេ។ ដូចនេះមានតែអនីតិសង្វាសជនដែលជាសន្តតិជនតាមមតកសាសន៍ ឬដែលមានឱស្ស័យពិសេសទេ ទើបមានសិទ្ធិបន្តភតិសន្យាបាន។

ហើយក្នុងករណីភតិសន្យាលើអចលនវត្ថុដើម្បីធ្វើជាលំនៅដ្ឋាន នៅប្រទេសជប៉ុនវិញ តុលាការកំពូលបានទទួលស្គាល់ថា "*ករណីដែលក្រោយពេលប្តីនៃអនីតិសង្វាសបានទទួលមរណភាព បើភតិបតីទាមទារឲ្យប្រគល់ផ្ទះវិញនោះ ប្រពន្ធនៃអនីតិសង្វាសអាចលើកឡើងអំពីសិទ្ធិជួលរបស់សន្តតិជន ហើយបដិសេធការប្រគល់ផ្ទះវិញបាន*"។ ហើយមាត្រា ៣៦ នៃច្បាប់ស្តីពីការជួលដី ឬ ផ្ទះ ចែងថា "*ក្នុងករណីដែលគ្មានសន្តតិជន សហព័ទ្ធនៃអនីតិសង្វាសទទួលបន្តនូវសិទ្ធិជួលអាគារសម្រាប់ស្នាក់នៅ*"[82]។

ចំណុចទី ២- ចំពោះកុន

82 Ms. MIURA YASUKO, សាស្ត្រាចារ្យនៃវិទ្យាស្ថានស្រាវជ្រាវ និង បណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌, (២០១៣, សិក្ខាសាលាស្តីពីអនីតិសង្វាស និង សន្តតិកម្ម), *ស្តីពីអនីតិសង្វាស*, ទំព័រទី៧។

www.elibraryofcambodia.org
Scanned with CamScanner

គួរបញ្ជាក់ថាកូនទៅទីនេះជាកូនដែលមិនចុះនៅក្នុងសំបុត្រអត្រានុកូលដ្ឋាន (សំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើត) ឬ ដែលមានការទទួលស្គាល់នៅក្នុងសេចក្តីសម្រេចរបស់តុលាការ។

ហើយ *ស្ថានភាពគតិយុត្តពីរស្រដៀងគ្នា ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងដោយច្បាប់តែមួយ* (method d'interprétation a pari ou a simili ou par analogie)[83] ដូចជាអនុភាពក្រោយការលែងលះគ្នា និង អនុភាពក្រោយការរលាយអធិតិសង្វាសជាដើម។ នេះជាខ្លឹមសារនៃគោលការណ៍នៃការមិនរើសអើង (Principe de la non-discrimination)។

១- អ្នកមានអំណាចមេបា

អំណាចមេបាក្រោយការរលាយអធិតិសង្វាស មានរបបគតិយុត្តដូចគ្នានឹងអំណាចមេបានៅក្រោយការលែងលះគ្នា គោលគឺជាអំណាចមេបាទោល។ ដោយគ្រាន់តែពេលរលាយចំណងអធិតិសង្វាស ភាគីអាចទាមទារឱ្យតុលាការកំណត់អ្នកមានអំណាចមេបាទៅលើកូន បើសិនជាការពិភាក្សាមិនបានសម្រេច។ សូមមើល

---

83 សាស្ត្រាចារ្យ ស៊ឹម សុខម្ហូ, *បរិច្ឆេទទស និង វិធីសាស្ត្របកស្រាយបទដ្ឋានគតិយុត្តខាងក្រៅ*, (រាជបណ្ឌិតសភាវិញ្ញាជីវៈតុលាការ, កញ្ញា ២០០៩), ទំព័រទី៦ ចំណុច ១-១- វិធីបកស្រាយ ឬធ្វើវិចារណកិច្ចតាមសទិសវិធី ឬតាមវិធីប្រដូច។

www.elibraryofcambodia.org
Scanned with CamScanner

ចំណុចទី ១ (អំណាចមេបា៖ ទោល ឬ សហការ?) កថាខណ្ឌទី ២ ផ្នែកទី២ ជំពូកទី២។

២- សិទ្ធិ និង ការលើកយកចិត្តទុកដាក់ឪពុកម្តាយដែលមិនរស់នៅជាមួយកូន

តាមទស្សនៈរបស់ជប៉ុនគេថា៖ - *អ្នកមាននៅក្នុងមាត្រា១១៤០ (សិទ្ធិ និង ការលើកយកចិត្តរបស់ឪពុកម្តាយដែលមិនរស់នៅជាមួយកូន) ក្នុងករណីដែលមានការទទួលស្គាល់ទំនាក់ទំនងឪពុក និង កូន រវាងឪពុក ឬ ម្តាយដែលមិនមានអំណាចមេបាអាចចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូនបានអ្នកករណីអាពាហ៍ពិពាហ៍ហើយដែលមានកាតព្វកិច្ចទទួលខុសត្រូវលើបន្ទុកសោហ៊ុយចាំបាច់សម្រាប់ការគ្រប់គ្រងថែរក្សាកូន*-[84]។ ការកំណត់អំពីការចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន និង សោហ៊ុយចាំបាច់សម្រាប់ការគ្រប់គ្រងថែរក្សាកូន ត្រូវធ្វើឡើងដោយឆន្ទៈសេរីរបស់ភាគី លើកលែងតែការពិភាក្សាគ្នាមិនបានសម្រេច។

ការលើកឡើងខាងលើបែបនេះគឺសមស្របទៅនឹង[85] កថាខណ្ឌទី៣ មាត្រា ១០៤០ នៃក្រមដែលសំដែងថា" *ឪពុកដែលមិនបានរស់ជាមួយកូនដែលបានទទួល*

---

84 Ms. MIURA YASUKO, សាស្ត្រាចារ្យនៃវិទ្យាស្ថានស្រាវជ្រាវ និង បណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌, (ឆ្នាំ២០១៣, សិក្ខាសិលាស្តីពីអនីតិសង្វាស និង សន្តតិកម្ម), *ស្តីពីអនីតិសង្វាស*, ទំព័រទី៦។

85 សូមមើលឯកសារយោងលេខ ៥៧ ខាងលើ។

www.elibraryofcambodia.org

Scanned with CamScanner

ស្គាល់ អាចពិភាក្សា និង កំណត់ ជាមួយម្ដាយ អំពីរបៀបជួបប្រាស្រ័យទាក់ទង និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន "។ បុគ្គលភាព រវាងកូនទៅនឹងឪពុកឬម្ដាយគឺជាលក្ខណៈជាសារវន្តដ៏ប្លែកបំផុតក្នុងការអនុវត្តបទប្បញ្ញត្តិនេះ។ "ក្នុងករណីមិនមានពុំបានសម្រេច ឬ បើពុំអាចធ្វើការពិភាក្សាបានទេ ការទូលខ្លួនអន្តរាគមន៍របស់តុលាការគឺជាការចាំបាច់ក្នុងការកំណត់ និងផ្ទាស់ប្ដូរសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន ដោយយកប្រយោជន៍របស់កូនជាអាទិភាព និងដោយពិចារណាទៅលើស្ថានភាពនៃជីវភាព និងស្ថានភាពសេដ្ឋកិច្ចរបស់ឪពុកម្ដាយ "។

អថាខណ្ឌទី ២· អនុគតផែនទ្រព្យសម្បត្តិ (ផែនរបបតិកតណ្ឌ)

ចំណុចទី ១· ការជម្រះបញ្ជី

ដោយមិនត្រូវបានចាត់ទុកថាជាទ្រព្យសម្បត្តិរួមប្ដីប្រពន្ធ ទ្រព្យសម្បត្តិក្នុងអនីតិសង្វាសអាចត្រូវបានជម្រះតាមមធ្យោបាយដូចខាងក្រោម អាស្រ័យទៅតាមរបបតតិយុត្តនៃទ្រព្យសម្បត្តិនីមួយៗ។

១· អម្ចាស់ឯកាភាព

www.elibraryofcambodia.org
Scanned with CamScanner

ដោយសារមិនមានរបបមាតិកភ័ណ្ឌ ជាគោលការណ៍អនីតិសង្វាសជនម្នាក់ៗ ទទួលទ្រព្យក្នុងនាម ឱង ជាប្រយោជន៍ផ្ទាល់ខ្លួន។ ភស្តុតាងដើម្បីបញ្ជាក់អំពីទ្រព្យសម្បត្តិផ្ទាល់ខ្លួនអាចត្រូវបានបង្ហាញតាមគ្រប់មធ្យោបាយ។ នៅពេលដែលទ្រព្យសម្បត្តិត្រូវបានឡុកឡំគ្នា និងមិនអាចបែងចែកដាច់ពីគ្នាបាន ទ្រព្យសម្បត្តិទាំងនោះនឹងត្រូវចាត់ទុកជាទ្រព្យសម្បត្តិដែលនៅក្រោមរបបគតិយុត្តនៃកម្មសិទ្ធិរវិភាគ។

យើងត្រូវវែកញែកទៅតាមប្រភេទនៃទ្រព្យសម្បត្តិនីមួយៗ ដែលទ្រព្យសម្បត្តិនោះត្រូវបែងចែកទៅតាមចំណែករបស់អនីតិសង្វាសជននីមួយៗ បើសិនជាមានភស្តុតាងអាចបញ្ជាក់បាន ឬក្នុងចំណែកពាក់កណ្តាលស្មើៗគ្នា បើគ្មានភស្តុតាង [86]។ មាត្រា២០២ នៃក្រមរដ្ឋប្បវេណីកម្ពុជាកំណត់ថា "*ស្ថានភាពដែលបុគ្គលច្រើននាក់មានកម្មសិទ្ធិស្របទៅតាមភាគចំណែករបស់ខ្លួនដែលគិតទៅតាមចំនួននៅលើទ្រព្យតែមួយ ហៅថា កម្មសិទ្ធិរវិភាគ* "។ ហើយមាត្រា២០៣ នៃក្រមដដែលកំណត់ថា "*ចំណែកនៃម្ចាស់កម្មសិទ្ធិរវិភាគម្នាក់ៗ ត្រូវបានសន្មតថា ស្មើគ្នា* "។ ដូចនេះ ការបកស្រាយខាងលើ ស្របជាមួយបញ្ញត្តិស្តីពីកម្មសិទ្ធិរវិភាគនៃក្រមរដ្ឋប្បវេណី។

២. ក្រុមហ៊ុនអតីតឆ្មីនតាមអន្តរហេតុ

86 Philippe MALAURIE, Hugues FULCHIRON, *LA FAMILLE*, (Editions juridiques associés: DEFRENOIS, 2006), p168, paragraphe 330.

www.elibraryofcambodia.org
Scanned with CamScanner

ក្នុងករណីមួយចំនួន អនីតិសង្វាសជនទាំងពីរនាក់អាចបង្កើតក្រុមហ៊ុនមួយរវាងពួកគេ។ បើសិនជាមិនមានកិច្ចសន្យាក្រុមហ៊ុននោះទេ ភាគីណាម្ខាងអាចលើកឡើងថាមានការកកើតឡើងនូវក្រុមហ៊ុនកើតឡើងតាមអង្គហេតុ (société créée de fait)។ ក្នុងទិដ្ឋភាពគតិយុត្ត ក្រុមហ៊ុនប្រភេទនេះត្រូវចាត់ទុកជាអោឃៈតែត្រូវធ្វើការជម្រះបញ្ជី ដែលក្នុងករណីនេះម្នាក់ៗមានចំណែកភាគទុនស្មើៗគ្នា។ លក្ខខណ្ឌទាំងបីនៃកិច្ចសន្យាក្រុមហ៊ុនត្រូវតែបំពេញដូចជា៖ ទីមួយ ការដាក់ភាគទុនចូលគ្នា (ដែលអាចជាភាគទុនជាមូលធន ឬ ក្រៅពីមូលធន) ទីពីរ ការចូលរួមក្នុងការចំណេញ និង ការខាតបង់ និង ទីបី ឆន្ទៈរួមក្នុងការសហការគ្នា (ដែលឆន្ទៈរួមនេះ អាចកំណត់បានថាអនីតិសង្វាសជនណាម្នាក់មិនមែនជានិយោជិតនោះទេ)។

ដូចគ្នាដែរ មាត្រា៦៩៩ ក្រមរដ្ឋប្បវេណីកម្ពុជា បានកំណត់អំពីលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាក្រុមហ៊ុនដោយចែងថា "*កិច្ចសន្យាក្រុមហ៊ុន សំដៅទៅដល់កិច្ចសន្យាបង្កើតជាក្រុម ដែលគ្មានការរៀបចំលក្ខណៈជានីតិបុគ្គល ដើម្បីប្រកបកិច្ចការ ដោយសហការគ្នា ដោយភាគីនីមួយៗធ្វើការវិនិយោគទ្រព្យធនរៀងៗខ្លួន*"។ ហើយកិច្ចសន្យាក្នុងបញ្ញត្តិនេះ មិនចាំបាច់ជាកិច្ចសន្យាជាលាយលក្ខណ៍អក្សរនោះទេ។ ដូចនេះបញ្ញត្តិនេះអាចយកមកអនុវត្តនៅក្នុងករណីដែលអនីតិសង្វាសត្រូវបានរលាយ ហើយទាមទារឱ្យមានការជម្រះចំណែងនេះ។ តែការជម្រះបញ្ជីក្រុមហ៊ុនប្រភេទនេះ មិនមានបញ្ញត្តិឱ្យច្បាស់លាស់នៅក្នុងក្រមរដ្ឋប្បវេណី តែគួរតែអាចត្រូវបានជម្រះបញ្ជី

www.elibraryofcambodia.org
Scanned with CamScanner

តាមរបបកម្មសិទ្ធិអវិភាគ ដោយហេតុថាមាត្រា៧០១ នៃក្រម បានចាត់ទុកទ្រព្យសម្បត្តិក្រុមហ៊ុនស្ថិតនៅក្រោមរបបកម្មសិទ្ធិអវិភាគ។

នេះក៏ដោយសារថាមាត្រា៣ នៃច្បាប់ស្តីពីក្ស័យធនឆ្នាំ២០០៧ មានវិសាលភាពអនុវត្តតែចំពោះក្រុមហ៊ុនដែលមានបុគ្គលភាពគតិយុត្ត (ឌីតិបុគ្គល) និង ពាណិជ្ជករដែលបានចុះបញ្ជីតែប៉ុណ្ណោះ។ ការទាមទារគុណសម្បត្តិជាពាណិជ្ជករដែលបានចុះបញ្ជីក្នុងន័យនេះ ក៏ព្រោះថាមាត្រា១៤ថ្មី ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ទាមទារថាពាណិជ្ជករតាមផ្លូវច្បាប់ត្រូវមានការចុះបញ្ជីឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម។

៣. សេចក្តីចម្រើនដោយឥតហេតុ

នៅប្រទេសបារាំង តុលាការបានឈរទៅលើទ្រឹស្តីនៃសេចក្តីចម្រើនដោយឥតហេតុក្នុងការបែងចែកទ្រព្យសម្បត្តិរវាងអធិតិសង្ខាសជនផងដែរ។ ដោយសារវាជាមធ្យោបាយដែលគេតែងតែលើកឡើងជាញឹកញាប់ និង ត្រូវបានគេទទួលស្គាល់ជាទូទៅនោះ សេចក្តីចម្រើនដោយឥតហេតុអនុញ្ញាតឲ្យមានការស្តារឡើងវិញនូវសមធម៌នៃប្តី ប្រពន្ធដែលមិនបានរៀបអាពាហ៍ពិពាហ៍។ ឧទាហរណ៍ ប្រសិនបើអធិតិសង្ខាជនណាម្នាក់បានធ្វើការដើម្បីជាប្រយោជន៍ឲ្យភាគីម្ខាងទៀត ដោយគ្មានប្រាក់កម្រៃនោះទេ បុគ្គលខាងដើមអាចស្នើសុំទាមទារការបង់ប្រាក់កម្រៃសំណង

www.elibraryofcambodia.org
Scanned with CamScanner

នោះមកឱ្យខ្លួន ដោយឈរលើមូលដ្ឋាននៃសេចក្តីចម្រើនឥតហេតុដែលគាត់បានផ្តល់ទៅឱ្យភាគីម្ខាងទៀតនោះ និងមូលដ្ឋាននៃការចុះក្រឡូតដែលខ្លួនបានទទួល[87]។ សេចក្តីចម្រើនដោយឥតហេតុ ត្រូវគោរពលក្ខខណ្ឌចំនួនបួន គឺទីមួយ ភាគីម្ខាងទទួលបានសេចក្តីចម្រើន ទី២ ភាគីម្ខាងទៀត ទទួលនូវការបាត់បង់ផលប្រយោជន៍ ទីបី សេចក្តីចម្រើននោះមិនមានមូលហេតុតាមផ្លូវច្បាប់ និងទីបួន មានចំណងរវាងសេចក្តីចម្រើនឥតហេតុជាមួយនឹងការបាត់បង់ផលប្រយោជន៍។

ដូចគ្នាដែរ មាត្រា៧៣៦ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណីកម្ពុជា បានកំណត់អំពីលក្ខខណ្ឌ និងអានុភាពនៃសេចក្តីចម្រើនដោយឥតហេតុ ដោយសំដែងថា៖ "*ទោះបីជាគ្មានមូលហេតុលើផ្លូវច្បាប់ក៏ដោយ បុគ្គលដែលបានទទួលផលប្រយោជន៍ដោយសារទ្រព្យសម្បត្តិ ឬ ពលកម្មរបស់អ្នកដទៃ ហើយធ្វើឱ្យកើតមានការបាត់បង់ផលប្រយោជន៍ដល់អ្នកដទៃ ដោយសារការទទួលនោះ មានកាលៈកិច្ចសងផលប្រយោជន៍នោះ ត្រឹមកម្រិតដែលផលប្រយោជន៍នោះមាន*"។ កថាខណ្ឌទី២ នៃមាត្រាដែល កំណត់ថា៖ "*នៅក្នុងករណីដែលបានទទួលការផ្តល់តាវកាលិកពីអ្នកដទៃ ដោយយោលតាមកិច្ចសន្យា ប្រសិនបើកិច្ចសន្យានោះពុំមានអានុភាព ឬ ត្រូវបានបាត់បង់អានុភាព បុគ្គលដែលបានទទួលការផ្តល់តាវកាលិកនោះមានកាលៈកិច្ច*

87 Direction de l'information légale et administrative, *Séparation des concubins, article* publié le 12 décembre 2011. WWW.service-public.fr, date de consultation le 16 janvier 2014.

www.elibraryofcambodia.org
Scanned with CamScanner

កិច្ចត្រូវសងផលប្រយោជន៍ដែលខ្លួនបានទទួលដោយសារការផ្តល់តាវកាលិកនោះឲ្យទៅអ្នកដទៃដែលបានផ្តល់តាវកាលិកនោះវិញ ដូចគ្នាទឹងបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះដែរ"។

យើងឃើញថា ក្រមរដ្ឋប្បវេណីកម្ពុជា បានកំណត់ខ្វះលក្ខខណ្ឌនៃសេចក្តីចម្រើនឥតហេតុដូចគ្នាជាមួយអ្វីដែលច្បាប់បារាំងបានកំណត់។

ចំណុចទី ២. តើការធានារ៉ាប់រងនៃការខូចខាតករណីដែលអនីតិសង្វាសជនណាម្នាក់បានស្លាប់ដោយសារអំពើខុសច្បាប់ករណីសាលាភ្លើងត្រូវហាមដាច់ខាតឬទេ?

តាមពិតទៅអនីតិសង្វាសមិនមែនជា លិខិត ឬ សកម្មភាពគតិយុត្តទេ តែវាជាព្រឹត្តការណ៍គតិយុត្តដែលបង្កើតអានុភាពគតិយុត្ត។ មានន័យថា ក្នុងករណីអនីតិសង្វាសជន ឬ អនីតិសង្វាសឪណាម្នាក់បានស្លាប់ដោយសារអំពើអនីត្យានុកូលភាគីម្ខាងទៀតមិនមានសិទ្ធិណាមួយក្នុងការទាមទារសំណងដែលកើតចេញពីអំពើអនីត្យានុកូល ឬ បទល្មើសណាមួយនោះទេ នេះបើយើងទៅតាមការបកស្រាយមាត្រា ៧៦០ នៃក្រមរដ្ឋប្បវេណី និងមាត្រា១៣ (បណ្តឹងរដ្ឋប្បវេណី និងព្យសនកម្ម) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ យោងតាមមាត្រា៧៦០ កថាខណ្ឌទី៣ (ការទាមទារសំណងនៃការខូចខាតដោយការបំពានលើជីវិត) នៃក្រមរដ្ឋប្បវេណី បញ្ញត្តិថា "*បើជនរងគ្រោះទទួលមរណភាព ដោយអំពើអនីត្យានុកូល **សហព័ន្ធ ញាតិ**ធម៌ក្នុង ១*

www.elibraryofcambodia.org
Scanned with CamScanner

(មួយ) ថ្នាក់ និង ញាតិដែលរស់នៅជាមួយជនរងគ្រោះ អាចទាមទារសំណងនៃការខូចខាតសតិអារម្មណ៍ដែលកើតឡើង ដោយសារមរណភាពរបស់ជនរងគ្រោះនោះបាន "។ រីឯ មាត្រា១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កំណត់ថា៖ *" បណ្តឹងរដ្ឋប្បវេណីត្រូវអនុវត្តដោយជនរងគ្រោះនៃបទល្មើស។ ដើម្បីទទួលការផ្តល់សុជនបាន ព្យសនកម្មត្រូវតែ៖ -ជាផលវិបាកផ្ទាល់នៃបទល្មើស -ជាព្យសនកម្មផ្ទាល់ខ្លួន -បានកើតឡើងនិងនៅក្នុងពេលបច្ចុប្បន្ន។ ព្យសនកម្មអាចជាព្យសនកម្មខាងសម្ភារៈ ខាងរូបកាយ ឬខាងផ្លូវចិត្ត "។*

ក៏ប៉ុន្តែ ការកំណត់រឹតត្បិតតែទៅលើទំនាក់ទំនងញាតិ ដើម្បីជាលក្ខណៈក្នុងការទាមទារសំណងការខូចខាតផ្នែកសតិអារម្មណ៍បែបនេះ ដោយមិនបានពិចារណាទៅលើភាពចំបងនៃការខូចខាតផ្នែកសតិអារម្មណ៍របស់អធិតិសង្ឃាសជន (ចំណងតាមព្រឹត្តន័យ) ណាម្នាក់នោះ ថាតើវាសមហេតុផលដែរឬទេ។

ទោះជាយ៉ាងណាក៏ដោយ បញ្ហាសំណងនៃការខូចខាតនេះវាបានស្គាល់នូវការវិវត្តដែលគួរឱ្យកត់សម្គាល់ដែលស្តែងចេញឡើងនៅក្នុងសំណុំរឿងក្តីខ្នែរក្រហមដែលក្នុងនោះ តុលាការទទួលស្គាល់នូវអ្នកមាន *ចំណងពិសេសនៃសេចក្តីស្រលាញ់*[88]

---

88 អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, *សាលដីកា* (កាំង ហ្គេចអ៊ាវ ហៅ ឌុច) *ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១២, សំណុំរឿងលេខ ០០១/១៨ ខែកក្កដា ឆ្នាំ២០០៧,* ចំណុះទី៣២៨ ដល់ ៣៣៣, កថាខណ្ឌទី៤០៦ ដល់ ៤១១ ។ **សូមរកមើលផងដែរ៖** អង្គជំនុំជម្រះសាលា

www.elibraryofcambodia.org
Scanned with CamScanner

មានសិទ្ធិតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទាមទារសំណងការខូចខាតពីជនជាប់ចោទក្នុងសំណុំរឿង០០១/១៨ ខែកក្កដា ឆ្នាំ២០០៧ តែជាសំណងការខូចខាតផ្លូវចិត្ត និង សម្ភហភាពតែប៉ុណ្ណោះ។

ដោយឡែក ការយកយុត្តិសាស្ត្រដែលមាននៅក្នុងសំណុំរឿងផ្សេងក្រហមមកអនុវត្តនៅក្នុងសំណុំរឿងក្តីរដ្ឋប្បវេណីខាងលើ វាហាក់ដូចជាមិនមានការប៉ះពាល់ទៅដល់សន្តិសុខគតិយុត្តកម្ពុជានោះទេ ផ្ទុយទៅវិញវាបានបំពេញបន្ថែមទៅឱ្យប្រព័ន្ធច្បាប់កម្ពុជាទៅវិញ។ ពីព្រោះថា អនីតិសង្វាសជន ក៏ជាអ្នកទទួលរងគ្រោះផ្នែកផ្លូវចិត្តដែរ ហើយគោលបំណងនៃការផ្តល់សំណងផ្នែកផ្លូវចិត្ត គឺសង្គ្រោះផ្នែកផ្លូវចិត្ត ដោយមិនគួរពិចារណាតែអំពីចំណងញាតិតាមផ្លូវច្បាប់នោះទេ ពោលគឺគួរតែពិចារណា និងទទួលស្គាល់ចំណងតាមព្រឹត្តិយថផងដែរ។

ផ្អែកទៅលើការបកស្រាយខាងលើនេះ យើងអាចនិយាយបានថាក្រមរដ្ឋប្បវេណីកម្ពុជាត្រង់មាត្រា៧៦០ កថាខណ្ឌទី៣ ដែលចែងថា *"បើជនរងគ្រោះទទួលមរណភាព ដោយអំពើអនីតិឫទុក្ខល សហព័ន្ធ ញាតិនៅក្នុង ១ (មួយ) ថ្នាក់*

ប៉ុស្តិ៍នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, *សាលក្រម* (កាំង ហ្គេចអ៊ាវ ហៅ ឌុច) *ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, សំណុំរឿងលេខ ០០១/១៨ ខែកក្កដា ឆ្នាំ២០០៧*, កថាខណ្ឌទី៦៤២ និង ៦៤៣ ទំព័រ (ចំណុច ៤ ២ ២ អត្ថិភាពនៃទំនាក់ទំនងហេតុ និង ផលរវាងព្យសនកម្មរបស់ជនរងគ្រោះ និង កំហុសរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច)

www.elibraryofcambodia.org
Scanned with CamScanner

និងញាតិដែលរស់នៅជាមួយជនរងគ្រោះ អាចទាមទារសំណងនៃការខូចខាតសតិអារម្មណ៍ដែលបានកើតឡើង ដោយសារមរណភាពរបស់ជនរងគ្រោះនោះបាន" បង្កើតបានជាសច្ចធារណ៍តាមផ្លូវតុលាការ ដោយអ្នកទាំងនោះអាចទទួលបានសំណងខូចខាតផ្លូវចិត្ត ដោយមិនចាំបាច់បង្ហាញភស្តុតាងអំពីព្យសនកម្មផ្នែកសតិអារម្មណ៍។ ផ្ទុយទៅវិញ ដោយគ្រាន់តែបង្ហាញថាខ្លួនមានទំនាក់ទំនងញាតិជាមួយនឹងជនរងគ្រោះជាការស្រេច(បន្ទុកភស្តុតាង)។ ដូចគ្នាដែរ យើងក៏អាចនិយាយបានថា អនីតិសង្វាសជនណាម្នាក់ដែលទទួលរងព្យសនកម្មផ្លូវចិត្តអាចទាមទារសំណងការខូចខាតផ្នែកផ្លូវចិត្តបានដោយមានបន្ទុកត្រូវបង្ហាញភស្តុតាងអំពីព្យសនកម្មផ្លូវចិត្តដែលខ្លួនទទួលរងដោយសារមរណភាពរបស់អនីតិសង្វាសជនម្ខាងទៀត។ ការអនុញ្ញាតឲ្យអនីតិសង្វាសជនណាម្នាក់មានសិទ្ធិទាមទារសំណងការខូចខាតផ្នែកផ្លូវចិត្តដែលខ្លួនទទួលរងដោយសារមរណភាពរបស់អនីតិសង្វាសជនម្ខាងទៀតនេះ គឺផ្អែកលើទឡ្ហីករណ៍ចំនួនបី។ ទីមួយគឺ ដោយសារថាព្យសនកម្មជាមូលហេតុដែលនាំឲ្យមានការសងសំណង។ ទីពីរគឺដោយសារតែការផ្តោតទៅលើការទទួលរងព្យសនកម្មជាជាងទៅលើទំនាក់ទំនងញាតិ គឺជាការសមហេតុសមផលចំពោះអ្នកទាមទារសំណងជាអនីតិសង្វាសជន។ និង ទីបី ព្រមទាំងគោរពបានខ្វះលក្ខណ្ឌស្តីពីអំពើអនីតិ្យនុកូលដែលមានចែងក្នុងមាត្រា ៧៤៣[89] នៃក្រមខាងលើទៀតផង។

---

[89] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/

www.elibraryofcambodia.org
Scanned with CamScanner

កាន់តែតាំទ្រឱ្យការបកស្រាយខាងលើនេះកាន់តែមានទម្ងឹកករណ៍ដ៏រឹងមាំមួយ មាត្រា ១២៩៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីថ្មីកម្ពុជា បានផ្តល់សិទ្ធិទៅឱ្យ "*បុគ្គលដែលមានឱស្ថ័យពិសេស*" ក្នុងការទទួលបានមរតករបស់មតកជន។ យោងតាមបញ្ញត្តិនេះ បុគ្គលដែលមានឱស្ថ័យពិសេសនេះ អាចជា "*ជនដែលមានជីវភាពជាមួយគ្នាទឹងមតកជន ជនដែលបានមិតទំរើលថែទាំព្យាបាលមតកជន និងជនដែលមានឱស្ថ័យពិសេសផ្សេងទៀត*"។ តែតុលាការអាចបែងចែកមរតកឱ្យបានតែក្នុងករណីដែល តុលាការឃើញថាសមរម្យ មរតកជាផ្នែកដែលនៅសល់ក្រោយការជម្រះ មានពាក្យសុំរបស់ជននោះ និង ចំនួនសរុបនៃតម្លៃដែលត្រូវចែកទៅឱ្យមិនត្រូវលើសពីចំនួនពាក់កណ្តាលនៃមរតកដែលនៅសល់នោះទេ។

រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, អាត្រា ៧៤៣ លក្ខខណ្ឌ និងការទទួល ខុសត្រូវ ក្នុងការបញ្ជាក់បង្ហាញឯអំពើអនីត្យានុកូលទូទៅ។

១- បុគ្គលដែលប៉ះពាល់ដោយខុសច្បាប់ទ្វេសិទ្ធិ ឬផលប្រយោជន៍របស់អ្នកដទៃដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែល កើតឡើងដោយ អំពើនោះ។

២- បញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលការខូចខាតបានកើតឡើង ដោយសារមានករណីយកិច្ចធ្វើអំពើណាមួយ តែមិនបានធ្វើអំពើនោះ។

៣- ចំពោះកំហុសចេតនា ឬអចេតនារបស់ចារីនេះ ទំនាក់ទំនងនៃហេតុផងរវាងអំពើរបស់អ្នកប្រព្រឹត្តអំពើប៉ះពាល់ និង ការកើតឡើងនៃការខូចខាត និងការខូចខាតដែលកើតមានឡើងលើជនរងគ្រោះ បុគ្គលដែលទាមទារសំណងការខូចខាតត្រូវបញ្ជាក់បង្ហាញ លើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងក្រមនេះ ឬច្បាប់ផ្សេងទៀត។

www.elibraryofcambodia.org
Scanned with CamScanner

ចំណុចទី ៣- ការផ្តល់ទ្រព្យសម្បត្តិរវាងអនីតិសង្វាសជន៖ សន្ធានាន

(Libéralités)

នៅក្នុងនីតិបារាំងចាស់ ជាគោលការណ៍ សន្ធាទានរវាងអនីតិសង្វាសជន មានសុពលភាព។ ក៏ប៉ុន្តែ តុលាការបារាំងក្នុងនាមជានិយ័តករសង្គមបានត្រួតពិនិត្យមើលទៅលើមូលហេតុនៃសន្ធាទាននោះ។ បើសិនជាវាផ្ទុយនឹងសីលធម៌ នោះត្រូវចាត់ទុកជាអោយៈ។ ឧទាហរណ៍ ការផ្តល់ប្រាក់រវាងអនីតិសង្វាសជនដើម្បីទំនាក់ទំនងផ្លូវភេទ ការផ្តល់ឱ្យនេះត្រូវចាត់ទុកជាអោយៈ ដោយសារមូលហេតុនៃអសីលធម៌ និង ខុសច្បាប់។ តែក្រោយមកនៅឆ្នាំ២០០៤ តុលាការកំពូលបារាំង បានធ្វើការកែប្រែទស្សវត្តិសាស្ត្ររបស់ខ្លួនដោយចាត់ទុកថា មិនចាត់ទុកជាអោយៈទេ សន្ធាទានរវាងអនីតិសង្វាសជនក្នុងអំឡុងពេលទំនាក់ទំនងផ្លូវភេទនោះ ដោយសារវាមិនផ្ទុយនឹងទំនៀមទំលាប់ដ៏ល្អទេ។ នេះក៏ដោយសារតែការ វិវឌ្ឍន៍នៃជីវិតឯកជនរបស់ពលរដ្ឋ[90]។

បើក្រឡេកមកមើលច្បាប់កម្ពុជាវិញ មាត្រា៣៥ ក្រឹត្យ-ច្បាប់ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា លេខ៣៨ ក្រ.ច ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ ១៩៨៨ បានសំដែងថា៖ "*ត្រូវចាត់ទុកជាអោយៈ* [...] - *ការលក់វត្ថុពីប្តីទៅឱ្យប្រពន្ធ*

90 Philippe MALAURIE, Hugues FULCHIRON, *LA FAMILLE*, (Editions juridiques associés: DEFRENOIS, 2006), p172 et 173, paragraphe 335.

www.elibraryofcambodia.org
Scanned with CamScanner

ឬ ពីប្រពន្ធទៅឲ្យប្តី [...]" ។ យើងឃើញមានតែការហាមលក់វត្ថុរវាងប្តីប្រពន្ធតែប៉ុណ្ណោះ តែមិនបានហាមការលក់ ឬផ្ទេរកម្មសិទ្ធិលើវត្ថុតាមរបៀបផ្សេងទៀត រវាងអនីតិសង្វាសជននោះទេ។ តែមាត្រា៧៩ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលចូលជាធរមានចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ (យោងតាមមាត្រា៨៤ នៃច្បាប់នេះ) បានទិភាករណ៍បញ្ញត្តិនៃក្រឹត្យច្បាប់លេខ៣៨ (រួមទាំងមាត្រា៣៥) លើកលែងតែមាត្រា៨៣ ដល់ មាត្រា៨៨។

ទោះជាយ៉ាងណាក៏ដោយក៏ សម្ភាទានទ្រព្យសម្បត្តិរវាងអនីតិសង្វាសជនទាំងពីរ ត្រូវគោរពគោលការណ៍ទូទៅនៃការបង្កើតកិច្ចសន្យាដែរ បើពុំនោះទេ វាត្រូវចាត់ទុកជាអោយៈ។ ជាប្រត្យក្ស មាត្រា៥ នៃក្រឹត្យច្បាប់លេខ៣៨ បានបញ្ញត្តិថា៖ *"ត្រូវចាត់ទុកជាអោយៈអាថ៌ខាត -កិច្ចសន្យាទាំងឡាយណាដែលមិនស្របទឹងរបៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ ឬ ទំនៀមទំលាប់ដ៏ល្អប្រពៃ។ - កិច្ចសន្យាទាំងឡាយណាដែលមិនស្របទឹងផលប្រយោជន៍សង្គម ឬ មិនស្របទឹងគោលការណ៍សីលធម៌សង្គម។ - កិច្ចសន្យាទាំងឡាយណាដែលមានតាវកាលិក កម្មវត្ថុនៃកិច្ចសន្យា មិនអាចធ្វើកើត "*។ ហើយមាត្រា៦ បន្តថា *"អាចទុកជាអោយៈបាន៖ - កិច្ចសន្យាទាំងឡាយណាដែលមិនកើតចេញពីការព្រមព្រៀងដោយពិតប្រាកដ ឬ ដោយសេរី។ - កិច្ចសន្យាទាំងឡាយណាដែលមិនកើតចេញពីបុគ្គលមានសមត្ថភាពចុះកិច្ចសន្យា "*។ ក្រមរដ្ឋប្បវេណី ត្រង់មាត្រា៣៥៤ កថាខណ្ឌទី១ ចែងថា៖ *"ទោះបី*

www.elibraryofcambodia.org
Scanned with CamScanner

ជាភាគីនៃកិច្ចសន្យាចានធ្វើការបង្ហាញធន្លុះដោយគ្មានវិការៈកំណាយ ក៏កិច្ចសន្យាត្រូវ
ចានចាត់ទុកជាមោយៈ ក្នុងករណីខាងក្រោមនេះ ក- អត្ថន័យនៃកិច្ចសន្យានោះផ្ទុយ
និងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ។ ខ- អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹង
សណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទំលាប់ល្អ"។

ដូច្នេះ សំណួរដែលចោទឡើងនោះ ថាតើតុលាការត្រូវប្រកាន់ជំហរយ៉ាង
ដូចម្តេចចំពោះការការពារសីលធម៌ និង ប្រពៃណីដ៏ល្អរបស់សង្គម ក្នុងករណីមាន
បណ្តឹងសុំលុបចោល ឬ មោឃភាពការផ្ទេរទ្រព្យសម្បត្តិរវាងអនីតិសង្វាសជន៕

www.elibraryofcambodia.org
Scanned with CamScanner

សេចក្តីសន្និដ្ឋាន

ឥទ្ធិពលនៃការយកបទប្បញ្ញត្តិស្តីពីអាពាហ៍ពិពាហ៍មកអនុវត្តន៍ក្នុងរឿងក្តីអនីតិសង្វាស កំពុងតែនាំឲ្យមានអសន្តិសុខគតិយុត្តក្នុងប្រព័ន្ធច្បាប់ត្រួសារកម្ពុជា ព្រោះថាអាពាហ៍ពិពាហ៍ (ជាសកម្មភាព ឬ លិខិតគតិយុត្ត) និង អនីតិសង្វាស (ព្រឹត្តិការណ៍គតិយុត្ត) មានភាពខុសគ្នាច្រើន។ តែស្ថានភាពគតិយុត្តមួយចំនួនអាចឲ្យយើងយកបញ្ញត្តិស្តីពីអាពាហ៍ពិពាហ៍មកអនុវត្តន៍នៅក្នុងរឿងអនីតិសង្វាសបាន បើវាមានភាពស្រដៀងគ្នា (raisonnement a pari ou a simili ou par analogie)[91] តែមានដែនកំណត់របស់វា ជាក់ស្តែងបទប្បញ្ញត្តិស្តីពីអាពាហ៍ពិពាហ៍អាចយកទៅអនុវត្តន៍នៅក្នុងរឿងអនីតិសង្វាសបានតែក្នុងវិស័យរដ្ឋប្បវេណីមួយចំនួនតែប៉ុណ្ណោះ មិនអាចអនុវត្តន៍បាននៅក្នុងវិស័យព្រហ្មទណ្ឌបានឡើយ ដោយសារថាច្បាប់ព្រហ្មទណ្ឌត្រូវបកស្រាយតឹងរ៉ឹង។ វាដូចគ្នាជាមួយនឹងការលើកឡើងរបស់លោកសាស្ត្រាចារ្យ សុឹម សុខម្ន ដែលថា "*វិធីបកស្រាយបែបសទិសវិធី ឬ តាមវិធីប្រដូចនេះត្រូវប្រើដោយប្រយ័ត្នប្រយែងបំផុតក្នុងរឿងព្រហ្មទណ្ឌ ដើម្បីធានាបាននូវការ*

---

91 សាស្ត្រាចារ្យ សុឹម សុខម្ន, *បរិច្ឆេទសេស និង វិធីសាស្ត្របកស្រាយបទដ្ឋានគតិយុត្តនានា*, (រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ, កញ្ញា ២០០៩), ទំព័រទី៦ ចំណុច ១-១- វិធីបកស្រាយ ឬធ្វើវិចារណកិច្ចតាមសទិសវិធី ឬតាមវិធីប្រដូច។

www.elibraryofcambodia.org
Scanned with CamScanner

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ
មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ
ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្តេនជា eBook ដោយ ហៃ គីមសាន
ខែធ្នូ ឆ្នាំ២០១៦
បើលោក លោកស្រី ចង់បានសៀវភៅនេះ ឬអានបន្តរទៀត
សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សារសិទ្ធ" របស់អ្នកនិពន្ធ។
យើងខ្ញុំ ពុំមានការប្រស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយ
អ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ
ខ្ចៅ ឃុនសំរ៉ង
ប្រធានមូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

www.elibraryofcambodia.org

Scanned with CamScanner